ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង

**ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩**

**សវនាការលើអង្គសេចក្តី (លើកទី១២)**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវ៉ែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង

លោក ម៉ាត្ទូ គ្រីស្តារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ បេ៊ិត

*(Mr. Alexander Bates)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទួអាត ហ្វដ *(Mr.stuart FORD)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**មេធាវីការពារជនជាប់ចោទ កាំង ហ្កេក អ៊ាវ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រ៉ូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms.Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក យុង ផានិត

លោគ គឹម ម៉េងឃី

លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី

*(Ms. Silke Studzinsky)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោក ហ្វីលីព កាណុន

*(Mr. Philippe Cannone)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សី ៖** ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច

សួរបន្តដោយ ចៅក្រម យ៉ា សុខន ផ្តើមពី ....................ទំព័រ ១៣
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................ទំព័រ ១៤
សួរដោយ ចៅក្រម យ៉ា សុខន ផ្តើមពី ....................ទំព័រ ១៥
សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ៣៣
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ផ្តើមពី ....................ទំព័រ ៥៤
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................ទំព័រ ៥៩

## បញ្ជីឈ្មោះ អ្នកនិយាយ៖

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ | បារាំង |
| ចៅក្រម យ៉ា សុខន | ខ្មែរ |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធាអង្គជំនុំជម្រះ) | ខ្មែរ |
| លោក អាឡិចសាន់ឌឺ ប៊េត | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្តី | អង់គ្លេស |
| លោក ហ្វីលីព កាណុន | បារាំង |
| លោគ គឹម ម៉េងឃី | ខ្មែរ |
| លោក គង់ ពិសី | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | បារាំង |
| លោក តាន់ សេណារ៉ុង | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:០៥:០៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តសវនាការពិភាក្សាដេញដោលលើអង្គហេតុ ការបង្កើតមន្ទីរសន្តិបាល ស-២១ និងគុកនៅមន្ទីរពេទ្យឆ្កួតតាខ្មៅ ។ ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និង អវត្តមានភាគី ដែលត្រូវចូលរួមសវនាការនៅថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ភាគីដែលបានចូលរួមក្នុងដំណើរការនីតិវិធីសវនាការក្នុងថ្ងៃនេះមាន វត្តមានគ្រប់ចំនួនហើយ ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីចាត់បញ្ចូលរបាយការណ៍ស្តីអំពីស្ថានភាពវត្តមាន អវត្តមានភាគីដែលត្រូវចូលរួម សវនាការនៅថ្ងៃនេះទៅក្នុងប្រតិចារឹក ។ ជាកិច្ចបន្ត អង្គជំនុំជម្រះសូមសួរទៅមេធាវីការពារក្តីថា តើ មានបញ្ហាអ្វីដែលត្រូវចង់លើកឡើង ឬក៏ធ្វើការកត់សម្គាល់អំពីឯកសារមួយដែលជាសៀវភៅ ដែលសុំ ធ្វើការបែងចែកដោយសហព្រះរាជអាជ្ញាកាលពីថ្ងៃទី២៣ ខែមេសា កន្លងមកដែរឬទេ? ហើយតើលោក ជំទាស់ទៅនឹងរបៀបបង្ហាញឯកសារដែលបាន ដែលមាននៅក្នុងសំណុំរឿងដែលបានលើកឡើងដោយ សហព្រះរាជអាជ្ញា ឬក៏មានបញ្ហាអ្វីបន្ថែមបញ្ជាក់លើនេះ?

បើមានសូមលោកមេធាវីអញ្ជើញ ។

លោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណ លោកប្រធាន ។ មេធាវីការពារបានពិនិត្យឯកសារនេះយ៉ាងល្អិតល្អន់ ដែលសហ ព្រះរាជអាជ្ញាបានដាក់ជូនតុលាការ ក្នុងពេលសវនាការថ្ងៃចុងក្រោយពីសប្តាហ៍មុន ។ ខ្ញុំយោងទៅរក ឯកសារដែលមានៗរូបថតមួយចំនួននៅក្នុងនោះផង ។ នេះជាឯកសារមួយ ដែលមេធាវីការពារសូម

បញ្ជាក់ដូចខាងក្រោមនេះ ៖

មេធាវីការពារបានយល់យ៉ាងច្បាស់អំពីការកំណត់ ការណែនាំរបស់អង្គជំនុំជម្រះថាឲ្យភាគីអាចលើកសំណើររបស់ខ្លួន ដើម្បីដាក់បញ្ចូលនៅក្នុងភស្តុតាងជាកំណត់ត្រា ជាឯកសារនៅក្នុងសំណុំរឿង ។ ប៉ុន្តែ ឯកសារដែលត្រូវបានដាក់ឡើងដោយសហព្រះរាជអាជ្ញានោះៗ មិនមែនជាឯកសារនៅក្នុងសំណុំរឿងនោះទេ គឺជាសេចក្តីដកស្រង់មួយនៃសំណុំរឿង ហើយជាខុសគ្នាទាំងស្រុង ។ សហព្រះរាជអាជ្ញាបានដកស្រង់ បានជ្រើសរើសឯកសារមួយចំនួន ដែលដកស្រង់តែមួយផ្នែកពីក្នុងសំណុំរឿងដែលថា ជាឯកសារតែមួយផ្នែកតែប៉ុណ្ណោះ ហើយបានលើកឡើងដែលថា ជាការជ្រើសរើសរបស់ខ្លួនដែលមានតែមួយផ្នែកតូចមួយ ។ ដូច្នេះហើយជាចាំបាច់វាមានលក្ខណៈលម្អៀងនៅក្នុងនោះ មុនពេលដែលជនជាប់ចោទត្រូវបានសួរចប់សព្វគ្រប់ពីបញ្ហានេះ ។

[០៩:១០:៣១]

មេធាវីការពារសូមស្នើសុំឲ្យមានការបំភ្លឺអំពីចំណុចនោះ ។ ទាក់ទងនឹងបញ្ហានេះជាឧទាហរណ៍ទាក់ទងទៅនឹងរូបថតរបស់ការសម្តែងឡើងវិញដែលបញ្ជូន ដែលបង្ហាញដោយការិយាល័យសហព្រះរាជអាជ្ញា មានតែរូបថតមួយចំនួនទេដែលត្រូវបានជ្រើសរើសយកមកប្រើដោយសហព្រះរាជអាជ្ញាដែលបានដាក់ចូលនៅក្នុងឯកសារ ។ ដូច្នោះហើយ វាមានន័យថា មេធាវីការពារគប្បីត្រូវផ្តល់ជូនឲ្យលោកចៅក្រមអំពីរូបថតផ្សេងទៀតដែលថា ខុសពីអ្វីដែលសហព្រះរាជអាជ្ញាបញ្ជូននោះទេ ហើយយើងនឹងបាត់បង់ យើងត្រូវប្រើពេលវេលាច្រើន បើយើងធ្វើដូច្នោះ ។

យើងបានយល់ច្បាស់ថា បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងនឹងចោទសំណួរទៅជនជាប់ចោទ ឬក៏សាក្សីនោះ មេធាវីក៏-- ពេលនោះភាគីអាចនឹងស្នើ ឬក៏និយាយឲ្យបានត្រឹមត្រូវជាងនេះ ឬក៏អាចស្នើសុំឲ្យ ឲ្យដាក់ចូលភស្តុតាងនោះចូលទៅក្នុងកំណត់ត្រា គឺថាឯកសារភស្តុតាងនោះ វានៅក្នុងសំណុំរឿងរួចស្រេចទៅហើយ ។ ហើយមានតែពេលនោះទេ ដែលភាគីនានាអាចជ្រើសរើសយកភស្តុតាងដែលខ្លួនអាចនឹងសម្រេចថានឹងយកមកប្រើនៅពេលណា ចំណុចណាបាន ។ សហព្រះរាជអាជ្ញាអាចនឹងជ្រើសនូវឯកសារ ឬក៏*ម៉ែតធីរៀល* ឬក៏ឧបករណ៍អ្វី របស់របរអ្វីដែលថា ខ្លួនចង់យកមកប្រើ ។ ហើយមេធាវីការពារក៏នឹងជ្រើសរើសយកឯកសារដែលគាំទ្រ និងដែលគាំទ្ររឿងក្តីរបស់ខ្លួននោះដែរ ។ ប៉ុន្តែ អ្វីដែលយើងមិនចង់ឃើញនៅទីនេះនោះគឺថា ការិយាល័យសហព្រះរាជអាជ្ញា មុនពេលដែលបានសួរជនជាប់ចោទ ហើយនឹងមុនពេលសាក្សីផ្តល់សក្ខីកម្ម ព្រះរាជអាជ្ញាបានជ្រើសរើសយកឯកសារនៅ ក្នុងសំណុំ

រឿង ហើយបានបង្ហាញទៅដល់អង្គជំនុំជម្រះទោះបីជាមានការជំទាស់យ៉ាងណាក៏ដោយ ។

ដូច្នេះ ទោះជាសហព្រះរាជអាជ្ញាក៏ដោយ ដោយគាត់បានដាក់ឲ្យឯកសារហ្នឹងជូនអង្គជំនុំជម្រះទាំងស្រុងនោះក៏ដោយ នៅពេលសមស្របក៏ដោយ ឬប្រសិនបើខ្លួនចង់ធ្វើការជ្រើសរើសឯកសារនោះ ខ្លួនត្រូវរង់ចាំដល់ជនជាប់ចោទ ឬក៏ហើយនិងសាក្សីផ្តល់សាក្ខីកម្មឲ្យបានចប់សព្វគ្រប់សិនដែរ ។ នេះជាចំណុចដែលខ្ញុំចង់លើកឡើង ដែលថាមេធាវីការពារចង់បញ្ជាក់នូវសេចក្តីសង្កេតរបស់ខ្លួន ដែលខ្លួនស្នើសុំឲ្យអង្គជំនុំជម្រះមេត្តាផ្តល់ការបំភ្លឺ ដែលថាមេធាវីការពារបានត្រៀមខ្លួនជាស្រេចទោះបីជាមិនបានធនធានរបស់ខ្លួនមិនគ្រប់គ្រាន់ដូចដែលខាងសហព្រះរាជអាជ្ញាមានក៏ដោយ ។ មេធាវីការពារបានត្រៀមខ្លួនជាស្រេចដើម្បីធ្វើការ ដើម្បីដាក់ជូនអង្គជំនុំជម្រះសាលាដំបូងនូវរូបភាព រូបថតទាំងអស់ ហើយមិនមែនតែរូបថតមួយចំនួនដែលខ្លួនជ្រើសរើសប៉ុណ្ណោះនោះទេ ។

[០៩:១៤:២៣]

ខ្ញុំយល់ឃើញថា ហ្នឹងគឺថា បើធ្វើការជ្រើសរើសមួយចំនួនតូចតែប៉ុណ្ណោះ គឺថានឹងខ្ជះខ្ជាយពេលច្រើន ។ ខ្ញុំសូមអនុញ្ញាតិសង្ខេប ចំណុចដែលជាបញ្ហានៅទីនេះ គឺសហព្រះរាជអាជ្ញា គឺបង្ហាញតែរូបថតមួយចំនួនដែលខ្លួនបានជ្រើសរើសចេញពីឯកសារដែលដកស្រង់ចេញពីសំណុំរឿង ។ គឺថា គឺជាការបកស្រាយដែលមិនមែនជា មានលក្ខណៈសត្យានុម័តិទេ មានលក្ខណៈជាអត្តនោម័តិ ។ នេះគឺជាករណី ឬក៏ការគាំទ្ររបស់សហព្រះរាជអាជ្ញាខ្លួនឯង ហើយវាបានលើកឡើងមុនកាលកំណត់ដែលត្រូវលើក ។

ខ្ញុំសូមអរគុណលោកប្រធាន! ខ្ញុំបានបញ្ជាក់ពីទស្សនៈដែលមេធាវីការពារបានយល់ដឹង ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញា ។

**លោក អាឡិចសាន់ឌឺ ប៊េត៖**

មានបញ្ហាពីរនៅក្នុងមតិយោបល់ នៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ។ ចំណុចទីមួយ អង្គជំនុំជម្រះបានស្នើសុំឲ្យភាគនានាផ្តល់នូវការជូនដំណឹងឲ្យបានពិស្តារអំពីឯកសារនានា ដែលថាឯកសារនោះ ដែលថា ភាគីចង់ពឹងផ្អែក ឬក៏ចង់លើកឡើង ដើម្បីវិភាគពិចារណាជូនអង្គជំនុំជម្រះ ។ នេះជាគោលបំណង ដែលយើងខ្ញុំដាក់សំណុំឯកសារនេះជូនអង្គជំនុំជម្រះសាលាដំបូង ដើម្បីជួយឲ្យតុលាការហ្នឹងកាន់តែយល់ច្បាស់ ហើយខ្លួនក៏បានគោរពទៅតាមអ្វីៗដែលបានបញ្ជាក់នៅក្នុងសេចក្តីសម្រេច នៅក្នុងៗសវនាការបឋមនោះដែរ ឬក៏នៅក្នុងសវនាការរៀបចំ សវនាការជំនុំជម្រះ ។

ហើយខ្ញុំជឿថាចៅក្រម ឡាវែន៍ បានបញ្ជាក់បង្ហាញថា ប្រសិនបើក្នុងពេលណាសមស្របភាគីអាចៗដាក់ឯកសារជារូបថត នៅក្នុងសំណុំរឿងជូនអង្គជំនុំជម្រះ ដើម្បីជួយឲ្យអង្គជំនុំជម្រះអាចនឹងយល់កាន់តែច្បាស់ ។ អ៊ីចឹងហើយចំណុចជាបឋមគឺថា ឯកសារដែលយើងបានដាក់ជូននេះ ដើម្បីជួយដល់តុលាការនៅក្នុងរឿងក្តី ។

[០៩:១៦:៥៣]

ចំណុចទីពីរ គឺថាជាការត្រឹមត្រូវណាស់ដែលថា យើងអាចនិយាយថា គឺជាការជ្រើសរើសយកមួយចំនួននូវរូបថត ដែលដកស្រង់អំពីឯកសារវត្ថុតាងទាំងស្រុងនៅក្នុងសំណុំរឿង ។ សុំអភ័យទោសប្រសិនជាខ្ញុំលើកឡើងខុសគឺថា គឺសហព្រះរាជអាជ្ញាខ្លួនមានបន្ទុកក្នុងការបង្ហាញភស្តុតាងពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។ ហើយតាមពិតសហព្រះរាជអាជ្ញាខ្លួនឯង នឹងស្វែងរកនូវការដាក់ជូននូវឯកសារជូនដល់អង្គជំនុំជម្រះអំពីអ្វីដែលថាខ្លួនពឹងផ្អែកលើកឯកសារនោះ ដើម្បីគាំទ្រពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។

ប៉ុន្តែ នេះគឺជាប្រព័ន្ធដឹកនាំដោយភាគីដែលមានយុត្តិធម៌ ។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីគឺអាចជ្រើសរើសយកឯកសារ ឬផ្នែកណាមួយនៃឯកសារដែលខ្លួនយល់ថាជាបង្អែករបស់ខ្លួននោះ ។

ខ្ញុំក្រែងថា ខ្ញុំមិនយល់ច្បាស់ ពីដែលលើកឡើង-- មេធាវីលើកឡើងថា ការខ្វះខ្លាយពេលនោះគឺថា ដូច្នេះ គឺសហព្រះរាជអាជ្ញាបានប្រើកិច្ចប្រឹងប្រែង ដើម្បីសន្សំពេលយើងបានប្រើឯកសារមួយចំនួនតូច ដើម្បីសន្សំពេល ដែលយើងជឿជាក់ថា ជាការគាំទ្រនូវទ្រឹស្តីរឿងក្តីរបស់ខ្លួន ។

មេធាវីការពារក៏មានសិទ្ធិនឹងធ្វើដូច្នោះបានដែរ ដើម្បីបញ្ចប់មតិរបស់ខ្ញុំ គឺសហព្រះរាជអាជ្ញាគឺបានលើកឡើងនូវឯកសារនេះជូនអង្គជំនុំជម្រះ គឺមិនមែននៅក្នុងការវិភាគរបស់ខ្លួន ឬក៏ជាសេចក្តីសន្និដ្ឋានរបស់ខ្លួន ។ ដើម្បីនឹងធ្វើដូច្នោះបាន នឹងតម្រូវឲ្យៗមានជាសេចក្តីសន្និដ្ឋានពីរ ឬសំណើពីរ ថាតើតើអាចនឹងដាក់ជូនឯកសារទៅអង្គជំនុំជម្រះដូចម្តេចបាន បើមិនធ្វើតាមរបៀបនេះ?

លោកប្រធានបានផ្តល់ឱកាសថា បានឲ្យឯកសារយើងនៅព្រឹកនេះ ដែលយើងបានរៀបចំគឺថាដែលថា ដែលយើងមានបំណងថាយើងនឹងយកប្រើជាបង្អែក ដែលទាក់ទងទៅនឹងបញ្ហាបច្ចុប្បន្ននេះ ។ បញ្ហាដែលខ្ញុំលើកឡើងបញ្ហានេះគឺដោយហេតុថា វាអាចនឹងជួយដល់ៗភាគីទាំងអស់ ប្រសិនបើតុលាការនឹងផ្តល់នូវការណែនាំឲ្យរឹងមាំមួយដែលថា តើខ្លួនកំណត់ភាគីឲ្យដាក់ឯកសារយ៉ាងដូចម្តេច?

ឯកសារដែលយើងបានរៀបចំព្រឹកនេះ ជាឯកសារមួយទំព័រ ដែលដាក់បញ្ជូនថាមានឯកសារបួន

យ៉ាងដែលយើងនឹងប្រើជាបង្អែក នៅក្នុងការសួរតទល់ជាមួយនឹងជនជាប់ចោទ ។ នោះគឺជាសំណើមួយពីសហព្រះរាជអាជ្ញា ។ តើអង្គជំនុំជម្រះសាលាដំបូងអាចទទួលយកបាន? បើដូច្នោះយើងខ្ញុំនឹងស្នើធ្វើដូច្នេះ ដើម្បីជូនដំណឹងជាមុនថា សហព្រះរាជអាជ្ញានឹងប្រើឯកសារអ្វីខ្លះជាបង្អែក ។ អ៊ីចឹងហើយខ្ញុំលើកពីខាងដើម អ្វីដែលយើងមានគោលបំណងនឹងធ្វើ និងផ្តល់នូវឯកសារ និងរូបថតមួយចំនួនដែលមានមួយសំណុំ ដែលយើងបានធ្វើពីសប្តាហ៍មុន ។

ប៉ុន្តែ សហព្រះរាជអាជ្ញាមិនបានសុំទោសដែលថា ខ្លួនមិនជ្រើសទាំងអស់ គឺថាយើងជ្រើសរើសមួយផ្នែកដែលថាមានពាក់ព័ន្ធ ដែលថាមិនមានការពាក់ព័ន្ធយើងមិនជ្រើសរើសទេ ។ អ៊ីចឹងហើយសង្ឃឹមថា ខាងមេធាវីក៏នឹងធ្វើដូច្នោះដែរ ។ សូមអរគុណ ។

[០៩:២០:៣០]

**ប្រធានអង្គជំនុំ៖**

មេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី តើមានអ្វីចង់លើកឡើង ឬកត់សម្គាល់អំពីការដែលលើកឡើងដោយសហព្រះរាជអាជ្ញា អំពីការបែងចែកនូវសៀវភៅ ដែលបានដកស្រង់នូវរូបភាព ដែលបានចែកជូនកាលពីថ្ងៃទី២៣ នៅពេលចុងសវនាការ ។ តើលោកមានយោបល់ពាក់ព័ន្ធនឹងបញ្ហាហ្នឹងទេ?

បើមានសូមអញ្ជើញ។

**លោក អាឡាំង វ៉ែនណឺ៖**

លោកចៅក្រម! អរុណសួស្តី សូមគោរពលោកចៅក្រម!

ក្នុងនាមមេធាវីក្តី គឺយើងខ្ញុំគាំទ្រសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ។

សូមអរគុណលោកប្រធាន និងលោក លោកចៅក្រមជាទីគោរព ។

**ប្រធានអង្គជំនុំ៖**

មេធាវីក្រុមពីរ បើមានសូមអញ្ជើញ។

**លោក គង់ ពីសី៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន និង លោក លោកស្រីចៅក្រមទាំងអស់!

ខ្ញុំសូមធ្វើការចាប់អារម្មណ៍បន្តិច ទាក់ទងទៅនឹងឯកសាររបស់ព្រះរាជអាជ្ញា ហើយខ្ញុំក៏សូមគាំទ្រពីបញ្ហាដែលដាក់របស់ព្រះរាជអាជ្ញាហ្នឹងដែរ ។ ហើយក៏សូមឆ្លើយតបទៅនឹងមេធាវីការពារ ខ្ញុំជឿថា លោកមេធាវីការពារ គាត់ការពារក្តីច្រើនរឿងណាស់ហើយ មានបទពិសោធន៍ច្រើនណាស់ហើយ គឺ

ថា និយាយអំពីទាក់ទងទៅនឹងការដាក់បន្ទុកនិងការបង្ហាញភស្តុតាង ។ ហើយគាត់បានលើកឡើង ដាក់បន្ទុកនិងបង្ហាញភស្តុតាង គឺជាភារកិច្ច ជាកាតព្វកិច្ចរបស់ព្រះរាជអាជ្ញា គឺត្រូវតែដាក់បន្ទុក និងការបង្ហាញភស្តុតាង ។

[០៩:២២:០៩]

អ៊ីចឹង រាល់ឯកសារទាំងអស់គឺគាត់លើកយកមក គឺដើម្បីធ្វើការដាក់បន្ទុកក្នុងការបង្ហាញភស្តុតាង។ ហើយចំពោះលោកមេធាវីការពារគាត់បានលើកឡើងថា កាលណាយកតែឯកសារអ៊ីចឹងយកមក វាជាការលម្អៀង ។ បើសិនណាជាឲ្យព្រះរាជអាជ្ញាគាត់លើកយកឯកសារទាំងអស់ទាក់ទងទៅនឹងការដាក់បន្ទុកផង ទៅទាក់ទងទៅនឹងការដោះបន្ទុកផង អ៊ីចឹងសួរថា តើកាតព្វកិច្ចរបស់គាត់ធ្វើអីទៀត?

ដូច្នេះ គាត់ៗបំពានកាតព្វកិច្ចអស់ហើយ ។ អ៊ីចឹងគាត់មានកាតព្វកិច្ចក្នុងការដាក់បន្ទុកប៉ុណ្ណោះ រីឯមេធាវីការពារទេ ដែលត្រូវតែរកភស្តុតាងមកដោះបន្ទុក ។ ហ្នឹងចំណុចមួយ ។

ចំណុចទីពីរ ទាក់ទងទៅនឹងគេហៅថា ដែលយកឯកសារស្រាវជ្រាវរើសរកពីសំណុំរឿងនោះវាខាតពេលវេលា ខ្ញុំបាទជឿជាក់ថា នេះគឺជាការខិតខំប្រឹងប្រែងរបស់ភាគីនីមួយៗ ទាំងព្រះរាជអាជ្ញា ក៏ដូចជាមេធាវីការពារដែរ ។ អ៊ីចឹង គាត់ត្រូវតែខំប្រឹងប្រែងមិនយកលេសថា ជាពេលវេលា ដែលទៅខ្វះខាតពេលវេលាគ្រាន់តែយកឯកសារនោះមកប៉ុណ្ណឹង មកបង្ហាញភស្តុតាងអ៊ីចឹងទេ ។

អ៊ីចឹងគាត់គួរតែធ្វើឲ្យដូចព្រះរាជអាជ្ញាដែរ ។ តែបើសិនណាជាការខកខានមិនបានធ្វើ មិនបានយកពេលហ្នឹងទៅធ្វើ នេះជារឿងរបស់គាត់ ។ ខ្ញុំសូមអរគុណប៉ុណ្ណឹង ។ សូមអស់ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី បើចង់មានយោបល់សូមអញ្ជើញ។

**លោក គីម ម៉េងឃី៖**

សូមគោរពលោកប្រធាន និងអង្គជំនុំជម្រះទាំងមូល! ក្រុមមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី មិនមានការសង្កេតអ្វីទៅលើបញ្ហានេះទេ ។ ហើយសូមទុកបញ្ហានេះឲ្យអង្គជំនុំជម្រះជាអ្នកសម្រេច ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីក្រុមបួន បើមានសូមអញ្ជើញ។

**លោក ហុង គីមសួន៖**

សូមអរគុណ។ សូមគោរពលោកប្រធានអង្គជំនុំជម្រះ និងលោកស្រី លោកចៅក្រមជំនុំជម្រះ និងអង្គសវនាការជាទីគោរព!

ចំពោះខ្ញុំបាទជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមបួន សូមធ្វើការកត់សម្គាល់ ។ ទីមួយ គឺសូមគាំទ្រទាំងស្រុង ចំពោះមតិលើកឡើងរបស់សហព្រះរាជអាជ្ញា ។ ទីពីរ គឺខ្ញុំបាទយល់ឃើញថា ការដាក់ឯកសារនៅក្នុង កាលពីថ្ងៃទី២៣ នេះ ខ្ញុំបាទយល់ថា មិនមានអ្វីដែលជាចោទជាបញ្ហានាំឱ្យអាក់ខាន ឬរាំងស្ទះដល់ដំណើរការនីតិវិធីសវនាការនេះទេ ។ ដោយហេតុថា ឯកសារទាំងអស់នេះ មានតាំងពីនៅក្នុងរយៈពេលនៃការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតម្ល៉េះ បូករួមទាំងឯកសារមាននៅក្នុងសំណុំរឿងផង គឺជាការពន្លឿននីតិវិធី មិនពិបាកអូសបន្លាយដែលនាំឱ្យសាធារណៈមតិចោទប្រកាន់ថា តុលាការនេះ បន្តនីតិវិធីតែធ្វើឱ្យរាំងស្ទះ ឬធ្វើឱ្យយឺតពេល ។

អ៊ីចឹងខ្ញុំបាទយល់ថា ឯកសារនេះ នៅក្របទីមួយ ទីពីរ ទីបី ដែលមានជាភាសាខ្មែរ និងភាសាអង់គ្លេស ភាសាបារាំង នោះបានពន្យល់រួចហើយ គឺជាការលើកឡើងសម្រាប់ជួយបង្ហាញទាំងភាគី ទាំងលោកប្រធាន និងលោក លោកស្រីចៅក្រមសម្រាប់ពិចារណា ដើម្បីឱ្យទាំងជនជាប់ចោទ ទាំងភាគីបានយល់កាន់តែច្បាស់ កុំឱ្យមានខាតពេលវេលាសម្រាប់ថយទៅពិចារណាក្រោយឡើងវិញទៀត ។

ដូច្នេះហើយ ឯកសារទាំងអស់នេះ ខ្ញុំបាទយល់ឃើញថា លោកមេធាវីការពារលោកបានចូលរួមទាំងនៅពេលធ្វើការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត រួមទាំងភាគីទៅដល់មន្ទីរស-២១ ទៀតផង ។ អ៊ីចឹងឯកសារទាំងអស់នេះ នៅក្នុងប្រព័ន្ធស៊ីវិលឡ ភាគីមានសិទ្ធិដាក់។ ដូច្នេះ ភាគីព្រះរាជអាជ្ញា ភាគីមេធាវីការពារ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលមានមេធាវីតំណាង មានសិទ្ធិដាក់ដូចគ្នា សម្រេចទៅលើអង្គជំនុំជម្រះទទួលយកបាន ឬមិនបានតែប៉ុណ្ណោះ ។ អាស្រ័យហេតុនេះខ្ញុំបាទជាមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន សូមឱ្យលោកប្រធានទទួលយកសម្រាប់ពិចារណានាពេលសវនាការបន្តទៅទៀត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

បាទលោកប្រធាន!

មេធាវីការពារក្តីបានធ្វើការពិនិត្យប្រតិចារឹកនៃសវនាការ នៃៗ-- នៅក្នុងសវនាការថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ គឺសវនាការអង្គបុរេ គឺនៅក្នុងទំព័រទី៥៦ និង៦៦ នៃប្រតិចារឹកជាភាសាបារាំង គឺខ្ញុំបានពិនិត្យមើលទៅលើប្រតិចារឹកនោះ នៅក្នុងជួរ១៦ នៃឯកសារបារាំងបាននិយាយថា អង្គជំនុំជម្រះបានបញ្ជាក់ដោយពិនិត្យទៅលើអង្គហេតុដែលត្រូវធ្វើការដំណើរការក្តី គឺអង្គជំនុំជម្រះ គឺមានលទ្ធភាពក្នុងការបង្ហាញភស្តុតាង ។ នេះគឺជាការដកស្រង់ចេញពីប្រតិចារឹកនោះ ។ នេះគឺជាអ្វីដែលខ្ញុំយល់ថាកិច្ចដំណើរការនីវិតិធីគួរតែដំណើរការទៅតាមណា?

ដូច្នេះតាមខ្ញុំ ដូចដែលខ្ញុំលើកឡើងមុននៅក្នុងនេះវាហាក់ដូចជាមុនកិច្ចនីតិវធី ឬក៏វាលឿនពេកសម្រាប់សហព្រះរាជអាជ្ញាក្នុងការលើកឯកសារនេះ ។ មុនពេលដែលអង្គជំនុំជម្រះធ្វើការសួរដេញដោលទៅលើជនជាប់ចោទ ហើយវាមិនមានភាពយុត្តិធម៍ក្នុងការលើកឡើងអំពីឯកសារនេះ ដោយបង្ហាញថាវាជាឯកសារនៅក្នុងសំណុំរឿង ។ ហើយសហព្រះរាជអាជ្ញាបានលើកឡើងហើយ គឺជាការដកស្រង់ឯកសារមួយចំនួននៅក្នុងសំណុំរឿង ។ ចំណុចនេះវាខុសគ្នាទៅលើករណីនេះ ។

នៅថ្ងៃនេះ សហព្រះរាជអាជ្ញាបានធ្វើការចែកជូនភាគីផ្សេងៗ ហើយនិងអ្នកចូលរួមនូវបញ្ជីមួយ ឬក៏ក្រដាសមួយសន្លឹក ដែលសហព្រះរាជអាជ្ញាបានបញ្ជាក់ថា គាត់នឹងយកឯកសារនោះមកផ្អែកនៅក្នុងសវនាការថ្ងៃនេះ ។ ហើយខ្ញុំគិតថា វាជាប្រយោជន៍សម្រាប់ភាគីទាំងអស់ ។ សហព្រះរាជអាជ្ញាបានបញ្ជាក់ជាមុនថា តើគាត់មានបំណងនឹងដាក់ឯកសារអ្វីនៅមុខអង្គជំនុំជម្រះ? គឺវាមានឯកសារចំនួនបួន គឺចំណុចវាល្អ ហើយខាងមេធាវីការពារក្តីក៏មិនមានភាពជំទាស់ដែរ ។

ប៉ុន្តែនៅថ្ងៃមុន សហព្រះរាជអាជ្ញាគាត់មានបំណងលើកឯកសារដែលមិនមែនជាអ្វីនៅក្នុងសំណុំរឿង ប៉ុន្តែគាត់ចង់ធ្វើការជ្រើសរើសឯកសារមួយចំនួននៅក្នុងសំណុំរឿង ។ ចំណុចនេះហើយ ដែលជាការភ្ញាក់ផ្អើលរបស់ខាងមេធាវីការពារក្តី ។

សូមអរគុណលោកប្រធាន និងលោកស្រីចៅក្រម ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣២:៤០]

**ប្រធានអង្គជំនុំ៖**

ក្រោយពីបានស្តាប់មតិកត់សម្គាល់របស់មេធាវីការពារក្តី លើបញ្ជីនៃឯកសាររូបភាព ដែលដាក់ដោយសហព្រះរាជអាជ្ញា កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ កន្លងមកនេះ ហើយបានកត់សម្គាល់

និងបានស្តាប់លើមតិលើកឡើងរបស់សហព្រះរាជអាជ្ញា របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ អង្គជំនុំជម្រះនៅតែរក្សាជំហរក្នុងការបដិសេធនូវការជំទាស់របស់មេធាវីការពារក្តី ក្នុងការដាក់ឯកសារនេះ ហើយកិច្ចការលម្អិត អង្គជំនុំជម្រះនឹងពិចារណាសម្រេចនៅក្នុងអំឡុងពេលនៃការឈប់សម្រាក ។

ដោយឡែកឯកសារផ្សេងទៀត ដែលលើកឡើងដោយសហព្រះរាជអាជ្ញា ហើយគ្មានការជំទាស់នោះ គឺឯកសារនោះអាចលើកមកពិភាក្សាដេញដោលបាន ។

ជាកិច្ចបន្តគឺយើងនឹងចាប់ផ្តើមធ្វើការពិភាក្សាដេញដោលលើអង្គហេតុ ដែលបានគ្រោងទុកតាមកម្មវិធីដែលបានគ្រោងទុក ។ ហើយមុនចាប់ផ្តើម សូមអនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទមកឈើរាំងរង្វង់ក្រចកសេះនៅទីនេះ ។

មានអ្វីទៅៗ សុំមុនណ៎ា មិនអាចគ្រាន់តែចុចដើបនិយាយៗទេ សុំការអនុញ្ញាតជាមុន ។

**លោក អាឡាំង វែនណឺ៖**

ខ្ញុំនឹងធ្វើតាមលោក លោកស្រីចៅក្រម ។ មានចំណុចមួយដែលក្រុមមេធាវីរដ្ឋប្បវេណីចង់លើកឡើង គឺមានចំណុចមួយដែលយើងខ្ញុំចង់លើកឡើង ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

[០៩:៣៥:២២]

**លោក អាឡាំង វែនណឺ៖**

សូមអរគុណ លោកប្រធាន។ នៅថ្ងៃពុធ ខែមេសា គឺអាទិត្យមុន គឺជនជាប់ចោទបានលើកឡើងអំពីការបង្កើតស-២១ ហើយជនជាប់ចោទធ្វើការពិនិត្យដោយខ្លួន-- លើកឡើងដោយខ្លួនឯង ហើយលោកចៅក្រម យ៉ា សុខន បានដេញដោលទៅលើបញ្ហានេះ ។ នៅថ្ងៃទី២៣ ខែមេសា លោក រូ បានសុំឲ្យជនជាប់ចោទធ្វើការបំភ្លឺចម្លើយមួយរបស់ជនជាប់ចោទ ហើយលោក រូ បានលើកឡើងដូចតទៅ៖

គឺខ្ញុំសូមលើកឡើងប្រតិចារឹកនៅថ្ងៃព្រហស្បតិ៍ ហើយខ្ញុំលើកឡើងសាជាថ្មីថា វាជាការបញ្ហាការបកប្រែម្តងទៀត ហើយបន្ទាប់ពីលើកឡើងអំពីជនជាប់ចោទនៅក្នុងអង្គហេតុ ហើយខ្ញុំចង់ឲ្យជនជាប់ចោទបញ្ជាក់អំពីខ្សែទំនាក់ទំនង ខ្សែបណ្តោយ និងខ្សែទទឹងឲ្យបានច្បាស់ ។ ហើយលោក លោកស្រីចៅក្រម ជនជាប់ចោទនៅក្នុងសវនាការនេះ គឺនឹងធ្វើការផ្តល់សក្ខីកម្មដោយផ្ទាល់ ហើយនឹងផ្តល់ចម្លើយច្រើនដង ។ ហើយលោក លោកស្រីចៅក្រមបានបញ្ជាក់នៅក្នុងដីកាបង្គាប់របស់លោកចៅក្រម

នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ នៅក្នុងចំណុចទី៩ គឺលោកចៅក្រមបានលើកឡើងថា ដំណើរការគឺចាប់ផ្ដើមពីចៅក្រម សហព្រះរាជអាជ្ញា មេធាវីភាគី និងមេធាវីការពារក្ដី ហើយយើងអនុញ្ញាតឲ្យសួរសំណួរមួយចំនួនដែលវាមានភាពចាំបាច់ ហើយនិងភាគីមានបំណង ។

[០៩:៣៧:១០]

ដូច្នេះហើយនៅទីនេះ យើងខ្ញុំជឿថា ការដេញដោលរបស់ភាគី និងភាគីត្រូវតែបញ្ជាក់ និងលើកឡើងនៅក្នុងពេលសវនាការ គឺមិនមែនក្រៅសវនាការនោះទេ ។ ហើយយើងមិនជឿថា នៅពេលជនជាប់ចោទបានលើកឡើងពីរង្វង់ក្រចកសេះ ។ ហើយឆ្លើយតបទៅនឹងសំណួរមួយចំនួន ភាគីបន្ទាប់ពីសវនាការ គឺត្រូវពិនិត្យទៅលើស្ថានភាពផ្សេងៗរបស់ជនជាប់ចោទ ដែលបានលើកឡើងនៅក្នុងសំណុំរឿង ។ ហើយដើម្បីឲ្យមានភាពច្បាស់លាស់ យើងមិនមែនស្នើសុំថា នៅពេលជនជាប់ចោទលើកលែងនោះ មិនមែនមិនមែនឲ្យគាត់និយាយ ហើយមិនឲ្យគាត់និយាយជាមួយភាគីនៅពេល នៅក្រៅសវនាការនោះទេ ។

ហើយគឺខ្ញុំសូមនិយាយឲ្យបានច្បាស់លាស់ យើងមិនស្នើសុំ យើងមិនមែនស្នើសុំថា នៅពេលដែលជនចាប់ចោទឆ្លើយនៅពេលសវនាការ គឺមិនអាចទាក់ទងមេធាវីរបស់គាត់នោះទេ គឺមិនមែនស្នើសុំដូច្នេះទេ គឺមេធាវីការពារក្ដី គាត់ដឹងច្បាស់ណាស់ ចំពោះចំណុចជាក់លាក់ទាក់ទងទៅនឹងការចេញសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍នៅ *អាយស៊ីធីវ៉ាយ* នៅក្នុងរឿងក្ដី *ប៉ែលវិក* នៅក្នុងឆ្នាំ២០០៨ គឺបានលើកឡើងថា ជនជាប់ចោទត្រូវតែមានលទ្ធភាពពិភាក្សាជាមួយមេធាវីរបស់គាត់ នៅក្នុងពេលសវនាការ នៅពេលដែលគាត់ និងជនជាប់ចោទផ្ដល់ចម្លើយនៅក្នុងសវនាការ ។ យើងមិនជំទាស់ទៅលើករណីនេះទេ ប៉ុន្តែនៅក្នុងសវនាការមួយនេះ ដោយសារតែភាគី គឺអាចសួរសំណួរផ្សេងៗ អនុលោមតាមវិធានទី៩១ នៅក្នុងអំឡុងពេលសវនាការ ។ ដូច្នេះហើយ គឺខ្ញុំនៅពេលនេះ ធ្វើការស្នើសុំថា ក្នុងពេលសវនាការនៅពេលជនជាប់ចោទធ្វើការផ្ដល់សក្ខីកម្ម និងឆ្លើយសំណួរផ្សេងៗនោះ គឺយើងមិនស្នើសុំ មិនឲ្យភាគីណាមួយ រួមទាំងមេធាវីការពារ ក្ដីទាក់ទងនៅពេលនេះ ហើយឲ្យគាត់អាចទាក់ទងនៅក្រៅសវនាការជាមួយកូនក្ដីរបស់គាត់ និងភាគីហ្នឹង ។ គឺវិធាន៩១ គឺបានបញ្ជាក់ច្បាស់លាស់ហើយថា សំណួរ និងចម្លើយទាំងឡាយ ត្រូវតែធ្វើឡើងនៅក្នុងពេលសវនាការ ប៉ុន្តែ អ្វីដែលខ្ញុំបានលើកឡើង គឺជាបំណងរបស់ខាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

[០៩:៤០:០៦]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ដើម្បីបំភ្លឺនូវបញ្ហាទាំងអម្បាលមាណនោះ ដែលអាចនឹងបញ្ជាក់ពីចំណុចសំខាន់របស់ច្បាប់ខំមិនឡូ យើងនៅទីនេះ នៅក្នុងនីតិវិធីរបស់ច្បាប់ស៊ីវិលឡូ ហើយសហសេវិករបស់ខ្ញុំ គឺថាមេធាវីហ្នឹងបាននិយាយថា ជនជាប់ចោទបានផ្តល់សក្ខីកម្មនៅក្នុងនីតិវិធីរបស់ប្រព័ន្ធច្បាប់ស៊ីវិលឡូ ។ ដូច្នេះលោក លោកស្រីចៅក្រម បានឃើញហើយថា មេធាវីនោះបានលើកឡើង គាត់មិនមែនផ្តល់សក្ខីកម្មទេ គាត់បានផ្តល់ជាចម្លើយ ។ អ៊ីចឹងបញ្ហាដែលលោកបានលើកឡើងនោះ ដែលលោក លើកឡើងនោះ គឺតាមពិតនោះ គឺជាវិធាន ដែលយើងបានដឹងច្បាស់រួចទៅហើយ ហើយយើងបានពិនិត្យមើលឃើញហើយនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលថា នៅទីនោះគឺគេប្រើប្រព័ន្ធច្បាប់ខំមិនឡូ ហើយខ្ញុំបានពិនិត្យឃើញវិធានមួយនេះដែរ ដែលអនុលោមបន្ទាប់ពីដំណាក់កាលដែលជនជាប់ចោទបានផ្តល់សក្ខីកម្មរួចហើយ ។ មេធាវីការពារមិនអាចលើកឡើងពីបញ្ហានោះឡើងវិញនោះទេ ។ តាមពិតនោះ គឺថាត្រូវតែធ្វើឡើងនៅក្នុងសវនាការ ។

នៅក្នុងប្រព័ន្ធច្បាប់ខំមិនឡូអាចធ្វើបានបែបនេះ គឺហាមអ៊ីចឹង ។ ប៉ុន្តែ យើងមានប្រព័ន្ធស៊ីវិលឡូជាការជំនុំជម្រះស៊ីវិលឡូ ។ អ៊ីចឹងហើយលោកមេធាវី ដែលលើកឡើងនោះ គឺថាមិនមានអ្វីដែលថាអាចរារាំងមិនឲ្យខ្ញុំនិយាយជាមួយកូនក្តីខ្ញុំនៅក្នុងដំណាក់កាលក្នុងពេលធ្វើសវនាការ ហើយនិងផ្តល់អនុសាសន៍មួយចំនួនដែលខ្ញុំយល់ថា វាសមស្របបាន ។ នេះគឺជាតួនាទីតាមវិជ្ជាជីវៈ ហើយខ្ញុំបានធ្វើសម្បថ ហើយនឹងទទួលការបណ្តុះបណ្តាលធ្វើនោះ ។

បើសិនជាខ្ញុំមិនគោរពដូច្នេះទេ គឺថាខ្ញុំក្បត់នឹងសម្បថរបស់ខ្ញុំ ។ បើសិនជាខ្ញុំមិននិយាយជាមួយកូនក្តីរបស់ខ្ញុំពេលសម្រាក បើមិនធ្វើដូច្នេះទេ គឺថាខ្ញុំនឹងមិនគោរពតាមវិជ្ជាជីវៈនោះទេ ។ នេះហើយ គឺថាគាត់ជាជនជាប់ចោទ ដែលថាស៊ីវិលឡូ មាននីតិវិធីមួយ ឬក៏អនុញ្ញាតឲ្យមេធាវីនិយាយគ្រប់ពេលវេលាទាំងអស់ក្នុងសវនាការ និងក្រោយសវនាការ ។ នេះហើយជាកត្តាចាំបាច់ ដែលយើងត្រូវធ្វើ ។

សូមអរគុណ លោកប្រធាន ។

[០៩:៤២:៥៩]

**លោក អាឡាំង វ៉ែនណឺ៖**

លោកប្រធាន ហើយខ្ញុំសូមនិយាយដោយសង្ខេបពីបញ្ហានេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ ហើយជាចុងក្រោយហើយ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមលោកប្រធានមេត្តាបញ្ជាក់ឡើងវិញពីអ្នកបកប្រែ ដោយសារអ្នកបកប្រែស្តាប់អត់ទាន់ ។

**ប្រធានអង្គជំនុំ៖**

បាទ ជាការកត់សម្គាល់នេះ គឺករណីៗនេះ គឺជារឿងចុងក្រោយចំពោះបញ្ហានេះ ។

**លោក អាឡាំង វ៉ែនណឺ៖**

លោកប្រធាន យើងបានពិភាក្សាចំណុចនេះរួចហើយ ថាតើយើងប្រើប្រព័ន្ធស៊ីវិលឡូ ឬក៏ខំមិនឡូ? ប្រព័ន្ធខំមិនឡូ គឺជាប្រព័ន្ធច្បាប់បារាំង ដែលយើងត្រូវប្រើ ហើយខ្ញុំមិនចាំបាច់ត្រឡប់មកចំណុចនេះទេ ។ តាមពិតយើងគោរពទៅតាមវិធានផ្ទៃក្នុង គឺថាជាចំណុចតែមួយគត់ ដែលអាចនឹងតម្រង់ទិសដៅនៃសវនាការពេលនេះ ។ ហើយវិធានផ្ទៃក្នុង៩០ កថាខណ្ឌទី២ បានចែងដាក់លាក់ថា “អំពីការសួរចម្លើយទៅជនជាប់ចោទ” ហើយជាវិធាននេះដែលតម្រូវឲ្យធ្វើចំណុច៩០.១ អនុញ្ញាតឲ្យ ៩២.២នោះ គឺថា ៩០.២នោះ គឺថាអនុញ្ញាតឲ្យភាគីទាំងអស់ដែលថាចៅក្រម ហើយសហព្រះរាជអាជ្ញា ហើយគឺថាមេធាវីការពារ ហើយអ៊ីចឹងហើយភាគីអាចស្នើទៅជនជាប់ចោទ ហើយសុំអាចឲ្យគាត់បំភ្លឺបាន ។ អ៊ីចឹងនៅក្នុងសំណួរសុំឲ្យបំភ្លឺនេះ គឺត្រូវតែកើតឡើងនៅក្នុងពេលសវនាការផ្ទាល់ ។ អ្វីដែលជាមូលហេតុនោះ គឺថាយើងមានៗមូលហេតុគឺថាឲ្យសួរសំណួរនៅក្នុងសវនាការនោះ គឺថាពេលរៀងរាល់ល្ងាចគាត់បានជួបកូនក្តីរបស់គាត់ មេធាវីនោះបានសួរសំណួរនូវក្រៅសវនាការ តើគោលបំណងហ្នឹងធ្វើដើម្បីអ្វី?

អ៊ីចឹងវិធាន៩០.២ នោះចែងច្បាស់ក្នុងពេលដែលជនជាប់ចោទ នៅពេលដែលមេធាវីបាននឹងបំភ្លឺឲ្យផ្តល់ការបំភ្លឺក៏ត្រូវតែធ្វើបំភ្លឺដល់កូនក្តីរបស់គាត់នៅក្នុងពេលសវនាការ ដើម្បីធានានូវបូរណភាពនៃការជំនុំជម្រះនោះ គឺថាយើងមិននិយាយអំពីច្បាប់បារាំង ឬច្បាប់បារាំង ឬក៏ប្រព័ន្ធច្បាប់បារាំង គឺយើងនិយាយអំពីវិធាន៩០ កថាខណ្ឌទី២ ដែលតម្រូវឲ្យភាគីទាំងអស់សួរសំណួរ ហើយនឹងសុំឲ្យមានការបំភ្លឺនៅក្នុងពេលសវនាការ ។ នេះហើយជាចំណុចដែលខ្ញុំចង់លើកឡើងនោះ លោកចៅក្រមលោក

ប្រធាន ។

[០៩:៤៦:៣៥]

**ប្រធានអង្គជំនុំ៖**

បញ្ហាអង្គជំនុំជម្រះកត់សម្គាល់ ហើយនឹងឆ្លើយតបនូវក្នុងអំឡុងពេលអង្គជំនុំជម្រះនឹងពិភាក្សានៅក្នុងពេលវេលាសវនាការសម្រាកនៅនូវខាងមុខនេះ ហើយនឹងឆ្លើយបញ្ជាក់ជូនអំពីបញ្ហានេះ ។

ជាកិច្ចបន្ត គឺដំណើរការសវនាការសួរពិភាក្សាដេញដោលលើអង្គហេតុនៃការបង្កើតមន្ទីរសន្តិ-បាល ស-២១ ហើយនិងគុកនៅពេទ្យឆ្កួតតាខ្មៅ ហើយដោយសារសំណួរពាក់ព័ន្ធកាលពីថ្ងៃព្រហស្បតិ៍នោះ គឺមានការជាប់នៅឡើយ មិនទាន់អស់ដោយចៅក្រម យ៉ា សាខន ។

ដូច្នេះ អង្គជំនុំជម្រះសូមប្រគល់នាទីនេះ ទៅលោកចៅក្រម យ៉ា សាខន ដើម្បីបន្តកិច្ចសួរដល់ជនជប់ចោទអំពីអង្គហេតុដូចបានជម្រាបខាងលើតទៀត ។ សូមអញ្ជើញ ។

**ចៅក្រម យ៉ា សុខន៖**

**ស៖** សូមអរគុណលោកប្រធាន ។ ជនជាប់ចោទកាលពីអាទិត្យមុនលោកបានបញ្ជាក់ថា អង្គ-ភាពសួរចម្លើយមាន៤ក្រុម មានក្រុមក្តៅ, ក្រុមស្លូត, ក្រុមអង្កៀម ។ តើក្រុមទី៤ គឺជាក្រុមអ្នកសួរចម្លើយប្រភេទស្រីឬយ៉ាងដូចម្តេច?

**ជនជាប់ចោទ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រមៗ ក្រុមទី៤ ដែលខ្ញុំចង់និយាយនេះ គឺក្រុមកម្មាភិបាលស្រីសួរចម្លើយអ្នកទោសស្រី ។

**ស៖** សួរចម្លើយនេះ លោកមានភារកិច្ចសួរចម្លើយអ្នកទោសដែរ ឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ខ្ញុំគ្មានភារកិច្ចសួរចម្លើយអ្នកទោសទេ ។ ដោយឡែកមានតែមួយករណីគត់ គឺជាមួយ កុយ ធួន ដែលមេតម្រូវឲ្យខ្ញុំសួរដោយផ្ទាល់មាត់ ដោយផ្ទាល់ដៃ ដោយផ្ទាល់ខ្លួន ក្រៅពីនោះ ខ្ញុំអត់បានសួរអ្នកណាដោយផ្ទាល់មាត់ទេ ។

**ស៖** លោកបានបញ្ជាក់ថា នៅអាគារ "A" គឺជាទីកន្លែងសម្រាប់សួរចម្លើយ តើនៅអាគារនេះមានបានសរសេរវិន័យសន្តិបាលអ្វីទេ សម្រាប់ឲ្យអ្នកទោសមើលមុនពេលសួរចម្លើយ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម វិន័យសន្តិបាលនេះមិនមែនជារបស់ស-២១ ទេ ខ្ញុំឃើញហើយកាលថ្ងៃទៅតទល់គ្នា ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ដើម្បីសុំឱ្យបំភ្លឺដែលទាក់ទងទៅនឹងសំណួររបស់លោកចៅក្រមខាងដើម ទាក់ទងអំពីនយោបាយ អំពីការណែនាំបទបញ្ជាដែលត្រូវអនុវត្ត ថាតើនយោបាយពេលនោះ គឺថាមានន័យដូចម្តេចដែរ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកចៅក្រម ឡាវែន៍ ពេលនេះ ការបកប្រែខុសម្តងទៀតហើយ វិន័យសន្តិបាល បើយើងនិយាយជាភាសាបារាំងថា *ឌីស៊ីភ្លីន ដឺសឺគួរីតេ* ដែលជាការប្រឌិតរបស់យួន ពេលគេចូលមកនោះមាន "ដប់ខ" ដែលខ្ញុំបានបដិសេធហើយសម័យដែលតទល់គ្នា ។ ដូច្នេះមិនមែន *ប៉ូលីទីក* ទេ គឺ*ឌីស៊ីភ្លីន* ។

**សួរដោយចៅក្រម យ៉ា សុខន៖**

**ស៖** តើអង្គភាពយោធាអ្នកណាទទួលខុសត្រូវ? មានភារកិច្ចធ្វើអ្វី? ហើយទទួលបញ្ជាពីអ្នកណា?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ខ្ញុំបានបញ្ជាក់ថា រួមមកហើយថា កាលនូវសម័យស៊ើបអង្កេតថា កិច្ចការខាងយោធា អនុប្រធានរបស់ខ្ញុំ គឺមិត្តហ៊ ជាអ្នកទទួលខុសត្រូវ ។ ឥឡូវ ខ្ញុំសូមបញ្ជាក់ទៀតថា ស្អីទៅជាកិច្ចការខាងយោធា? កិច្ចការខាងយោធាទី១ គឺការចាប់ ទី២ គឺមានការឃុំឃាំង ទី៣ គឺមាននាំយកទៅជើងឯក យកទៅកម្ទេច ហើយទី៤ អន្តរាគមន៍ពេលណាមានការបះបោរនៅខាងក្នុង និងការវាយលុកពីខាងក្រៅ ។ ដូច្នេះ កិច្ចការនេះវាជារបស់គេតាំងពីដើមមកខ្ញុំរក្សាទុក ក៏ប៉ុន្តែដោយឡែកដែលខ្ញុំរវល់ជាប់ទៅនឹងកំណត់ហេតុ ជាប់រវល់តែនឹងអានឯកសារសួរចម្លើយតាំងពីពេលដែលខ្ញុំបានឡើងធ្វើប្រធានមកនេះ កិច្ចការខាងចែកក្រុមសួរចម្លើយ កិច្ចប្រចាំថ្ងៃខាងចាត់ចែងការងារសួរចម្លើយក៏នៅលើគេទៀតដែរ ។ គេមិត្តហ៊ គ្មានសិទ្ធិមើលតែឯកសារចម្លើយដែលប៉ះមនុស្សសំខាន់ នេះជាបញ្ជាពីលើកមកផ្តាច់សិទ្ធិរបស់គាត់ត្រង់ហ្នឹងមួយ ។ ដូច្នេះ កិច្ចការប្រចាំថ្ងៃ ដូចខ្ញុំបានជម្រាបលោកចៅក្រមហើយ គឺនៅលើគាត់ ។

[០៩:៥៤:៤៤]

សរុបមកខ្ញុំសូមបញ្ជាក់ថា ភារកិច្ចជាបទឧក្រិដ្ឋទាំងប៉ុន្មាន ដែលមិត្តហ៊ គាត់ទទួលភារៈប្រចាំ

ថ្ងៃនេះ វាជាបទឧក្រិដ្ឋទៅលើមនុស្សដែលស្លាប់រួចទៅហើយទេ ។ មនុស្សដែលស្លាប់រួចទៅហើយយ៉ាងម៉េច? សម័យខ្មែរក្រហមឲ្យតែអាក្រុម៤នាក់នោះ វាសម្រេចកម្ទេចអ្នកណាហើយ អ្នកខាងក្រោមត្រូវតែចាប់ ចាប់ហើយយកមកដាក់គុក ដាក់គុកហើយសួរចម្លើយដោយមានទារុណកម្ម រួចហើយយកទៅកម្ទេចឲ្យស្ងាត់កុំឲ្យក្រុមគ្រួសារដឹង ។

ដូច្នេះ មិត្តតហ៊ា ធ្វើអាកន្លែងនុ៎ង ឧក្រិដ្ឋកម្មរបស់គ្នាដែលខាងលើប្រគល់ឲ្យ ហើយដែលខ្ញុំត្រួតពិនិត្យពីលើហ្នឹង គឺនៅលើកិច្ចការហ្នឹង ។ ឯចំណែកខ្ញុំដូចបានជម្រាបលោកចៅក្រមរួចហើយ វាទាក់ទងនឹងឧក្រិដ្ឋកម្មស្អី ដែលមានន័យជាជម្រៅ ដូចជាបង្រៀនគេឲ្យចេះសួរ ឲ្យដាច់ចិត្តសួរ ឲ្យដាច់ខាតសួរ ឲ្យដាច់ខាតធ្វើទារុណកម្មស្អីៗហ្នឹង គឺខ្ញុំ ។ សរុបមកវិញ ឧក្រិដ្ឋកម្មនេះ ខ្ញុំអត់គេចទេ ក៏ប៉ុន្តែខ្ញុំកិច្ចដែល--មើលទៅវាដូចជាខ្លាំងណាស់ ឧក្រិដ្ឋកម្មខ្លាំងណាស់ ក៏ប៉ុន្តែ តាមពិតគ្នាប្រព្រឹត្តឧក្រិដ្ឋកម្មទៅលើអ្នកដែលស្លាប់រួចទៅហើយទេ អ្នកដែលគេសម្រេចរួចទៅហើយទេ ។

ឯចំណែកឧក្រិដ្ឋកម្ម ដែលខ្ញុំធ្វើវាទាក់ទងនឹងមនុស្សដែលមានសេរីភាព ប៉ះពាល់ដល់ឈ្មោះគ្នាដែលនៅមានសេរីភាព ដែលបក្សនៅជឿទុកចិត្តនៅឡើយ ហើយខ្ញុំបង្កើតឯកសារទៅប៉ះឈ្មោះគេ នេះដែលជារឿងធ្ងន់ធ្ងរ ។ សរុបមកវិញ ខ្ញុំនិយាយនេះវែងបន្តិចហើយ ខ្ញុំសូមអត់ទោស ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

**លោក តាន់ សេណារ៉ុង៖**

សូមគោរពប្រធានអង្គជំនុំជម្រះ ខ្ញុំសូមមានយោបល់បន្តិចបានទេបាទ? ដើម្បីឲ្យជនជាប់ចោទហ្នឹងបញ្ជាក់ពីឯកសារមួយពាក់ព័ន្ធនឹងវាសំណួររបស់លោកចៅក្រម ដែលបានសួរអំពីវិន័យសន្តិបាលនៅក្នុងមន្ទីរស-២១ នុ៎ង ពីព្រោះកាលលើកឡើងរបស់-- ខ្ញុំបាទសូមការអនុញ្ញាតជាមុនសិនបាទ! សុំទោសតើលោកប្រធានអនុញ្ញាតឲ្យខ្ញុំ សូមលើកបន្តិចបានទេ?

**ប្រធានអង្គជំនុំ៖**

មិនអនុញ្ញាតទេៗ ។

ចៅក្រម យ៉ា សុខន ។

**ចៅក្រម យ៉ា សុខន៖**

**ស៖** លោកបានបញ្ជាក់អម្បាញ់មិញគឺថា ហ៊ ទទួលខុសត្រូវលើអង្គភាពយោធា តែនៅក្នុងអង្គការលេខរបស់លោក លោកបានបញ្ជាក់ថា ឈ្មោះ ផល ជាអ្នកទទួលខុសត្រូវខាងអង្គភាពយោធា

តើផលនោះ មានទំនាក់ទំនងយ៉ាងដូចម្តេចជាមួយ ហ៊?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម នៅមន្ទីរសន្តិបាលនេះ ការងារមានពីរ ។ ខ្ញុំសូមបញ្ជាក់ឡើងវិញទីមួយ ខាងការងារបែបសន្តិបាល។ ទីពីរ ខាងការងារយោធា ។ ការងាខាងសន្តិបាល ខ្ញុំទទួលខុសត្រូវ ខាងការងារយោធា មិត្តហ៊ ទទួលខុសត្រូវ ។ ឯចំណែក មិត្តផល ខ្ញុំអត់មាននាមត្រកូលទេ មិនដឹងជានាមត្រកូលគាត់ស្អីទេ ប៉ុន្តែជាកម្មាភិបាលល្អម្នាក់ (សូមទោស) ជាកម្មាភិបាលដាច់ខាតម្នាក់ ដាច់ខាត ពាក្យ “ដាច់ខាត” នេះ ។

ខ្ញុំសូមបញ្ជាក់ថាពាក្យ “ដាច់ខាត” នេះ ពាក្យជំនាន់នុំងគេប្រើសំដៅអ្នកណាដែលដាច់ខាតកម្មេចខ្លាំងអីៗហ្នឹង ។ បានន័យថា ដាច់ខាតទៅខាងបទឧក្រិដ្ឋ ក្នុងចំណោមកម្មាភិបាលកងពល៧០៣ ដែលប្រគល់មកឲ្យស-២១ ជាកេរដំណែលមកឲ្យស-២១ នេះ គឺ មិត្តផល នេះ ជាកម្មាភិបាលដែលដាច់ខាតទៅរកបទឧក្រិដ្ឋហ្នឹងជាងគេ ។

បើខ្ញុំនិយាយនេះ គឺដើម្បីចង់បញ្ជាក់ថា ផល របស់ស-២១ នេះ ខុសអំពីមិត្ត ផល ឈ្មោះដើមម៉ែន សុផល របស់ ម-១៣ ដែលខាងលើគេឲ្យខ្ញុំកម្មេចរួចទៅហើយនោះៗ ។ ដូច្នេះ កិច្ចការខាងយោធាទាំងប៉ុន្មានដែល មិត្តហ៊ គាត់មានបន្ទុក គាត់ផ្ទេរឲ្យមិត្តផល រត់ការងារជំនួសគាត់ បំពេញភារកិច្ចសំខាន់ៗជំនួសគាត់ គាត់ជាអនុប្រធានរបស់មិត្តហ៊ ។ ខាងការងារយោធាគឺ មិត្តផល គាត់ជាអនុប្រធានរបស់ មិត្តហ៊ ។

[១០:០១:៣២]

**ស៖** តើនៅក្នុងអង្គភាពយោធានេះចែកចេញជាប៉ុន្មានកងដែរ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកចៅក្រម! ការងារល្អិតខាងស្ថិតិ ខាងការក្តាប់កម្លាំង ខ្ញុំអត់បានដិតដល់ទេ គ្រាន់តែសូមញែកជារួមជាពីរ ។ ទីមួយ ពួកកងការពារធម្មតា ដែលទទួលភារកិច្ចការពារជនរងគ្រោះដែលទៅជាប់ទោសនៅស-២១ នៅក្នុងកន្លែងឃុំឃាំង ។ ទីពីរ អង្គភាពកងពិសេសដែលគ្រប់គ្រងដោយមិត្ត ហ៊ុយ-- ហ៊ឹម ហ៊ុយ នេះទទួលភារកិច្ចខាងកងពិសេស ។

ដូច្នេះខ្ញុំសូមញែកជាពីរដាច់ដោយឡែកពីគ្នាសិន ជម្រាបប្រសាសន៍ ។

**ស៖** ដើម្បីឲ្យបានច្បាស់ សូមមន្ត្រីតុលាការបង្ហាញឯកសារដែលមានលេខ E00154228 នៅលើអេក្រង់កុំព្យូទ័រ ដើម្បីជំនួយដល់ជនជាប់ចោទ ។

ពង្រីកឲ្យបានច្បាស់បន្តិច!

កងការពារនេះចែកចេញជាប៉ុន្មានក្រុមទៀត? ហើយក្នុងមួយក្រុមៗមានគ្នាប៉ុន្មាននាក់?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រុម! កម្លាំងក្តាប់ល្អិតដល់នុ៎ង ខ្ញុំក្តាប់មិនជាប់ទេ គ្រាន់តែដឹងថា មិត្តផល, មិត្តស្លួន, មិត្តម៉ាន, មិត្តប៉ូច ទាំងអស់នេះសុទ្ធតែជាកម្មាភិបាលអនុសេនាធំ មិនទាន់មានកម្មាភិបាលវរសេនាតូចទេ នៅស-២១ ដែលផ្ទេរពីកងពល ៧០៣ មកឲ្យខ្ញុំ នៅខាង ស-២១ នេះ ។

ទីមួយ មិត្តផល កម្មាភិបាលអនុសេនាធំ, ទីពីរ មិត្តស្លួន កម្មាភិបាលអនុសេនាធំ, ទីបី ខ្មោចមិត្តម៉ាន កម្មាភិបាលអនុសេនាធំ, ហើយទីបួន ខ្មោចមិត្តប៉ូច កម្មាភិបាលអនុសេនាធំ ។

ដូច្នេះឲ្យខ្ញុំក្តាប់ដល់ទៅក្រុមអីៗទៀត ខ្ញុំបាត់បង់ ខ្ញុំមិនបានយកចិត្តទុកដាក់គិតគូរទេពេលនុ៎ង ។ ដោយឡែកកងពិសេសនេះ កងពិសេស*ហ្វុសស៊្យេស្យាល់* នេះ កងពិសេសនេះ ។ ដំបូងគឺមិត្តប៉េង ទទួលខុសត្រូវ ។ មិត្តប៉េង ក៏ជាកម្មាភិបាល ក្រោយមកគាត់ក៏ជា-- មិត្តប៉េង ក្រោយមកគាត់ក៏ជាកម្មាភិបាលអនុសេនាធំដែរ ។ ហើយបានដល់ មិត្តប៉េង ដកយកទៅជំនួស មិត្តប៉ូច ដែលយើងខ្ញុំចាប់បាត់ទៅ ឡើងមិត្តហ៊ុយ គ្រប់គ្រងកម្មាភិបាលអនុសេនាតូចកងពិសេសនេះ ។

កងការពារដំបូងមាន មិត្តប៉ូច ដល់យើងខ្ញុំចាប់ នៅ ប៉ូច បាត់ទៅ បានយើងខ្ញុំដាក់ ប៉េង ឲ្យឡើងជាកម្មាភិបាលអនុសេនាធំទទួលភារៈការពារនៅខាងក្នុង ។ ដោយឡែក មិត្តហ៊ុយ លេខាអនុសេនាតូចកងពិសេសក៏ឡើងទៅជាអនុលេខា អនុសេនាធំកងការពារ ។ ហើយទន្ទឹមនេះមាន មិត្តវ៉ាន់ ឈ្មោះដើមញៀប ហ្វ មួយនៅក្នុងគណៈកម្មាធិការហ្នឹងដែរ ។

[១០:០៦:៣០]

នេះ ខាងឆ្វេងនេះយើងឃើញកម្មាភិបាលស្រី គឺកម្មាភិបាលជាភេទស្រី សម្រាប់សួរចម្លើយអ្នកទោសស្រី ។ លើគេបំផុតនេះឈ្មោះ ម៉ុត ។ ស្រីហ្នឹងឈ្មោះ ម៉ុត ប្រពន្ធ មិត្តហ៊ី ។ មិត្តហ៊ី អនុលេខាខ្ញុំនេះ ធ្វើជាប្រធានក្រុមសួរចម្លើយស្រី ។ បន្ទាប់មកមិត្ត យឿន ប្រពន្ធមិត្តហ៊ុយ ។ នុន ហ៊ុយ ហ៊ុយនៅស្រែងណោះ អនុប្រធានក្រុមសួរចម្លើយស្រី ។ បន្ទាប់មកបានមាន មិត្តនី ប្រពន្ធ មិត្តប៉ុន ជាកម្មាភិបាលស្រីម្នាក់សួរចម្លើយស្រីដែរ ។ បន្ទាប់មកបានមាន មិត្តរ៉ន ប្រពន្ធ មិត្តត្រូវ ។ មិត្តត្រូវនេះឈ្មោះដើម ប៉ាន់ សុខន កម្លាំងមកពីភ្នំពេញ ។ មិត្តរ៉ន ជាកម្មាភិបាលស្រី សួរចម្លើយស្រី ។ ខ្ញុំគូរអង្គការលេខនេះខ្វះម្នាក់ ដោយខ្ញុំភ្លេច ។ ខ្វះមិត្ត ពឿនៗ ប្រពន្ធ មិត្តម៉េង ដែលខ្ញុំឲ្យគេកម្ទេចរួចទៅហើយ ដោយសារជាប់ជំពាក់ជំពិនជាមួយនឹងប្តីដែលត្រូវមានរឿង ដែលត្រូវកម្ទេច ។

ដូច្នេះ កម្មាភិបាលសួរចម្លើយស្រីមានប្រាំនាក់ ម៉ុត, យឿន, នី, រ៉ន និង ពឿន ។ កម្ទេចអស់ពីរ

មិត្តឃឿន កម្មេចនៅពេលដែលចាប់ប្តី មិត្តហ៊ុយ ហើយនិងកម្មេចមិត្តពឿន នៅពេលដែលចាប់ប្តីមិត្តម៉េង ។ ដូច្នេះនៅសល់បី សូមបញ្ជាក់ប៉ុណ្ណោះអំពីកម្មាភិបាលស្រី ស្សរចម្លើយស្រី ។

**ស៖** តើកងការពារនោះមានភារកិច្ចធ្វើអ្វីដែរ?

**ឆ៖** កងការពារគឺ យាមអ្នកទោស ជនរងគ្រោះដែលគេជាប់ទោសនៅនោះទាំងយប់ទាំងថ្ងៃ ផ្តល់ម្ហូបអាហារ ហើយនិងថ្នាំសង្កូវបន្តិចបន្តួច ដើម្បីទុកឱ្យរស់សម្រាប់សួរចម្លើយចប់ ។ ហើយជូនជនរងគ្រោះទៅឱ្យពួកកម្មាភិបាលសួរចម្លើយផង ។ ដូច្នេះ សំខាន់គឺការពារមិនឱ្យអ្នកទោសរត់រួច មិនឱ្យស្លាប់ដាច់ចម្លើយ នេះសំខាន់ប៉ុណ្ណឹងឯង ។

**ស៖** កងការពារនោះមានបានបែងចែកអ្នកយាមផ្នែកខាងក្នុងនិងផ្នែកខាងក្រៅនៃមន្ទីរស-២១ទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! រឿងនេះវាចាស់យូរបន្តិចដែរទៅហើយ ហើយអង្គាល់នោះខ្ញុំក៏មិនសូវយកចិត្តទុកដាក់ដែរ ។ ក៏ប៉ុន្តែ សូមរំឭកឡើងវិញតាមការចងចាំដូចតទៅ៖

កងការពារធម្មតានៅក្រោមការគ្រប់គ្រងរបស់ មិត្តប៉ូច និង មិត្តប៉េង នេះ គិតតួរយាមកាមការពារតែខាងក្នុងទេ ។ ឯចំណែក យាមគុកពិសេសដែលនៅខាងក្រៅ គឺនៅខាងត្បូងវិទ្យាល័យពញាយ៉ាត គុកពិសេសហ្នឹងត្រូវកងពិសេសយាមៗ ។ ដូច្នេះ អ្នកកងការពាររបស់ មិត្តប៉េង យាមនៅខាងក្នុង កងពិសេសរបស់ មិត្តហ៊ុយ យាមនៅខាងក្រៅ ។

[១០:១១:២២]

**ស៖** សូមលោកបញ្ជាក់ឱ្យច្បាស់បន្ថែមទៀតមើល កងពិសេសនោះមានភារកិច្ចធ្វើអ្វីដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! កងពិសេសមានភារកិច្ចប្រាំមួយយ៉ាងដូចតទៅ៖

ភារកិច្ចទីមួយ គឺយាមការពារនៅខាងក្រៅ ។ ភារកិច្ចទីពីរ គឺរង់ចាំទទួលជនរងគ្រោះដែលគេបញ្ជូនមក ។ ធម្មតាអង្គភាពក្រៅគេបញ្ជូនជនរងគ្រោះមកឱ្យជាប់ទោស ជាប់ទណ្ឌនៅស-២១ គេយកមកបញ្ជូន-- គេបញ្ជូនយកមកដាក់នៅផ្ទះមួយ ដែលយើងខ្ញុំសរសេរថាអក្សរ *“R”* ដែលឥឡូវនេះវាជាវិទ្យុសំបុកឃ្មុំ ស្ថានីយ៍របស់វិទ្យុសំបុកឃ្មុំ ជាដីរបស់យើងខ្ញុំពីអង្គាល់ជំនន់នោះហើយ ។ ពួកនុ៎ងទទួលអ្នកទោស ហើយកត់ឈ្មោះហើយស្រួលបួល ក៏បណ្តើរអ្នកទោសយកទៅប្រគល់ឱ្យកងការពារ គឺមិត្តហ៊ុយ ត្រូវនាំអ្នកទោសយកទៅឱ្យ មិត្តប៉េង ។ ដល់ប្រគល់រួចស្រួលបួលគ្រប់ចំនួនហើយ បានៗមិត្តហ៊ុយ រួចខ្លួន ។ នេះភារកិច្ចទីពីរ ទទួលជនរងគ្រោះ ហើយនិងប្រគល់ជនរងគ្រោះទៅឱ្យពួកកង

ការពារ ។

ភារកិច្ចទីបី គឺអន្តរាគមន៍ខាងក្នុង ។ ឧបមា ពេលខ្មាំងឆក់កាំភ្លើងបាន កងពិសេសនេះហើយ ដែលនៅក្រោមបញ្ជា មិត្តហ៊ា ផ្ទាល់ក្នុងករណីពិសេសអ៊ីចឹង ជាអ្នកប្រយុទ្ធស៊ីសាច់ហុតឈាមគ្នា ដើម្បីការពារអង្គភាព ការពារមន្ទីរ ការពារបក្សរបស់គេនៅនុ៎ង នេះទីបី ។ ទីបួន ប្រសិនបើមានអន្តរាគមន៍មកពីខាងក្រៅ ពួកនេះឯង ជាអ្នកប្រយុទ្ធការពារអង្គភាពនេះ ជាមួយនឹងអន្តរាគមន៍ពីខាងក្រៅ ។ ប៉ុន្តែវាមិនដែលមានមួយប្រវត្តិស-២១ មិនដែលមានទេ ។ ហើយទីប្រាំ ពេលខ្លះកងពិសេសនេះទទួលចាប់មនុស្ស ដែលគេសម្រេចចិត្តឲ្យចាប់ ហើយឲ្យកម្មេចទៅ មកចាប់នៅស-២១ ។ ឧទាហរណ៍ដូចយ៉ាង ចាប់ កុយ ធួន ក៏ចាប់នៅនឹងក្រោមផ្ទះខ្ញុំ-- នៅនឹងផ្ទះខ្ញុំ ដែលកងពិសេសហ្នឹងជាអ្នកចាប់ ។

[១០:១៤:១៥]

ចាប់ ឈឹម សំអោក ហៅ ប៉ង់ នេះ ក៏កងពិសេសៗហ្នឹងចាប់ ក៏ប៉ុន្តែ ឈឹម សំអោក ហៅ ប៉ង់ អត់ទាំងមានកងពិសេសផង មេកងពិសេសធំតែម្តងជាអ្នកចាប់ មិត្តហ៊ា ។ មានតែគ្នាបីនាក់ទេ ខ្ញុំជាបញ្ជាការ, មិត្តហ៊ា ជាអ្នកចាប់, ឈឹម សំអោក ហៅ ប៉ង់ ជាអ្នករងគ្រោះ ដែលមកឲ្យខ្ញុំចាប់ តាមបញ្ជារបស់ពូ នួន ឈ្មោះដើម នួន ជា នោះ ។

ដូច្នេះ ភារកិច្ចរបស់កងពិសេសប៉ុណ្ណឹង សូមគោរពរាយការណ៍ជូនលោកចៅក្រមប៉ុណ្ណោះ ។

**ស៖** តើនៅក្នុងកងការពារនេះ មានបានចែកកងណាមួយដែលទៅប្រចាំការនៅជើងឯកទេ?

[១០:១៥:១២]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! កងដែលទៅប្រចាំការនៅជើងឯកហ្នឹង ជាផ្នែកមួយតូចនៃកងពិសេសៗទេ ។ ខ្ញុំទើបនឹងតែឃើញមុខពួកនុ៎ង នៅដែលគេយកខ្ញុំទៅបង្ហាញ ចៅក្រមស៊ើបអង្កេតទៅបង្ហាញទីតាំងហ្នឹង ខ្ញុំឃើញមុខ មិត្តតេង គ្នាមានភារកិច្ចត្រឹមតែជីករណ្តៅ ហើយលុបរណ្តៅឲ្យគេទេ ។ នេះនិយាយឲ្យតាមពិត មួយថ្ងៃៗនៅតែនឹងខ្មោចហ្នឹងឯង ។

**ស៖** តើនៅក្នុងកងនោះ មានមនុស្សចំនួនប៉ុន្មាននាក់?

**ឆ៖** បើតាម-- ជម្រាបប្រសាសន៍លោកចៅក្រម បើតាមខ្ញុំចាំ ហើយដោយខ្ញុំសួរមិត្តហ៊ា ម្តងមានប្រហែលជាបួននាក់ប៉ុណ្ណោះ បើកងតូចហ្នឹង-- បើៗគ្នា២៤នាក់ ហ្នឹង នៅប្រចាំនៅហ្នឹង ។ ប្រចាំម្យ៉ាងទៀត ការពារមិនឲ្យអ្នកណាចូលទៅលួចមើលកន្លែងសពកន្លែងកប់សពអីហ្នឹង ។

**ស៖** ក្រៅពីអង្គភាពសួរចម្លើយ អង្គភាពយោធា តើអង្គភាពអ្វីផ្សេងទៀតនៅក្នុងមន្ទីរស-២១

នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម មានអង្គភាពច្រើនផ្សេងទៀត ដែលខ្ញុំសុំរៀបរាប់តទៅ ហើយក៏អាចភ្លាត់ភ្លេចខ្លះ ។ ទីមួយ អង្គភាពខាងវាយម៉ាស៊ីន វាយអក្សរអង្គុលីលេខ ។ ទីពីរ អង្គភាពខាងរៀបចំប្រព័ន្ធទូរស័ព្ទនៅខាងក្នុងស-២១ ហ្នឹង ។ ទីបី អង្គភាពថតរូប ។ ទីបួន អង្គភាពពេទ្យ ។ ទីប្រាំ អង្គភាពខាងស្បៀងអាហារដែលចែកចេញជាផ្ទះបាយពីរ ផ្ទះបាយសម្រាប់ជនរងគ្រោះហ្នឹងមួយផ្នែកទៅ ហើយនិងផ្ទះបាយសម្រាប់យុទ្ធជនកម្មាភិបាលមួយផ្នែកទៀត ។

ហើយមានបង្កើតកូនអង្គភាពមួយតូចទៀត គឺអង្គភាពចម្លងផែនទី ។ យកផែនទីខ្នាត១ភាគហាសិបពាន់ហ្នឹង យកទៅចម្លង នឹងសូមបញ្ជាក់ខ្ញុំ-- ខ្ញុំរំឭកឡើងវិញភ្លាមៗនេះចាំបានប៉ុណ្ណេះ ។ នៅខាងអង្គភាពបញ្ជីមួយរយដែលគ្រប់គ្រងដោយមិត្តធី ហើយនិងអង្គភាពខាងចិញ្ចឹមសត្វនិងដាំបន្លែបង្ការ ។

**ស៖** តើអង្គភាពអង្គុលីលេខនោះ អ្នកណាជាអ្នកគ្រប់គ្រង? ហើយមានភារកិច្ចធ្វើអ្វី? ហើយទទួលកិច្ចការអ្វីពីអ្នកណា?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! អង្គភាពដែលវាយអង្គុលីលេខនេះ ទទួលការងារវាយអង្គុលីលេខចម្លងចម្លើយសារភាពរបស់ជនរងគ្រោះដែលគេជាប់ទោសនៅទុំង ។ ដូច្នេះ ពួកនេះភាគច្រើនទទួលចម្លើយសារពី មិត្តហ៊ុំ ក៏ប៉ុន្តែពេលខ្លះចាំបាច់ ខ្ញុំក៏ផ្តល់ឲ្យទៅពួកនោះដែរ ។ ដូច្នេះ ពួកនេះវាយសំខាន់គឺបញ្ជីចម្លើយសារភាព ។ បន្ទាប់មកទៀត វាយបញ្ជីមួយរយអីហ្នឹងខ្លះទៀតផងក៏មិនដឹង ។ ប៉ុន្តែ សំខាន់ គឺវាយអង្គុលីលេខចម្លើយសារភាពនេះ មិត្តហួ គ្រប់គ្រង ។

[១០:២០:២២]

សូមបញ្ជាក់លោកចៅក្រមថា ចម្លើយដែលសម្ងាត់មែនទែន មិនមែននៅលើមិត្តហ៊ុំ, មិត្តហួវាយចម្លងទេ ។ គឺនៅលើនីរសារខ្ញុំពីរនាក់ មិត្តឆេន ហើយនិង មិត្តសំ ហ្នឹងចម្លើយទាំងឡាយណាដែលសម្ងាត់បំផុត ហើយដែល មិត្តហ៊ុំ គ្មានសិទ្ធិមើលនោះ គឺនៅលើដៃនីរសារខ្ញុំទាំងពីរនាក់នេះឯង ។ នេះអង្គភាពអង្គុលីលេខ វាមានចែកជាកូនផ្នែកពីរតូចហ្នឹងទៅទៀត ។

**ស៖** អង្គភាពរៀបចំប្រព័ន្ធទូរស័ព្ទនោះ ហើយសម្រាប់ទំនាក់ទំនងខាងក្នុង តែខាងក្នុងស-២១ ឬក៏ខាងក្រៅហៅទៅ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ទូរស័ព្ទពីខាងក្រៅមកមាន មានតែមកកន្លែងផ្ទះខ្ញុំ តែមួយកន្លែងប៉ុណ្ណឹងទេ ។ ទូរស័ព្ទនេះពិសេសណាស់ ចាប់ផ្តើមនិយាយគ្នា ចុចប៊ូតុងទៅ*ប្រេកង់* ប្តូរហើយ

*ប្រេកង់* សំឡេងប្តូរហើយ គ្មានអ្នកណាអាចម្ហុលខ្ទាស់ទៅដោតស្តាប់តាមខ្សែទាំងពីរនោះបានទេ សំឡេងប្តូរហើយ លែងឮសំឡេងមនុស្ស តែឮញ៉ិក១ ។ ការតខ្សែពីផ្លូវផ្ទល់ចូលមកផ្ទះខ្ញុំគឺមិត្តហួ ទទួលខុសត្រូវឯចំណែកសង់ត្រាល់ទូរស័ព្ទនេះ នៅទីស្នាក់ការធ្វើការងាររបស់លោកគ្រូ សុន សេន ដែលខ្ញុំសរសេរអក្សរបេ "B" នៅលើផែនភ្ជំពេញរបស់ខ្ញុំបាទ នេះសង់ត្រាល់នៅនុ៎ង ។

ឯចំណែក នៅក្នុងមន្ទីរស-២១ មានទូរស័ព្ទពីរប្រភេទ ។ ទូរស័ព្ទមួយបែប ខ្ញុំបាទសូមហៅថា "ទូរស័ព្ទអគ្គិសីន"ចុះ ដែលពួកយោធាច្រើនប្រើរវៃដាក់ថ្មពិលពីរកូន១ ។ ទូរស័ព្ទនេះមានសង់ត្រាល់មួយប្រើបានប្រហែលជាជាង១០នាក់ ។ ទូរស័ព្ទបែបនេះគ្មានភ្ជាប់មកផ្ទះខ្ញុំនាំឲ្យរំខានទេ ។ មានទូរស័ព្ទមួយទៀត ដែលយើងខ្ញុំហៅថា "ទូរស័ព្ទស្វ័យប្រវត្តិ"នោះ ចុចដៃអ៊ីចឹងទៅបង្វិល ។ ទូរស័ព្ទនេះសង់ត្រាល់តូចណាស់ ដាក់បាន *កុំមុយណេ* ប្រហែលជាបីប៉ុណ្ណោះទេ មាន*កុំមុយណេ* មួយទៅផ្ទះខ្ញុំ *កុំមុយណេ* មួយនៅកន្លែងធ្វើការរបស់មិត្តហ៊ី ។ កាលណាខ្ញុំត្រូវការហៅ មិត្តហ៊ី ខ្ញុំហៅគាត់មកឲ្យជួបខ្ញុំតាមទូរស័ព្ទនេះ ។

សរុបមក មិត្តផេង ជាអ្នករៀបចំទូរស័ព្ទនេះ ទទួលខ្សែទូរស័ព្ទតចូលផ្ទះខ្ញុំ ទូរស័ព្ទមកពីខាងក្រៅហ្នឹងមួយ ហើយភ្ជាប់ពីផ្ទះខ្ញុំមកសង់ត្រាល់ទូរស័ព្ទស្វ័យប្រវត្តិហ្នឹងមួយ ។ ឯចំណែកក្រៅពីនោះគឺរៀបចំទូរស័ព្ទ-- អាទូរស័ព្ទអគ្គិសនីរវៃហ្នឹងនៅក្នុងអង្គភាព ប៉ុន្តែមិនដឹងចែកទៅកន្លែងណាខ្លះទេ ។

**ស៖** តើអង្គភាពថតរូបនេះ មានគ្នាចំនួនប៉ុន្មាននាក់? ហើយមានភារកិច្ចធ្វើអ្វី?

[១០:២៤:៣០]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! អង្គភាពថតរូបនេះមានគ្នាបើមិនប្រាំប្រាំមួយនាក់ប៉ុននុ៎ងទេ ។ ប្រធានអង្គភាពនេះឈ្មោះ មិត្តស្រ៊ាង ។ មិត្តស្រ៊ាង នេះ ខ្ញុំប្រើឲ្យថតរូបជនរងគ្រោះដែលទើបនឹងមកដល់ភ្លាម គឺ មិត្តស្រ៊ាង នេះហើយជាអ្នកថត ប្រធានគេ ។ ទីពីរ មិត្តសុង១ នេះទទួលភារកិច្ចទៅថតអ្នកដែលទទួលអប់រំសាថ្មីនៅព្រៃស ។ ឯចំណែក មានម្នាក់ទៀត ទទួលភារកិច្ចថតដែរ តែសម្ងាត់គឺមិត្តស្រ៊ី នៅក្នុងកងពិសេស ។ សូមលោកដាក់ទៅខាងកងពិសេសឲ្យខ្ញុំឃើញបន្តិចមក នេះ១មិត្តស្រ៊ី ។ មិត្តស្រ៊ី គាត់ជាអនុលេខាកងពិសេស ពេលណាជនរងគ្រោះទាំងឡាយណាដែល ពួនួន គាត់បញ្ជាឲ្យសម្លាប់ហើយ ថតរូបទៅឲ្យគាត់ទុកជាភស្តុតាងគឺ មិត្តស្រ៊ី ហ្នឹងហើយមិនមែនមិត្តស្រ៊ាង ជាអ្នកថតទេ ។ នេះកងពិសេស គេលែងអាសម្ងាត់អ៊ីចឹងទេ ។ ដូច្នេះ ជាងថតនោះវាមានពីរកូនផ្នែកទៅទៀត គាត់កងពិសេសតែគាត់ដើរជាអ្នកថត ។ ទីពីរគឺគាត់ជាអ្នកថតពិតប្រាកដ ម្នាក់ថតនៅក្នុងស-២១គឺ មិត្តស្រ៊ាង

ម្នាក់ទៀតគឺថតនៅឯព្រៃស គឺមិត្តសុង ។

**ស៖** តើអង្គភាពពេទ្យនោះ មានគ្នាប៉ុន្មានដែរ? ហើយមានភារកិច្ចធ្វើអ្វីនៅ ស-២១?

**ឆ៖** អង្គភាពពេទ្យនេះ ខ្ញុំក្លាប់អត់បានថាមានគ្នាប៉ុន្មានទេ ក៏ប៉ុន្តែប្រធានពេទ្យដំបូង គឺមិត្តសំអឿ ឈ្មោះ អឿ ។ សុំទោសខ្ញុំអាចច្រឡំឈ្មោះ ស្រពេចស្រពិលខ្លះ ក៏ប៉ុន្តែក្រោយមកក៏កម្ទេចបាត់ទៅ ឡើង មិត្តទ្រី ។ អង្គភាពពេទ្យនេះ ដំបូងមានភារកិច្ចព្យាបាលកម្មាភិបាលដែរ ក៏ប៉ុន្តែតាំងពី មិត្តប៉ោ គាត់ទៅ ដាក់ថ្នាំ *ប៉េម៉ាហ្សាល់* ពេលដែលមិត្តហ៊ា រាក មិត្ត ប៉ោ គាត់ដាក់ថ្នាំ *ប៉េម៉ាហ្សាល់* ហ្នឹងទៅ ធម្មតាទេ *ប៉េម៉ាហ្សាល់* វាមានជាតិ*អាស៊ីទិច* ។ វាប្រកាច់មិត្ត ហ៊ា ខ្ញុំរាយការណ៍ទៅលើភ្លាម ដល់ខាងលើដឹងរឿង ថាចាប់ទៅ មិត្តឌុច ។ ខ្ញុំក៏ឱ្យគេចាប់មិត្ត ប៉ោ ហ្នឹងបាត់ទៅ ។

ដូច្នេះ តាំងពីនោះមក កម្មាភិបាលដែលឈឺនៅក្នុងមន្ទីរច្រើនតែរត់ទៅក្រៅទេ ទៅពេទ្យ៩៨ ។

ដូច្នេះ សរុបមក ពេទ្យចុងបញ្ចប់នៅត្រឹមតែព្យាបាលអ្នកទោសសម្រាប់ឱ្យរស់ សួរចម្លើយចប់ ហ្នឹងអាលឱ្យគេយកទៅ ទុកឱ្យរស់ក៏នាំឱ្យសម្រាប់សួរ នេះសូមនិយាយខ្លី ។ ក្រៅពីនោះមានភារកិច្ច មួយទៀតគឺស្លថ្នាំបូរាណយកមកប្រើ មានទាំងច្នៃរបៀបធ្វើអំពូលអីផង ។ នេះសូមបញ្ចប់ អំពីភារកិច្ច ពេលប៉ុណ្ណោះ ។

**ស៖** ខ្ញុំបានបញ្ជាក់អម្បាញ់មិញថា មានភារកិច្ចធ្វើថ្នាំស្លបូរាណ តើថ្នាំស្លបូរាណនោះ គឺសម្រាប់ តែអ្នកទោស ឬក៏សម្រាប់កម្មាភិបាលនៅក្នុង ស-២១នោះដែរ?

**ឆ៖** ភាគច្រើន-- អឺ! មិននិយាយភាគច្រើនទេ សុទ្ធសាច់តែហ្នងឱ្យតែអ្នកទោស កម្មាភិបាល ច្រើនតែរត់ទៅពេទ្យ៩៨ ។

សូមបញ្ជាក់ជូនលោកចៅក្រមថា ពេទ្យ៩៨នេះ ជាពេទ្យរបស់សេនាធិការ "ព-៩៨" ពាក្យ៩៨ នេះ វាជាលេខត្រឡប់ លេខសម្ងាត់ លេខខ្លួនរបស់លោកគ្រូ សុន សេន លេខឈ្មោះគ្រូ សុន សេន ៨៩ ត្រឡប់ឱ្យទៅ ៩៨ ។

[១០:២៩:៤៨]

**ស៖** អង្គភាពស្បៀងអាហារ មានគ្នាប៉ុន្មាននាក់ដែរ? ហើយមានភារកិច្ចធ្វើអ្វីនៅ ស-២១?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម អង្គភាពស្បៀងអាហារនេះ ខ្ញុំស្គាល់ច្បាស់ជាងគេ គឺ មិត្តចន ចុះឡើង១ផ្ទះខ្ញុំ យកផ្លែឈើទៅឱ្យខ្ញុំទទួលទាន មិនសូវដែលដាច់ ។ មូលដ្ឋានផ្លែឈើទៅតាខ្មៅ បន្លែបង្ការអីនៅតាខ្មៅ ។ កន្លែងចិញ្ចឹមជ្រូកអីនៅតាខ្មៅដែរ ។

ដូច្នេះ គ្នាប៉ុន្មាននាក់ខ្ញុំក្តាប់អត់បានទេ នេះមានមួយផ្នែកទទួលភារៈខាងចិញ្ចឹមជ្រូក និងដាំបន្លែបង្ការ ហើយនិងថែទាំឈើហូបផ្លែនៅតាខ្មៅ ។ ឯចំណែកចង្ក្រានបាយ ចែកជាពី ចង្ក្រានបាយសម្រាប់យុទ្ធជន និងកម្មាភិបាលស-២១ ។ អ្នកទទួលខុសត្រូវដាំស្ល គឺបងមុំ ប្រពន្ធបង ម៉ម ណៃ ហៅចាន់ ។ ឯចំណែក អ្នកដែលទទួលភារកិច្ចដាំស្លឲ្យអ្នកទោសដែលជនរងគ្រោះទៅជាប់ទោសនៅទីនោះ ម្តងនោះដាក់ ចាន់ ថ្លា ហើយដល់ក្រោយមកដាក់ មិត្តម៉ែន ដោយក្រោយមកទៀតមិនដឹងដាក់អ្នកណាទេ ចេះតែប្តូរហើយ យកអ្នកទោសមកចាត់តាំងប្រើប្រាស់ ។ នេះសូមបញ្ជាក់ប៉ុណ្ណឹង ។ ឯចំណែក មិត្តថន ក៏មានភារកិច្ចដែរ ទៅបើរបស់របរពីខាងភស្តុភារសេនាធិការយកមកសម្រាប់អង្គភាព ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាកកន្លះម៉ោង ដើម្បីទៅជាការឈប់សម្រាកផង ហើយនឹងពិភាក្សាកិច្ចការចំនួនត្រូវសម្រេចផង ។

អ៊ីចឹងត្រឹមប៉ុណ្ណេះ ហើយម៉ោងដប់មួយ រហូតដល់ម៉ោងដប់មួយ អញ្ជើញចូលវិញ ។

[១០:៣២:០០]

*[សវនាការសម្រាកពីម៉ោង ១០:៣២ នាទីដល់ម៉ោង ១១:០៨នាទី]*

[១១:០៨:២៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចពិភាក្សាដេញដោលតទៅទៀត ហើយមុននឹងឈានចូលដល់កិច្ចពិភាក្សាដេញដោល អង្គជំនុំជម្រះសូមប្រកាសនូវសេចក្តីសម្រេចប្រឆាំងទៅនឹងយោបល់ជំទាស់ទៅនឹងការចែកឯកសារជាសៀវភៅ ដកស្រង់នូវរូបភាពមួយចំនួនចេញពីសំណុំរឿង ដោយសហព្រះរាជអាជ្ញាដែលមិនមានសេចក្តីពិភាក្សា ឬកំណត់សម្គាល់អ្វីភ្ជាប់មកជាមួយនោះ ។ ហើយទន្ទឹមនឹងនេះ ក៏មានការណែនាំដល់ភាគីមួយចំនួនដូចខាង៖

ភាគីទាំងអស់សុទ្ធតែមានសិទ្ធិនូវការចងក្រងនូវឯកសារភាពនានា ដើម្បីចែកជូនដល់អង្គជំនុំជម្រះ និងភាគីនានាផ្សេងទៀតដូចគ្នា ក្នុងគោលបំណងដើម្បីសម្រួលដល់កិច្ចដំណើរការនីតិវិធីរបស់យើង ។

ជាការល្អ និងជួយសម្រួលដល់ដំណើរការនីតិវិធី ប្រសិនបើភាគីមានបំណងលើកយកឯកសារណាមួយ ឬច្រើនមកពិភាក្សាដេញដោលគប្បីជូនដំណឹងពីឯកសារនេះមកអង្គជំនុំជម្រះសាលាដំបូងជាមុន ។ ហើយកិច្ចនេះគប្បីធ្វើតាមរយៈក្រឡាបញ្ជីសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង ។

ដោយឡែក សម្តីកត់សម្គាល់របស់មេធាវី-- (សូមទោស) គ្រប់ភាគីមានសិទ្ធិស្នើសុំលើកយកឯកសារ ឬច្រើនមកពិភាក្សាដេញដោលបាន តែមិនត្រូវធ្វើការវិភាគ ឬកត់ស្គាល់អ្វីទៅលើឯកសារដែលបានស្នើឡើងនោះឡើយ ។ ការស្នើសុំត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ថា ឯកសារនោះជាឯកសារទាំងស្រុង ឬក៏ជាឯកសារដកស្រង់នៅផ្នែកណាមួយ ។

[១១:១១:១៣]

ជាកិច្ចបន្តនេះ មុននឹងចាប់ផ្តើមអំពីកិច្ចបន្តទៀត សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលយ៉ា ខាតវ៉ាថ៍ មានសំណួរដែលមានការពាក់ព័ន្ធទៅនឹងសម្តីកត់សម្គាល់របស់មេធាវី អាឡាំង វ៉ែនណឺ ដែលជាមេធាវីតំណាងឲ្យដើម្បណ្តឹងរដ្ឋប្បវេណីក្រុមមួយ ។ សូមអញ្ជើញលោកស្រី ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធានមុននឹងចូលទៅដល់នោះ ខ្ញុំសូមកែអត្ថបទសេចក្តីសម្រេចការបកប្រែទៅលើសម្តីរបស់លោកប្រធាន គឺថា ដើម្បីសម្រួលដល់ដំណើរការនីតិវិធី គឺអាចនឹងមានប្រយោជន៍ប្រសិនបើភាគីដែលចង់ដាក់នូវឯកសារជូនអង្គជំនុំជម្រះសាលាដំបូង ហើយត្រូវតាមរយៈរបស់ក្រឡាបញ្ជីនេះ មិនជាកត្តាបង្គាប់ទេ ។ គឺថាភាគីអាចធ្វើដូច្នោះ បើខ្លួនចង់ធ្វើមិនមែនជាលក្ខខណ្ឌតម្រូវថាត្រូវតែធ្វើទេ ។

សូមអរគុណ ។ ឥឡូវនេះ ខ្ញុំចូលយើងត្រឡប់ទៅរកមតិយោបល់មួយរបស់លោក វ៉ែនណឺ តាមដែលខ្ញុំយល់គឺថា អាចនឹងវាខុសគ្នាបន្តិច ពីលោកចៅក្រមផ្សេងៗទៀត ដែលលោកជំទាស់នោះគឺដូចខាងក្រោម៖

លោកមិនបានស្នើថា ត្រូវមានសេចក្តីសម្រេចទាក់ទងទៅនឹងការទាក់ទងរវាងមេធាវី ហើយនិងមេធាវីការពារ ហើយនិងជនជាប់ចោទ តើត្រូវទេ?

[១១:១៣:០២]

**លោក អាឡាំង វ៉ែនណឺ៖**

ត្រូវហើយ លោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អ៊ីចឹងហើយ នៅពេលដែលលោកជំទាស់នោះ គឺដែលថាមេធាវីការពារបានផ្តល់នូវការសង្ខេប ផ្តល់ការសង្ខេប ផ្តល់ការសង្ខេបទៅលើសក្ខីកម្មរបស់ជនជាប់ចោទ មុនពេលដែលភាគីទាំងអស់ដែលនឹងសួរសំណួរ ។ ថាតើខ្ញុំយល់អ៊ីចឹងត្រូវទេ?

**លោក អាឡាំង វែ៉នណឺ៖**

គឺថាត្រូវហើយ ប៉ុន្តែក្រៅពីហ្នឹងទៀត គឺថានៅក្នុងការអាននូវវិធាន៩០ នៅក្នុងកថាខណ្ឌទី២ គឺផ្ទុះបញ្ចាំងពី-- គឺបញ្ជាក់ថាគឺៗបញ្ជាក់ទៅលើភស្តុតាងដែលផ្តល់ឡើងទៅតាមអ្វីដែលជនជាប់និយាយក្នុងពេលធ្វើសវនាការ ប៉ុន្តែនៅពេលដែលគាត់នៅក្នុងរង្វង់ក្រចកសេះ ដែលគាត់ឆ្លើយនូវសំណួរទាក់ទងទៅនឹងសំណួរគឺថាៗក្រៅពីហ្នឹងគឺថា គេមិនត្រូវពិភាក្សាពេលយប់ទេរវាងជនជាប់ចោទ និងមេធាវីការពារនោះ ។ គឺថា ប៉ុន្តែមេធាវីគឺអនុញ្ញាតឲ្យសួរសំណួរបំភ្លឺ ឬសំណួរនៅពេលមួយថ្ងៃក្រោយនោះក្នុងពេលដែលខ្ញុំៗលើកឡើងសំណួរនោះ ។ គឺថាខ្ញុំមិនបានបញ្ជាក់ថាមេធាវីការពារមិនអាចៗនិយាយជាមួយជនជាប់ចោទទេ គឺថាយើងមិនជំទាស់ទេ ។ ប៉ុន្តែ នៅក្នុងវិធាន៩០.២ គឺថាមូលដ្ឋាននៃធានាថានៅក្នុងករណីនេះ នៅពេលដែលគាត់កំពុងឆ្លើយសំណួររហូតទាល់តែបញ្ចប់គឺថា បន្ទាប់ពីចប់សវនាការទៅពេលយប់ គឺថាមេធាវីមិនត្រូវពិចារណាផ្តល់យោបល់អ្វីទេ រហូតទាល់តែបានសួរដោយភាគីផ្សេងៗទៀត ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អរគុណលោក វែ៉នណឺ ។

[១១:១៥:០៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះធ្វើការកត់សម្គាល់នូវសម្តីរបស់មេធាវី អាឡាំង វែ៉នណឺ ដែលជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ហើយអង្គជំនុំជម្រះនឹងយកបញ្ហានោះទៅពិភាក្សាសម្រេចនៅពេលក្រោយ ។

អត់មានការបកប្រែពិនិត្យឡើងវិញទៅមើល ភាសាបារាំងអត់មានការបកប្រែទេ ។ អញ្ជើញលោកមេធាវី ។ អញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រូ ដែលប៉ុនប៉ងនឹងការលើកឡើងនូវបញ្ហាអីផ្សេងទៀត សូមអញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន បន្ទាប់ពីមានការបំភ្លឺដោយលោក វ៉ែនណឺ មក ដើម្បីឲ្យអង្គជំនុំជម្រះធ្វើសេចក្តីសម្រេចលើបញ្ហានេះ ខ្ញុំចង់បញ្ជាក់អំពីសេចក្តីសង្កេតមួយចំនួនទាក់ទងទៅនឹងបញ្ហាដ៏សំខាន់មួយនេះ ដែលអាចនឹងអាចនឹងឲ្យមានការកែតម្រូវនូវលទ្ធផលនៃសវនាការនេះ ។

ជាថ្មីម្តងទៀត ដែលខ្ញុំអាចនឹងយល់យ៉ាងច្បាស់បានថា គោលជំហរដែលលើកឡើងដោយលោក វ៉ែនណឺ នោះ តាមពិតនៅពេលដែលយើងស្ថិតនៅក្នុងដំណើរការសវនាការ ខ្ញុំយល់ថា យើងនៅក្នុងដំណើរការនីតិវិធីដែលជនជាប់ចោទគាត់បានផ្តល់សម្បថហើយ នៅពេលដែលយើងនឹង-- ប៉ុន្តែនៅពេលដែលជនជាប់ចោទត្រូវបានសម្ភាសន៍ដោយសាក្សី ប៉ុន្តែជាគោលជំហរដែល អាឡាំង វ៉ែនណឺ បានលើកឡើង ។ ប៉ុន្តែ ក្នុងករណីនេះមិនត្រូវយកឃ្លានោះមកប្រើទេ ។ ជនជាប់ចោទមិនត្រូវបានសួរក្នុងឋានៈជាសាក្សីទេពេលនេះ ។

ហើយ អាឡាំង វ៉ែនណឺ លោក វ៉ែនណឺ ខ្ញុំសូមបញ្ជាក់លោកឲ្យបានច្បាស់ថា ខ្ញុំមិនបាននិយាយទៅកូនក្តីរបស់ខ្ញុំពេលល្ងាចនោះទេ ។ ខ្ញុំនិយាយពេលព្រឹកហើយពេលសម្រាក ហើយខ្ញុំក៏និយាយជាមួយគាត់ដែរនៅពេលល្ងាច ។ នេះជាកតាព្វកិច្ចរបស់ខ្ញុំជាមេធាវីការពារ ។

ហើយតាមពិតដែលខ្ញុំបានពិភាក្សាលម្អិតជាមួយគាត់ គឺគ្រប់សំណួរទាំងអស់ដែលយើងបានពាក់ព័ន្ធនៅក្នុងសវនាការនេះ ។

ដូច្នេះ ដោយសេចក្តីគោរពលោក លោកស្រីចៅក្រម ខាតវ៉ាយថ៍ ហើយនិងលោកចៅក្រម ដែលខ្ញុំយល់ថាលោកយល់អំពីនីតិវិធីប្រព័ន្ធច្បាប់ខំមិនឡូ ច្បាស់ណាស់ ដែលថានៅក្នុងនោះយើងមិនអនុញ្ញាតឲ្យលើឡើងនូវបញ្ហាអ្វីនៅក្នុងពេលសួរ-- មិនឲ្យធ្វើអន្តរាគមន៍ពេលដែលជនជាប់ផ្តល់ចម្លើយជាសាក្សី ប៉ុន្តែ ខ្ញុំគោរពទៅតាមប្រព័ន្ធហ្នឹង ។ ប៉ុន្តែ យើងធ្វើការងារក្នុងប្រព័ន្ធនេះ ប្រព័ន្ធឥឡូវ វានឹងអាចបង្កឲ្យមានគ្រោះអន្តរាយដើម្បីយកវិធាននេះមកប្រើនៅទីនេះនៅក្នុងពេលនេះ ។ វិធាននេះគឺមិនបានដាក់បញ្ចូលនូវក្នុងវិធាន៩០ នៃកថាខណ្ឌ២ ទេ ដោយមូលហេតុតែមួយដែលយើងមាន ដែលថាវិធាន៩០ នៅក្នុងកថាខណ្ឌទី២នោះ មិនបានបញ្ជាក់ថា ជនជាប់ចោទត្រូវបានធ្វើសច្ចាប្រណិធាននោះទេ ធ្វើសម្បថនោះទេ ។

ប៉ុន្តែ នៅពេលដែលវិធាននេះបានសរសេរហើយថា ជនជាប់ចោទបានធ្វើសម្បថនោះ គឺមិនមានបាននិយាយទេនៅក្នុងវិធាននេះ ។ អ៊ីចឹងហើយបើសិនជាជនជាប់ចោទមិនធ្វើសម្បថទេ ហើយសូមកុំ

បង្កើតវិធានថ្មីអ្វីនៅទីនេះ ពីព្រោះថាវិធានមានចែងនៅក្នុងតែដំណាក់កាលដែលថា ពេលដែលជនជាប់ចោទធ្វើសម្បថទេ ដែលមេធាវីមិនអាចពិភាក្សាបាននោះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យជជែកពីបញ្ហាហ្នឹងទៀតទេ ។ អង្គជំនុំជម្រះសូមកត់សម្គាល់នូវការលើកឡើងរបស់មេធាវី អាឡាំង វ៉ែនណឺ ដែលជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ដែលអង្គជំនុំជម្រះនឹងយកទៅពិភាក្សាសម្រេចនៅពេលក្រោយ ។

ជាកិច្ចបន្ត សូមអញ្ជើញលោក យ៉ា សុខន តាំងសំណួរផ្សេងៗ ដែលលោកយល់ឃើញថាចាំបាច់ដើម្បីសួរដល់ជនជាប់ចោទជាបន្តទៀត ទាក់ទិនជាមួយនឹងអង្គហេតុដែលបានកំណត់នៅក្នុងកាលវិភាគនៃដំណើរការសវនាការនៅពេលនេះ ។

**ចៅក្រម យ៉ា សុខន៖**

សូមអរគុណលោកប្រធាន ។

សូមមន្ត្រីតុលាការបង្ហាញឯកសារដែលមានលេខ 00154228 ម្តងទៀត លើអេក្រង់ ។

**ស៖** ជនជាប់ចោទនៅក្នុងផ្នែកអង្គភាពផ្សេងៗនេះ អង្គជំនុំជម្រះបានពិនិត្យមើលឃើញអង្គភាពមួយទៀត គឺអង្គភាពរដ្ឋបាល និងបុគ្គលិក ។ តើអង្គភាពនេះអ្នកណាជាអ្នកគ្រប់គ្រង ហើយភារកិច្ចធ្វើអ្វីនៅក្នុង ស-២១? តើត្រូវមានជ្រើសរើសបុគ្គលិកថ្មីផ្សេងទៀតទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! អង្គភាពរដ្ឋបាល និងបុគ្គលិកនេះ អត់មានជ្រើសរើសបុគ្គលិកថ្មីទេ ។ ក៏ប៉ុន្តែ និយាយអ៊ីចេះ វាជាន់កែងហើយ ។ ក្រោយពីកកើតមន្ទីរស-២១ យើងខ្ញុំបានសុំអនុញ្ញាត លោកគ្រូ សុន សេន ជាមេ ទៅយកក្មេងជំទង់មកពីខាងតំបន់៣១ មួយចំនួន ។ លោកគ្រូ សុន សេន គាត់អនុញ្ញាតឲ្យធ្វើអ៊ីចឹង ព្រោះមូលដ្ឋានពួកយុទ្ធជនកងពល៧០៣ ច្រើនតែជាកសិករតាមដងទន្លេ ។ កសិករតាមដងទន្លេហ្នឹងភាគច្រើនជាកសិករកណ្តាលថ្នាក់លើ ដែលបក្សមានការមិនសូវជឿទុកចិត្ត ។

[១១:២៣:៣៦]

ដូច្នេះ នៅពេលដែលកកើតមន្ទីរស-២១ ហើយ ខ្ញុំក៏សុំអនុញ្ញាតទៅយក រើសយកក្មេងជំទង់ពីតំបន់៣១ ។ តំបន់៣១ សូមបញ្ជាក់ថាខាងកំពង់ឆ្នាំង យកមកបញ្ចូលនៅក្នុងអង្គភាពនេះ មកប្រហែលជាពីរឡាន ម្តងមួយឡានៗ ។ មួយឡានអាកាត់ៗចិន គ្នាទាំងអស់បូកទៅប្រហែលជា៦០នាក់ ប៉ុននុ៎ង ។

ដូច្នេះ បុគ្គលិកដែលយើងហៅថាថ្មី គឺសុំបញ្ចូលមកក្រោយការកកើតអង្គភាពស-២១ហ្នឹងមានប៉ុណ្ណឹងៗ។ ក៏ប៉ុន្តែ អង្គភាពបុគ្គលិក និងរដ្ឋបាលនេះ កាន់កាប់ដោយ មិត្តធី ដដែល ។ បញ្ជីមួយរយបុគ្គលិក កងណានៅឯណា ថ្ងៃណា បុគ្គលិកណាចេញអីទាំងប៉ុន្មានគឺនៅលើបញ្ជីមួយរយហ្នឹងឯង ។

ដូច្នេះ គ្មានការជ្រើសរើសអង្គភាពបុគ្គលិកថ្មីទេ មានតែការផ្ទេរចុះឡើង ។ ឧទាហរណ៍ផ្ទេរមិត្តប៉េង ពីលេខាកងពិសេស មកជាលេខាអនុសេនាធំកងការពារ របៀបហ្នឹង មានតែប៉ុណ្ណឹង ហើយនិងមានចាប់អ្នកណាចេញ គឺផ្នែកហ្នឹងជាអ្នកគិតគូរបញ្ជីមួយរយ គិតគូរហើយ ចារទុកអ្នកនេះចាប់ពីថ្ងៃនេះអីច្បាស់លាស់ ។ ក៏ប៉ុន្តែ បញ្ជីបុគ្គលិករបស់ស-២១ តាំងពីយើងខ្ញុំចូលមកទទួលការស៊ើបអង្កេតនៅទីនេះមិនដែលឃើញបញ្ជីបុគ្គលិករបស់មន្ទីរស-២១ ម្តងណាទេ ។ ប៉ុន្តែ ជាគោលការណ៍មាន ។ នេះសូមបញ្ជាក់ជូនលោកចៅក្រមប៉ុណ្ណេះ ។

**ស៖** តើក្នុងការជ្រើសរើសកុមារ ក្មេងជំទង់៦០នាក់ បន្ថែមមកក្នុងមន្ទីរស-២១ នេះ តើមានគោលបំណងឲ្យមកបម្រើក្នុងផ្នែកអីនៅក្នុងមន្ទីរ ស-២១?

**ឆ៖** លោកចៅក្រមជាទីគោរព! ក្មេងជំទង់ទាំងអស់នេះ មិនទាន់ពេញវ័យសម្រាប់បំពេញភារកិច្ចឲ្យច្បាស់លាស់ទេ ។ ចូលមកដល់ ខ្ញុំប្រុងចង់ចាត់ចែងដែរ ប៉ុន្តែអង្កាល់នោះ ណាត គាត់នៅធ្វើប្រធានគាត់ថាយើស យកទៅដាក់ឲ្យខាងយោធាទៅ មិត្តឯងគ្មានសិទ្ធិទៅកាន់ខាងកិច្ចការនោះទេ ។ ខ្ញុំក៏ឲ្យទៅគេទៅ ។ ក៏ប៉ុន្តែ ក្នុងចំណោមគ្នា៦០នាក់នេះ ខ្ញុំជ្រើសរើសយកមកធ្វើនីរសាម្តងមួយ មិនពេញចិត្ត ខ្ញុំប្រគល់ទៅឲ្យមិត្តហ៊ី វិញ ។ ខ្ញុំរើសយកមកមួយទៀត ទាំងអស់បីនាក់ហើយ ។ នៅចុងក្រោយបានចុះមក ថាន់ ជាទីបីហ្នឹង ជាមួយមិត្ត ឆេន ។ ដូច្នេះ មួយផ្នែកមកជានីរសាររបស់ខ្ញុំ មួយផ្នែកទៀតទៅជាកុមារចិញ្ចឹមទន្សាយ រកត្រកួនឲ្យទន្សាយស៊ី ។ ហើយមួយផ្នែកទៀត ជួយការងារកំប៉ិកកំប៉ុកនៅនឹងកងការពារហ្នឹង ។ នេះតាមខ្ញុំចាំ ត្រង់ឲ្យខ្ញុំចាត់ចែងផ្ទាល់ល្អិតចំពោះពួកអស់នេះគឺអត់មាននៅឡើយទេ ។

ដូច្នេះ បើចូលបាន ចូលត្រឹមតែនីរសារខ្ញុំ ហើយនិងកងការពារមន្ទីរប៉ុណ្ណោះឯង ព្រោះនៅក្មេងៗណាស់ ។ នេះសូមបញ្ជាក់ប៉ុណ្ណេះ ។

[១១:២៧:៣៣]

**ស៖** តើនៅមន្ទីរ ស-២១ មានអង្គភាពនីរសារឬទេ?

**ឆ៖** នៅមន្ទីរស-២១ មាននីរសារតែបួននាក់ទេ ។ សុំទោសមានប្រាំ នីរសារ មិត្តហ៊ុយ មួយទៀត មិត្តហ៊ុយស្រែ នុន ហ៊ុយ ។ នីរសារមិត្តហ៊ុយ មានមួយ នីរសារមិត្តហ៊ី មានមួយ នីរសារខ្ញុំបី ។

ពីរនាក់ដូចខ្ញុំបានរាយការណ៍ជូនលោកចៅក្រមហើយ ឈ្មោះជានីរសាររមែន តែតាមពិតជាស្មៀនអ្នកវ៉ៃម៉ាស៊ីនទេ ឯកសារសម្ងាត់បំផុតនៅលើគេ ។ ហើយម្នាក់ទៀតកំបុតដៃម្ខាង កំបុតដៃស្ដាំ ទទួលចាំទទួលទូរស័ព្ទ ។ នៅចាំទូរសព្ទ័ខ្ញុំហ្នឹង ក្រែងលោមេហៅមក រត់មកហៅខ្ញុំ ហើយនិងរៀបចំផ្ទះសម្បែងឲ្យខ្ញុំ បញ្ជីមួយរយអីហ្នឹង ។ ដូច្នេះ និយាយពីអង្គភាពនីរសារផ្ទាល់តែម្ដងគ្មានទេ មានតែនីរសារបីនាក់របស់ខ្ញុំ នីរសារម្នាក់របស់មិត្តបាំ ហើយនិងនីរសារម្នាក់ទៀតរបស់មិត្ត នុន ហ៊ុយ ។

**ស៖** នៅក្នុងអង្គភាពរដ្ឋបាល និងបុគ្គលិកហ្នឹង លោកបានបញ្ជាក់ម្សាញ់មិញថា ឈ្មោះ ធី តើ ឈ្មោះ ធី ជាអ្នកគ្រប់គ្រងផ្នែកឯកសារនៅក្នុងមន្ទីរ ស-២១ ទាំងមូល?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ជនរងគ្រោះដែលទៅជាប់ទោសនៅទីនោះ ក៏ឯកសារនៅលើ មិត្តធី បុគ្គលិកក៏ឯកសារនៅលើមិត្ត ធី ។ ដូច្នេះឯកសារបញ្ជីមួយរយ ខាងបុគ្គលិក ខាងកាំភ្លើង សុំទោសកាំភ្លើងអាចនៅមិត្តហ៊ុយ ទេ ។ ខាងបញ្ជីមួយរយបុគ្គលិកអីអាចនៅ មិត្តធី ទាំងអស់ ។ នេះខ្ញុំគ្រាន់តែជម្រាបប្រសាសន៍ថា អាច ព្រោះខ្ញុំអត់បានទៅឆែកឆេរគិតគូររឿងបុគ្គលិកអីនេះប៉ុន្មានទេ ។ នេះសូមជម្រាបដោយស្មោះត្រង់ ។ គឺខ្ញុំអត់មានគិតគូររវីរវល់ប៉ុន្មានទេរឿងហ្នឹងនោះ ។

**ស៖** លោកពុំបានដឹងថានៅផ្នែកនេះមានចំនួនមនុស្សប៉ុន្មានទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! រឿងបុគ្គលិកប៉ុន្មាន អ្នកណានៅឯណាខ្លះ ខ្ញុំអត់មានបានគិតគូរចង់ក្ដាត់ចង់ដឹងអីទេ ។ រឿងតែម្យ៉ាងគឺម្ងៃៗគិតតែពីរឿងឯកសារ ចារឯកសារ ហើយធ្វើម៉េចឲ្យខាងលើស្រួលមើល ស្រួលយល់ប៉ុននុំងឯង ។ ប៉ុណ្ណឹងហើយនៅចង់រត់មិនទាន់ការងារម្ងៃៗវាស់ល្ងាច ។

[១១:៣០:១៤]

**ស៖** លោកបានបញ្ជាក់អម្បាញ់មិញថា នៅក្នុងអង្គភាពផ្សេងៗនេះមានអង្គភាពចម្លងផែនទី តើអង្គភាពចម្លងផែនទីហ្នឹងសម្រាប់ក្នុងគោលបំណងអ្វីនៅមន្ទីរ ស-២១?

**ឆ៖** ការងារផែនទី វាជាការងារបច្ចេកទេស ។ ខ្ញុំវានៅតែមានចិត្តស្រឡាញ់ការងារបច្ចេកទេសហ្នឹង ។ ដូច្នេះ យកផែនទីមកចម្លង ដាក់ *មេអុង* ពីក្រោមពីរអ៊ីចឹងទៅ តុដាក់កម្រាលកញ្ចក់ កញ្ចក់ថ្លាដាក់ផែនទីខ្នាតមួយភាគហាសិបពាន់ពីលើនោះទៅ ហើយដាក់ក្រដាសយើងពីលើទៅទៀត ឃើញហើយយកខ្មៅដៃគូសតាម ។ ការចម្លងផែនទីនេះមុនដំបូងវាជាការបង្រៀនឲ្យបុគ្គលិកនៅនោះ វាចេះចម្លងផែនទី ។ ដល់ក្រោយមកដល់ខាងលើដឹង ប្រើឲ្យខ្ញុំចម្លងផែនទីខ្លះសម្រាប់យកទៅឧទ្ទេសនាមពេល

រៀនវគ្គ ។ ជាពិសេសគឺបង ប៉ុល ហ្នឹង ប៉ុល ពត ហ្នឹង លេខាហ្នឹង ប្រើឲ្យ ប៉ង់ មកប្រើឲ្យមន្ទីរស-២១ ធ្វើអាហ្នឹង ។ ម្ល៉ោះហើយមន្ទីរស-២១ ចម្លងទាំងផែនទី ធ្វើទាំងក្របផែនទី ដាក់ទាំងផ្លាស្ទិកពីក្របក្រៅផែនទីទៀតដាក់ឡានយកទៅ ឲ្យ ប៉ង់ គេដាក់ឡានយកទៅ ។ ដូច្នេះ មុនដំបូងវាគ្រាន់តែជាការបង្រៀនឲ្យបុគ្គលិកមន្ទីរស-២១ ចេះបច្ចេកទេស ស្គាល់បច្ចេកទេសផែនទីប៉ុនន៎ុងឯង ។ ហើយដល់ក្រោយមក ប៉ុល ពត ប្រើបណ្ដោយ ។ នេះសូមបញ្ចប់ប៉ុណ្ណេះ ។

**ស៖** សូមមន្ត្រីតុលាការបង្ហាញឯកសារលេខ ០០១៥៤២២៩ ។

សូមលោកបញ្ជាក់មកមើលថា អង្គការលេខ លើកទីមួយរបស់ ស-២១ និងអង្គការលេខលើកទីពីររបស់ស-២១ មានភាពខុសគ្នាដូចម្ដេច? ហើយមូលហេតុអ្វីចាំបាច់មានការផ្លាស់ប្ដូរអង្គការលេខនេះ?

**ឆ៖** លោកចៅក្រមជាទីគោរព! ការផ្លាស់ប្ដូរអង្គការលេខនេះ គឺដោយសារខាងលើសម្រេចឲ្យចាប់មិត្តហ៊ុយ នុន ហ៊ុយ នៅខាងស្រែ ទៅតាមបាតុភាពដែលស-២១ រាយការណ៍ ។ ដល់ពេលចាប់ក្បាលម៉ាស៊ីនដឹកនាំនៅស្រែ ខ្ញុំពិគ្រោះគ្នាឯកភាពជាមួយហ្នឹងមិត្តហ៊ ដាក់មិត្តផល ទៅជំនួសមិត្ត ហ៊ុយ នុន ហ៊ុយ ។ ដល់មិត្ត ផល ចេញផុតទៅ ត្រូវមិត្តប៉េង ឡើងកាន់កាប់កិច្ចការយោធាអង្គភាពយោធាទាំងមូលនៅ ស-២១ ឡើងមួយថ្នាក់ មិត្តប៉េង គាត់ឡើងមួយថ្នាក់ ។ ឯចំណែកមិត្ត ផល ទៅនៅស្រែ ផ្ដាច់មុខ ។ នេះ មិត្តផល នៅព្រៃសផ្ដាច់មុខហើយ ទទួលភារៈអប់រំកែប្រែយុទ្ធជនសេរី យុទ្ធជនល្មើសវិន័យ បង្កបង្កើនផល ហើយនិងដាំបន្លែបង្កាចិញ្ចឹមអង្គភាពខ្លួនឯងឯណោះ ។ បង្កើនផលនេះបានន័យថា ធ្វើស្រែ ។

មិត្តផល នេះសូមបញ្ជាក់ម្ដងទៀត មិនមែន ផល ម-១៣ ដែលយើងខ្ញុំបានកម្ទេចទៅហើយនោះទេ គឺជាមិត្តផល កម្មាភិបាលរបស់៧០៣ ។ គាត់នៅរស់រហូត ដល់ក្រោយមកចេញទៅជនបទទៅក្រោយ៧មករា ដឹកនាំទ័ពម៉ាភូមិ ម៉ាអង្គភាព ។ ខ្ញុំប្រគល់ជូនតាម៉ុក តាមសំណូមពរគាត់ ។ គឺមិត្តផល នាំទៅ នេះសូមបញ្ជាក់ប៉ុណ្ណឹង ។

[១១:៣៥:៣៤]

ឥឡូវត្រឡប់មកវិញ ដែលលោកចៅក្រមសួរថាខ្ញុំមាន អ៊ំន៉ែសួរថា ប្លែកអីបានជាត្រូវការធ្វើអង្គការលេខថ្មី ប្លែកនៅហ្នឹងនៅហ្នឹងត្រង់នៅខាងព្រៃស ពីដើមមិត្ត នុន ហ៊ុយ ទទួលខុសត្រូវ ដល់ចាប់គាត់ទៅឡើងមិត្តផល ទទួលខុសត្រូវ ។ សូមបញ្ជាក់ថា ចាប់មិត្ត នុន ហ៊ុយ បើតាមខ្ញុំចាំមួយខែគត់ មុនយួន មកដល់ មុនវៀតណាមចូលមកដល់ គឺចាប់នៅថ្ងៃ៧ ធ្នូ ៦ ឬ៧ ធ្នូ ១៩៧៨ មួយខែ ។ ដូច្នេះ ចាត់

ចែងបានអ៊ីចឹង ។ នៅពេលដែលឲ្យមិត្តផល ទៅនេះ ខ្ញុំមិនប្រគល់ការងារនៅខាងស្រែនេះទៅឲ្យមិត្តហ៊ី ផ្ទាល់ទៀតទេ ខ្ញុំចុះទៅផ្ទាល់ ។ នេះដ្យារក្រាមនេះបញ្ជាក់ថា ខ្ញុំចុះទៅផ្ទាល់ នៅខាង មិត្តផល នេះ ដ្យារក្រាមនេះបញ្ជាក់ថាខ្ញុំចុះទៅផ្ទាល់ មិត្តផល ត្រូវឡើងមកខ្ញុំផ្ទាល់ ។

ការរៀបចំរចនាសម្ព័ន្ធប្រែប្រួលបែបនេះ ខ្ញុំបានរាយការណ៍ជូន ពូនួន ដែរ គឺ នួន ជា គាត់ អនុម័តតាមសំណូមពរ ។ ដោយឡែកខាងនៅភ្នំពេញ កិច្ចការនៅភ្នំពេញប្រគល់ឲ្យមិត្តហ៊ី ទាំងស្រុង ។ ពីដើមមិត្តហ៊ី មានទោសដោយគាត់ធ្វើឲ្យបែកការណ៍ រឿងមានចម្លើយឆ្លើយដាក់ បងភឹម លេខាភូមិ ភាគបូព៌ាហ្នឹង គាត់ធ្វើឲ្យបែក ។ មេដឹង មេហាមមកខ្ញុំមិនឲ្យមិត្តហ៊ី ដឹងកិច្ចការសម្ងាត់ទេ ។ ប៉ុន្តែឥឡូវ នេះរឿងបងភឹមហ្នឹងវាបែកខ្ចាត់ខ្ចាយ ហើយបងភឹម ក៏គាត់ស្លាប់ទៅហើយ ខ្ញុំដាក់មិត្តហ៊ី ឲ្យទទួលខុស ត្រូវនៅភ្នំពេញគ្រប់បញ្ហា ខុសត្រូវនៅភ្នំពេញគ្រប់បញ្ហា ។

ដូច្នេះ អង្គការលេខនេះ វាមកបង្ហាញឲ្យឃើញហើយ គ្រប់រឿងគ្រប់រ៉ាវនៅភ្នំពេញ ឆ្លងតាម មិត្តហ៊ី គ្រប់រឿងរ៉ាវនៅព្រៃស ឆ្លងតាមខ្ញុំ ។

គោលបំណងខ្ញុំមិនមែននៅត្រឹមប៉ុណ្ណេះទេ គោលបំណងខ្ញុំចង់ដកខ្លួនថយចេញពីស-២១ ដែរ បានជាខ្ញុំចាត់តាំងអ៊ីចឹង ។

សូមបញ្ជាក់ថា ខ្ញុំអត់មានចិត្តចង់ធ្វើនគរបាលទេ ។ អង្កាល់ពីក្រោយថ្ងៃ៣០ មេសា ក៏ខ្ញុំបាន សុំបង ចេង អន ទៅខាងឧស្សាហកម្ម ។ តែបក្សមិនព្រម អចិន្ត្រៃយ៍មិនព្រម បង សុន សេន មិនព្រម និយាយឲ្យចំគឺ បង សុន សេន ទេគាត់មិនព្រម ។ ដល់ក្រោយមក គេដក ណាត ចេញ ខ្ញុំសុំឲ្យឆាយ គឹមហ៊ី មកធ្វើប្រធានស-២១ ជំនួស ណាត ។ លោកគ្រូ សុន សេន គាត់កំហែងខ្ញុំ “យើ! ឌុច ស-២១ ហ្នឹងវាធំប៉ុនណា?” ខ្ញុំលែងហ៊ានមាត់ ។ ដល់ពេលនេះ ដល់ពេលឆ្លៀតឱកាសនេះ ដែលខ្ញុំចាប់មិត្តហ៊ុយ ចាប់អីទៅ ខ្ញុំប្រគល់ឲ្យមិត្តហ៊ី ហើយ ខ្ញុំស្នើសុំ ពូ នួន “ថាខ្ញុំចង់សុំ ស្នើសុំឲ្យមិត្តហ៊ី ទទួលខុសត្រូវស-២១ទាំងមូល” ។ ពូនួន គាត់កំហែងខ្ញុំទៀត នេះគាត់នៅទេ ពូ នួន នួន ជា ។ ពូ នួន នោះគឺ នួន ជា ។ គាត់ថា “មិត្តកុំភ្លេចណ៎ា ប្រធានស-២១ គឺខ្ញុំ!” ពូ នួន គាត់មានប្រសាសន៍អ៊ីចឹង ។ ខ្ញុំថាចប់ ស្នើដកខ្លួន ថយអត់រួចទេ នេះខ្ញុំសូមប្រវត្តិ ។

ដូច្នេះ ការរៀបចំអង្គការលេខបួរបែបនេះ នេះគឺ ទិសបំណងរបស់ខ្ញុំ គឺសុំចង់ដកខ្លួនថយ ហើយ ម៉្យាងទៀត ខ្ញុំព្រួយបារម្ភខ្លួនខ្ញុំ មិនដឹងជាថ្ងៃណានឹងផុតអនាគតគេ គេចាប់ និយាយឲ្យត្រង់ ព្រលឹងចុង សក់ហើយពេលហ្នឹង នេះសូមបញ្ជាក់យោងទៅម្តងទៀត ដល់រឿងអតីតកាល ។

[១១:៤០:០៥]

**ស៖** សូមវិលទៅក្រោយបន្តិចគឺថា នៅថ្ងៃទី២៣ ខែ៤ ២០០៩ នោះ លោកបានឆ្លើយថា អង្គការលេខនេះ គឺលោកជាអ្នករៀបចំផ្ទាល់ ហើយពុំមានឥទ្ធិពលពីអ្នកណាទេ តែចម្លើយរបស់លោក នៅចៅក្រមស៊ើបអង្កេតថា អង្គការលេខនេះត្រូវបានសម្រេចដោយថ្នាក់លើ ។ តើចម្លើយមួយណាដែល មានភាពត្រឹមត្រូវដោយយោងលើឯកសារ០០១៥៤២២២ បន្ទាត់ទីពីរ ជាឯកសារនៃចៅក្រមស៊ើប អង្កេត?

**ឆ៖** ខ្ញុំជម្រាបប្រសាសន៍លោកចៅក្រម សំណួររបស់លោក ខ្ញុំក្តាប់អត់បានមិនពេញលេញ ទេ ។ ឥឡូវខ្ញុំសុំសាកល្បងឆ្លើយតាមការចងចាំ។ ដែលហៅថាគ្មានឥទ្ធិពលពីអ្នកណា មានន័យថា អង្គការលេខនេះ វាស្របទៅនឹងការចាត់តាំងដែលយើងខ្ញុំ និង មិត្តហ៊ៃ រៀបចំកាលជំនាន់នោះ ដោយ មានការអនុញ្ញាតពីពូ នួន គឺ នួន ជា ។ ដូច្នេះ ដែលហៅថា គ្មានទទួលឥទ្ធិពលពីអ្នកណាគឺអ៊ីចឹង មិនមែន ពូ នួន ថាអ្ហែ មិត្តឯងកុំដាក់មិត្តផល មិត្តឯងដាក់ ម៉ម ណៃ ទៅវិញ អាហ្នឹងគ្មានទេ ។ ពូនួន អត់មាន ប្រសាសន៍អ៊ីចឹងដាក់ខ្ញុំទេ គឺការដែលដាក់មិត្តផល ព្រោះគេជាកងទ័ព កម្លាំងគេនៅនោះ លោកចៅក្រម ជ្រាបហើយ ប៉ុន្មានរយ ។

ដូច្នេះ ពាក្យថា គ្មានឥទ្ធិពលពីអ្នកណា គឺអង្គការលេខនេះ វាស្របទៅនឹងការចាត់តាំងដែល យើងខ្ញុំទាំងពីរនាក់ទទួលគិតគូរទាំងអស់គ្នាស្មើភាពគ្នា រៀបចំដាក់មិត្តផល ជំនួសមិត្តហ៊ុយ ។ ដូច្នេះ គ្មានការបង្ខិតបង្ខំរបស់ ពូនួន ទេ ។ ក៏ប៉ុន្តែយើងខ្ញុំធ្វើហើយរាយការណ៍ជូន ពូនួន ។ ពូនួន យល់ស្រប ។ នេះ ខ្ញុំសូមបញ្ជាក់ឡើងវិញតាមសភាពការណ៍ពិត ដែលយើងខ្ញុំ ដែលខ្ញុំបាទនៅចងចាំ ។

[១១:៤២:៤៦]

**ស៖** តើអង្គការលេខទាំងមួយ និងទីពីរនេះ មានសម្រេចពីថ្នាក់លើមកទេ?

**ឆ៖** មិនសម្រេចល្អិតទេ ជម្រាបប្រសាសន៍លោកចៅក្រម ដែលសម្រេចល្អិតតែការតែងតាំង មិត្តផល ជំនួស មិត្តហ៊ុយ ។ នេះគឺសម្រេចច្បាស់ពីថ្នាក់លើ ។ មុននឹងយកទៅស្នើគឺយើងខ្ញុំពីរនាក់ ឯកភាពគ្នាក្នុងគណ:កម្មាធិការរបស់យើងខ្ញុំ ។

**ចៅក្រម យ៉ា សុខន៖**

ជម្រាបលោកប្រធាន ខ្ញុំអស់សំណួរហើយ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការដាក់ឯកសារ ០០០១៥៣៦៧ បញ្ចាំងនៅលើកញ្ចក់ទូរទស្សន៍ ។

**ស៖** ជនជាប់ចោទពិនិត្យឯកសារនេះមើល ថាតើឯកសារនេះ ជាឯកសារដែលលោកគូរជូនដល់ចៅក្រម សហចៅក្រមស៊ើបអង្កេត ក្នុងកំឡុងពេល ស៊ើបអង្កេតពិតមែនដែរឬទេ?

**ឆ៖** លោកប្រធានជាទីគោរព! ឯកសារនេះពិតជាខ្ញុំបាទគូរដោយដៃខ្លួនឯង ជូនសហចៅក្រមស៊ើបអង្កេត ជម្រាបប្រសាសន៍ ។

**ស៖** លោកអាចបង្ហាញបានទេ នៅចំណុចនានា ដែលមាននៅក្នុងផែនទីនេះ ដែលមានជាការិយាល័យ ជាផ្ទះ សម្រាប់ឃុំខ្លួនសួរចម្លើយ ជាដើម ហើយដូចជាផ្ទះរបស់លោកអីនៅកន្លែងណា? ហើយអម្បាញ់មិញ គឺលោកឆ្លើយនឹងសំណួរ យ៉ា សុខន ដូចមានការទាក់ទិនជាមួយនឹងចំណុច *អ៊ែ "R"* ដែលលោកបានលើកឡើង ហើយលោកបញ្ជាក់ថា បច្ចុប្បន្ន គឺប៉ុស្តិ៍វិទ្យុសំបុកឃ្មុំជាដើម ។ លោកអាចបង្ហាញចំណុចទាំងអស់នេះក្បោះក្បាយបានទេ នៅលើផែនទី ដែលបានគូរដោយលោកកន្លងមកនេះ ។

**ឆ៖** សូមគោរព លោកប្រធាន ។ ដំបូងខ្ញុំសូមអរគុណលោកប្រធានដែលបានលើកសំណួរនេះឡើងវិញម្តងទៀត ព្រោះថ្ងៃដំបូងដែលយើង ខ្ញុំបាទរាយការណ៍លោកប្រធាន លឿនពេក ។ នេះចំណុច *"A"* ។ ចំណុច *A* នេះដើមឡើយជាកន្លែងយកមនុស្សមួយចំនួនតិច មកឃុំឃាំងនេះ នៅហ្នឹងផ្ទះជ្រុងនេះ ហើយសួរចម្លើយ គឺជ្រុងផ្លូវលេខ៣៦០ និងផ្លូវលេខ១៦៣នេះ សួរចម្លើយ ។ ឯចំណែក កងការពារ អំអ្នកសួរចម្លើយនេះ នៅជួរនេះ មិនដឹងផ្លូវលេខប៉ុន្មានទេ ។ ជួរខាងក្រោមខាងក្រោមបន្តិច ហ្នឹងៗកងការពារនៅនេះ ។

[១១:៤៦:២៤]

ពេលនោះខ្ញុំបាទមិនទាន់ការប្រពន្ធនៅឡើយទេ ខ្ញុំបាទនៅផ្ទះលេខ១នេះ ។ ផ្ទះលេខ១នេះ បើតាមចាំគឺ ផ្លូវលេខ១៤៣ ដែលខ្ញុំរាយការណ៍ជូនលោកចៅក្រមម៉្ងៃណោះថាជាផ្ទះចាស់របស់ឧត្តមសេនីយ៍ជា គឹមអេង ដែលជួលឲ្យ*យូអិនឌីភី (UNDP)* នេះ ។ នេះ ណាត គេឲ្យខ្ញុំនៅហ្នឹង ។ អ្នកទោសនៅជ្រុងកាច់ជ្រុងផ្លូវលេខ១៦៣ និង៣៦០ សួរចម្លើយនៅនេះ ។ ពេលនោះខ្ញុំស្មានថា អ្នកទោសមានតែប៉ុនហ្នឹងឯង ប៉ុនដល់មើលត្រឡប់ទៅក្រោយវិញតាមឯកសារដែលនៅសល់ខ្លះឥឡូវនេះ អ្នកទោសភាគច្រើននៅគុកតាខ្មៅឯណោះទេ គេយកមក ។

ដល់មួយសន្ទុះ ដូចខ្ញុំបាទរាយការណ៍ជូនលោកចៅក្រមហើយ ណាត គាត់ប្តូរកន្លែងសួរចម្លើយ

និងបង្រៀនស្លូរចម្លើយទៅនៅនាយកដ្ឋាននគរបាលជាតិ ដែលភាសាសាមញ្ញហៅថា *ប៉េហ្ស៊ី “PJ”* នោះ តាមផ្លូវប៉ាស្ទ័រ ផ្លូវលេខ៥១ ។ យើងអត់មានផែនទីទេ ។ ពេលនុ៎ង ណាត គាត់អត់ឲ្យខ្ញុំនៅក្នុងបរិវេណដីនេះទៀតទេ គាត់ឲ្យខ្ញុំទៅនៅផ្ទះលេខ២ ។ ខិតទៅក្រោយ សុំទោស សុំៗខិតទៅក្រោយបន្តិច លោករតនៈ បាន ។ ផ្ទះលេខ២ នេះបើមិននៅផ្លូវលេខ៣០២ នៅផ្លូវ៣០៦ ខ្ញុំភ្លេចផ្លូវ ។ ពេលដែលកន្លែងស្លូរចម្លើយ និងបង្រៀនស្លូរចម្លើយ នៅប៉េហ្ស៊ី ណាត គាត់ឲ្យខ្ញុំនៅផ្ទះលេខ២ ។ ខ្ញុំបានជម្រាបជូនពីលើកមុនហើយ ផ្ទះលេខ២ នេះ ជាវីឡារបស់ ដុកទ័រ មី សាមីឌី ។

ដល់ក្រោយមកមេដេញចេញពីប៉េហ្ស៊ី ឲ្យត្រឡប់មកវិញ ។ ខ្ញុំឈប់នៅផ្ទះលេខ២ ដែរ ខ្ញុំដាក់ជនរងគ្រោះ ស្លូរចម្លើយនៅកន្លែងដដែល គឺកន្លែង *A* ក៏ប៉ុន្តែផ្ទះរបស់ខ្ញុំឈប់នៅហ្នឹង ហើយ ខ្ញុំមកនៅលេខ៣ ។ នេះមិនមែនផ្ទះទៀតគឺ ការិយាល័យ ។ ពេលហ្នឹងខ្ញុំរៀបការប្រពន្ធហើយ ខ្ញុំអត់ឲ្យការិយាល័យខ្ញុំហើយនិងផ្ទះគ្រួសារនៅជាមួយគ្នាទេ ។ ខ្ញុំនៅផ្ទះលេខ៣ ជាផ្ទះតៀម ផ្ទះល្វែង ផ្ទះតៀម ពីដើមគេហៅថា ផ្ទះល្វែង ឥឡូវហៅថា ផ្ទះតៀម នេះ លេខ៣នេះ ។

រូបថតខ្ញុំដែលថតជាមួយមិត្តសុខ ហ្នឹងគឺនៅនឹងវេរ៉ង់ដា ផ្ទះលេខ៣ហ្នឹងឯង ។ ឯចំណែកផ្ទះខ្ញុំនៅនេះ ផ្លូវឯណោះទេ ។ អានេះការិយាល័យខ្ញុំ ។ ដល់នៅបានមួយសន្ទុះ ខ្ញុំសម្រេចចិត្តរើកន្លែងឃុំឃាំង និងស្លូរចម្លើយមកដាក់នៅ “B” គឺនៅបរិវេណ ដីរបស់វិទ្យាល័យពញាយ៉ាត ដើម្បីស្រួលឃុំឃាំងផង ស្រួលការពារកុំឲ្យទោសរត់ផង អីផង វានៅប្រមូលផ្តុំនេះស្រួល ។ ខ្ញុំសម្រេចយកន្លែងហ្នឹង ហើយខ្ញុំសូមអនុញ្ញាតមេ ។ ដូចបានរាយការណ៍ជម្រាបលោកចៅក្រមពីមុនហើយ ។ ក៏ប៉ុន្តែនៅខាងត្បូង កន្លែងនេះនៅតែជាគុកពិសេស មិត្តប៉ុន ស្លូរចម្លើយនៅតែជាគុកពិសេសហ្នឹង នៅខាងត្បូង *“B”* ហ្នឹង ។ មិនមែននៅខាងក្នុងទេ ។ កន្លែងហ្នឹងហើយដែលខ្ញុំបានជម្រាបលោកចៅក្រម យ៉ា សុខន អម្បាញ់មិញថា ពួកកងពិសេសយាមនៅទីហ្នឹង ។

[១១:៥០:១៦]

ហើយនិយាយពីផ្ទះ និងការិយាល័យខ្ញុំបាទ ចេះតែប្តូរ ម្តងទៅនេះ ម្តងទៅនោះរហូតដល់ទី៧ ។ អា *អេស.អឹម “SM”* នេះៗ ដែលខ្ញុំ *“SM”* នេះ ជាផ្ទះបាយរួមរបស់យុទ្ធជន និងកម្មាភិបាលហូបបាយនៅហ្នឹង ។ *“R”* នេះ ខ្ញុំអាចសរសេរច្រឡំផ្លូវដែរក៏ថាបាន ។ *“R”* នេះជាកន្លែងដែរ មិត្តហ៊ុយទទួលឡានដែលគេដឹកជនរងគ្រោះមក បញ្ជូនមក ស-២១ មកឲ្យជាប់គុកនៅ ស-២១ នេះ *“R”* នេះ ។ ហើយដល់ពេលដែរ-- ខ្ញុំមិនដឹង *“R”* នេះជាស្អីទេ ។

នៅពេលដែលតទល់គ្នាលើកមុន មិត្តហ៊ុយ និយាយសំបុកឃ្មុំចុះ សំបុកឃ្មុំឡើង ខ្ញុំដឹងថាអ៊ំអាកន្លែង *"R"* ដែលខ្ញុំសរសេរហ្នឹង ឥឡូវនេះគេដាក់ទៅជាស្ថានីយវិទ្យុសំបុកឃ្មុំស្អីគេនោះហើយ នេះ អក្សរ *"R"* នេះ ។ បន្ទាប់មកទៀត ខ្ញុំចេះតែផ្លាស់ប្តូរផ្ទះហើយ ទីតាំងរបស់គុក ហើយនឹងទីតាំងកន្លែងសួរចម្លើយអត់ប្តូរទេ ខ្ញុំសុំគាត់ផ្លាស់ប្តូរផ្ទះរបស់ខ្ញុំ ។ រហូតទៅដល់ចុងក្រោយបំផុត ហើយខ្ញុំនៅឃ្ងរជាងគេ គឺផ្ទះដែល ខ្ញុំដាក់លេខ៧ នៅតាមផ្លូវព្រះមុនីវង្ស ។ នេះលេខប្រាំពីរព្រីម(៧') ហើយសាលានយោបាយរបស់ ស-២១ ខ្ញុំដាក់លេខ *អ៊ី(E)* នេះ អាលេខ៧នេះ ការិយាល័យរបស់ខ្ញុំនេះ ។

ដូច្នេះខ្ញុំសូមរាយការណ៍លម្អិតសារឡើងវិញជូនលោកប្រធាន សូមជម្រាបប្រសាសន៍ប៉ុណ្ណេះ ។

**ស៖** មកខាងកែងផ្លូវលេខ១៦៣ ជាមួយនឹង៣៦០វិញ ចំណុច *"A"* ។ បង្ហិលៗផែនទីឲ្យដល់ចំណុច *"A"* ។

នៅលើផែនទីនេះមានចំណុច *អ៊ីអ៊ី(EE) អ៊ី*ពីរ *(EE)* ។ បារាំងគឺ *អ៊ី*ពីរ(EE) ហើយ អង់គ្លេសគឺ *ដាប់ប៊ែលអ៊ី* ចំណុចនេះជាចំណុចទីតាំងអីទៅ? ត្រង់ចំណុចនេះ ។

**ឆ៖** លោកប្រធានជាទីគោរព! សូមគោរពរាយការណ៍ជូនថា *"EE"* នេះ ដើមឡើយជាវិហារ *ប្រូតេស្តង់* ឈ្មោះវិហារ បាត់ទន្លេហ៊ីម ។ ដំបូងខ្ញុំបាទយកចំណុចនេះ ធ្វើជាកន្លែងអប់រំនយោបាយយុទ្ធជនកម្មាភិបាលរបស់ ស-២១ ។ ដល់ខ្ញុំបាទ បានធ្វើសាលានៅ *"E"* នៅត្រង់ផ្លូវលេខ ៣០៥ មិញក្បែរផ្ទះខ្ញុំលេខ៧ អាកន្លែងនេះជាកន្លែងចម្លងផែនទី ។

**ស៖** ចុះចំណុចក្បែរហ្នឹង ដូចជាត្រង់ចំណុចលេខ១, លេខ២, លេខ៣ ហើយនិង លេខ៣*ព្រីម* (៣') អាហ្នឹងជាចំណុចសម្រាប់ធ្វើអ្វីទៅ? ជាផ្នែកមួយនៃមន្ទីរ ស-២១ ដែរឬទេ?

[១១:៥៣:៣១]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន មួយនេះ គឺជាផ្ទះ និងជាការិយាល័យដំបូងបំផុតរបស់ខ្ញុំដែលខ្ញុំបានរាយការណ៍ជូនថា ជាផ្ទះចាស់របស់ឧត្តមសេនីយ៍ ជា គឹមអេង ។ ពីរ ជាផ្ទះនិងជាការិយាល័យរបស់ខ្ញុំបាទ នៅពេលដែលទីតាំងសួរចម្លើយនៅ *"PJ"* គឺជាវីឡាចាស់របស់ ដុកទ័រ មី សាមីឌី ។ បី គឺជាការិយាល័យរបស់ខ្ញុំបាទ នៅពេលដែលកន្លែងសួរចម្លើយត្រឡប់មក *"A"* វិញ ។ ក៏ប៉ុន្តែ ផ្ទះពេលនោះខ្ញុំបានរៀបការជាមួយប្រពន្ធហើយ ប្រពន្ធមកពីអន្លង់វែងមកនៅជាមួយខ្ញុំហើយ ។ ខ្ញុំផ្ទះ--ជាមួយនឹងប្រពន្ធនៅផ្ទះលេខ៣' នេះទេ ។ ការិយាល័យនៅលេខ៣ ផ្ទះខ្ញុំបាទនៅលេខ៣' នេះ ផ្លូវ ១៦៣ អ៊ូ! ត្រូវហើយផ្លូវ១៦៣ ។

**ស៖** អ៊ីចឹងបានសេចក្តីថា ចំណុចទាំងអស់នេះ គឺជាចំណុចពីមុនគឺលោកធ្លាប់រស់នៅទីនោះ ហើយក្រោយពេលលោកចាកចេញ លោកបានកែប្រែទីនោះទៅជាកន្លែងធ្វើការងារ សម្រាប់ធ្វើការងារ ដូចជាឃុំឃាំង ហើយនិងសួរចម្លើយអ្នកទោសនៅក្នុងអំឡុងពេលនៃមន្ទីរស-២១ នៅចំណុច *"A"* ។ ពិតអ៊ីចឹងទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ផ្ទះលេខ១ អត់មានអ្នកណាទៅសួរចម្លើយនៅនោះទេ ។ ផ្ទះលេខ២ ប្រគល់ទៅឲ្យលោកតា ប៉ែន នុត ។ កាលនោះខាងលើគេទាញ គេទាមទារយកផ្ទះហ្នឹងទៅប្រគល់ជូនលោកតា ប៉ែន នុត ។ គេដេញខ្ញុំចេញ អ្នកអចិន្ត្រៃយ៍នោះ ដេញខ្ញុំចេញ ។ ហើយផ្ទះលេខ៣ នេះ ខ្ញុំចេញទៅក៏នៅតែទុកចោល ជាផ្ទះល្វែងដែលទុកចោល ។ ផ្ទះល្វែង៣' ខ្ញុំចេញទៅក៏នៅតែវីឡាមួយដែលទុកចោល ។ ឯចំណែកកន្លែងសួរចម្លើយចេញពី *A* ទៅ *PJ*, មកពី *PJ* មក *A* វិញ ហើយបានចេញពី *A* ទៅចូល *B* ។

**ស៖** បង្វិលមកខាងកើតវិញ មកជិតផ្លូវព្រះមុនីវង្ស ។ ចុះចំណុចផ្សេង ដូចជាលោកសរសេរដាក់នៅចំណុចមានលេខ៦, លេខ៦*ព្រីម*(៦') ហើយលេខ៥, លេខ៥*ព្រីម*(៥') លេខ៤, លេខ៤*ព្រីម* (៤') នេះជាទីតាំងសម្រាប់ធ្វើអ្វីទៅ?

[១១:៥៦:១៦]

**ឆ៖** លោកប្រធានជាទីគោរព ពាក្យ *"ព្រីម"* នេះ ដែលខ្ញុំដាក់ គឺសំដៅផ្ទះដែលនៅ ។ ឯចំណែកពាក្យដែលអត់ *"ព្រីម"* គឺជាការិយាល័យ ។ នៅពេលដែលការិយាល័យខ្ញុំនៅលេខ៤ ផ្ទះជាមួយនឹងប្រពន្ធនៅលេខ៤' ។ ពេលដែលការិយាល័យខ្ញុំលេខ៦ ។ លេខ៦' ជាផ្ទះនៅ ។ សូមបញ្ជាក់ថា អាការិយាល័យលេខ៦ នេះក្រោយមកខ្ញុំប្រគល់ឲ្យបង ម៉ម ណៃ សួរចម្លើយវៀតណាមនៅហ្នឹង ។ អាលេខ៦នេះ កន្លែងសួរវៀតណាមហើយ ។ អាលេខ៥ ជាការិយាល័យរបស់ខ្ញុំ ហើយលេខ៥' ជាផ្ទះនៅ ។ លេខ៧ ជាការិយាល័យរបស់ខ្ញុំ លេខ៧' ជាផ្ទះនៅ ។ សូមបញ្ជាក់ថា លេខ៧' នេះ ជាកន្លែងដែលគេបញ្ជូន កុយ ធួន មកឲ្យចាប់ ។ សូមបញ្ជាក់ថា លេខ៧នេះ ជាកន្លែងដែល ពូ នួន គាត់ឲ្យ ប៉ង់ ដើរមកចូលមកនៅកន្លែងនេះ ឲ្យខ្ញុំចាប់ ពីរនាក់មិត្តហ៊ា ។

**ស៖** ក្នុងរចនាសម្ព័ន្ធនៃស្ថាប័នរដ្ឋ មន្ទីរស-២១ នេះ តើស្ថិតនៅក្នុងអង្គភាពណា? នៅក្នុងក្រសួងណា? ក្រសួងការពារជាតិ ឬក៏ក្រសួងស៊ីវិល បានន័យថា ផ្នែកខាងជាស៊ីវិល ឬក៏ផ្នែកខាងសន្តិសុខ?

**ឆ៖** លោកចៅក្រមជាទីគោរព! ក្នុងការអនុវត្តជាក់ស្តែង ស-២១នេះជើងពីរៗ ដែលខ្ញុំបានរាយការណ៍ជម្រាបថា ជើងពីរ ជាអង្គភាពខាងសេនាធិការ វាមានតម្លៃជាវរសេនាធំឯករាជ្យ ។ ភស្តុភារក៏ទៅបើកពីសេនាធិការ បញ្ជើកម្លាំងក៏បើកខាងសេនាធិការ ផែនការបង្កបង្កើនផលស្រូវក៏ទៅទាក់ទងនឹងខាងសេនាធិការ ពេទ្យក៏រត់ទៅរកសេនាធិការ ។ ទាំងអស់សុទ្ធតែនៅលើសេនាធិការ ។ បន្ថែមពីនោះទៅទៀត ការរៀនសូត្រប្រចាំឆ្នាំ ដែលខាងលើហៅខ្ញុំបីនាក់ទៅ ខ្ញុំ មិត្តហ៊ិ និងមិត្តហ៊ុយ គឺទៅរៀនក្រោមការខទ្ទេសនាមរបស់សេនាធិការ រហូតៗដល់ឆ្នាំ១៩៧៧ រៀនជាមួយសេនាធិការរហូតនេះជើងម្ខាង ។

ឯចំណែកជើងម្ខាងទៀត គឺខាងការងារសន្តិបាល ។ ខាងការងារសន្តិបាល ស-២១ ទទួលមនុស្សតែអចិន្ត្រៃយ៍ផ្តល់ឲ្យ គ្មានអ្នកណាមានសិទ្ធិផ្តល់មនុស្សមកស-២១ បានទេ ។ គឺមានតែខ្ញុំផ្ទាល់ទៅទទួលៗជាបញ្ជី ឬទទួលជាឈ្មោះពីអចិន្ត្រៃយ៍សិន បានខាងក្រោមគេចាត់ចែង ។ នេះទីមួយមនុស្សដែលបញ្ចូលមក ស-២១ ទាល់តែអចិន្ត្រៃយ៍បញ្ជូនមកបានៗទទួលបាន ។ បើអចិន្ត្រៃយ៍មិនបញ្ជូនមកទេទទួលមិនបានទេ ។ ខុស កំបុតក ។

ទីពីរ សេចក្តីរាយការណ៍របស់មន្ទីរ ស-២១ អត់មានសិទ្ធិរាយការណ៍ទៅឯណាបានទេ ។ ទៅកងពលក៏មិនបាន ទៅក្រសួងផ្សេងទៀតក៏មិនបាន ត្រូវតែរាយការណ៍ជូនអចិន្ត្រៃយ៍ ។ ហើយតែរាយ-ការណ៍ខុសពីនេះកំបុតក ។ នេះជាគោលការណ៍ដែលយើងខ្ញុំអនុវត្តនៅពេលនោះ ។ ឯកសារសល់ច្រើនណាស់ដែលបញ្ជាក់បញ្ហានេះ ។ ខ្ញុំបាទក៏មានបំណងសូមរាយការណ៍ជូនលោកប្រធាននៅពេលនេះដែរអំពីឯកសារខ្លះដែលយើងខ្ញុំរាយការណ៍ទៅខាងលើ ដោយត្រង់ទៅអចិន្ត្រៃយ៍ ។ បើលោកប្រធានអនុញ្ញាតខ្ញុំនឹងរាយការណ៍ជូន ។

[១២:០១:២៨]

**ស៖** អង្គជម្រះអនុញ្ញាត សូមលោកជនជាប់ចោទនិយាយមកចុះ អំពីឯកសារទាំងអស់ដែលពាក់ព័ន្ធហ្នឹងរបាយការណ៍នេះ ។

**ឆ៖** ដំបូងខ្ញុំសូមលើកយក សេចក្តីរាយការណ៍របស់ចម្លើយ យី លុយ អំពីសកម្មភាពទាក់ទងរវាង មាន, ផែន និង សុផាន ។ សូមបញ្ជាក់ថា មាន នេះ ចាន់ ចក្រី ។ ផែន គឺ លី ផែល ហើយសុផាន គឺ សួ សុផាន ។ ខ្ញុំរាយការណ៍ឯកសារនេះជូន ដើម្បីបញ្ជាក់ថា គ្រប់ចំណាររបស់ខ្ញុំសុទ្ធតែមានការពិគ្រោះ និងសុំយោបល់មេ ។ ខ្ញុំសូមជូន ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ យើងមើលទៅឯកសារដូចជាមានចំនួនច្រើន ហើយត្រូវការបកស្រាយត្រូវចំណាយពេលវេលាច្រើនប្រហែលមិនអាចបន្តដំណើរការសវនាការទេ គឺត្រូវសម្រាកត្រឹមនេះ ។ ប៉ុន្តែ មុននឹងសម្រាកអង្គជម្រះសូមជម្រាបជូនលោកជនជាប់ចោទថា នៅពេលរសៀល យើងបន្តនឹងអ្វីដែលលោកប៉ុនប៉ងក្នុងការបង្ហាញដល់អង្គសវនាការ អំពីឯកសារទាំងអស់នេះ ។ ប៉ុន្តែ សូមឲ្យការបង្ហាញហ្នឹងមានលក្ខណៈយឺត ហើយនឹងអាននូវឈ្មោះៗអ្នកដែលពាក់ព័ន្ធនៅក្នុងឯកសារហ្នឹងឲ្យបានច្បាស់ ដើម្បីឲ្យអ្នកបកប្រែ និងការកត់ត្រាចូលទៅក្នុងប្រតិចារឹកបានច្បាស់លាស់ ។

អង្គជំនុំជម្រះសូមប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ ហើយអង្គជំនុំជម្រះនឹងបន្តវិញនៅរសៀលនេះវេលាម៉ោងមួយ និងសាមសិបនាទី ។ ហើយសូមអញ្ជើញភាគីទាំងអស់ ដែលមានបំណងចូល ដែលត្រូវចូលរួមក្នុងដំណើរការសវនាការ សូមអញ្ជើញឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់មកកាន់ទីនេះឲ្យបានមុនម៉ោងមួយ និងសាមសិបនាទីរសៀលនេះ ។

*[សវនាការសម្រាកពីម៉ោង១២:០៤ នាទីដល់ម៉ោង ១៣:៣៨ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចពិភាក្សាដេញដោលតទៅទៀត ហើយអនុរក្សមន្ទីរឃុំឃាំងអញ្ជើញជនជាប់ចោទមកកាន់ឈើរាងរង់ក្រចកសេះ ។

**ស៖** ជាបន្តជនជាប់ចោទអាចមានឱកាសលើកឡើងផ្ទុះបញ្ចាំងអំពីឯកសារមួយចំនួន ដែលមានការពាក់ព័ន្ធទៅនឹងរបបរាយការណ៍នៃមន្ទីរសន្តិបាល ស-២១ ទៅនឹងអចិន្ត្រៃយ៍ដែលមានការផ្ទុះបញ្ចាំងសូមអញ្ជើញលោកជនជាប់ចោទ ។

**ឆ៖** លោកប្រធានជាទីគោរព ដំបូងខ្ញុំសូមរាយការណ៍អំពីចម្លើយ យី លុយ ដែលទាក់ទងទៅនឹងឈ្មោះ មាន, ឈ្មោះ ផាន និងឈ្មោះ ផែន ។ ឯកសារនេះនៅត្រង់ D32/4 ដំបូងខ្ញុំចង់រាយការណ៍ត្រង់ចំណុច *ERN* លេខ 00173044 ។ សូមអនុញ្ញាតលោកប្រធានឲ្យគេបញ្ចាំងនៅលើអេក្រង់ ដើម្បី

យើងខ្ញុំបានអធិប្បាយជូន ។

**ស៖** តុលាការចាត់ចែងបញ្ចាំងនូវឯកសារអម្បាញ់មិញនេះ នៅលើអេក្រង់ទូរទស្សន៍ ។

**ឆ៖** លោកប្រធានជាទីគោរព! មុននឹងអធិប្បាយខ្ញុំបាទសូមបញ្ជាក់ថា ជនអ្នកឆ្លើយនេះឈ្មោះ យី លុយ ។ ចម្លើយ យី លុយ ជនអ្នកឆ្លើយនេះឈ្មោះ យី លុយ ជាកម្មាភិបាលយោធាម្នាក់របស់កងពលនៅភូមិភាគបូព៌ា ។ ចម្លើយនេះទាក់ទងដល់ឈ្មោះ មាន ។ មាន នេះឈ្មោះបដិវត្តន៍របស់ ចាន់ ចក្រី ។ មាន ជាឈ្មោះរបស់ ចាន់ ចក្រី, ចាន់ ចក្រី ហៅ មាន, ផែន ជាឈ្មោះបដិវត្តន៍របស់ លី ផែល ហៅ ផែន សេនាធិការយោធាភូមិភាគបូព៌ា និង សុផាន ។ សុផាន នេះ ស្វ សុផាន អនុលេខាកងពល១៧០ ។ រឿងដែលខ្ញុំបាទចង់បញ្ជាក់ គឺរបៀបសរសេរកំណត់ហេតុ របៀបរាយការណ៍ ។ នេះអក្សរខ្ញុំបាទ ។ នេះនៅចុងខាងដើម ខិតមកនេះបន្តិច ខិតមកស្តាំទៀត បាទ ។

នេះអក្សរខ្ញុំបាទហើយ មួយច្បាប់នេះ ខ្ញុំជូនបង ខៀវ ផ្ទាល់ ដើម្បីបងពិនិត្យជាដំបូង ព្រោះយើងខ្ញុំមានចារថែមខ្លះដើម្បីសម្រួល ។ ដោយគោរព ។ នេះអក្សរខ្ញុំរាយការណ៍ទៅជូនព័ត៌មានមេ អំពីសេចក្ដីសារភាពនេះ ខ្ញុំបាទបានចារ បានកែតម្រូវនេះ ។ បានជាខ្ញុំលើកបញ្ហានេះយកមករាយការណ៍ជូនអង្គជំនុំជម្រះនៅពេលនេះចង់បញ្ជាក់ថា ការចារលើកំណត់ហេតុគឺខ្ញុំមានការទាក់ទងជាមួយនឹងមេខ្ញុំរាល់ថ្ងៃ ។

[១៣:៤៣:៥៨]

សូមតទៅមួយទំព័រទៀត គឺនៅទំព័រ 00173044 ឯកសារលេខ D32/4 ដដែល ។ នេះសូមបញ្ចាំងត្រង់កន្លែងមានអក្សរខ្ញុំបានហើយ ។ ទៅលើ ចុះក្រោមបន្តិចមក ទៅខាងស្តាំបន្តិច បាទ ។ នេះអក្សរខ្ញុំហើយ “បងជាទីគោរព!” គឺខ្ញុំសរសេរទៅជូនបង ខៀវ ។ “បងជាទីគោរព!

១) សេចក្ដីសារភាពនេះច្បាស់ជាមូលដ្ឋាន ។

២) រឿងច្របូលប្រចល់មាន គឺវាយកកម្មាភិបាលផ្ទៃក្នុងខ្លះមាន បងសុខ និង បងសៅ ជាដើម ។” បងសុខ មិត្តសុខ នេះលេខា១៧០ ក្រោយពីដក ចក្រី ទៅ យកទៅសេនាធិការថ្កល់ជើងនៅនោះ បក្សលើកបងសុខ នេះឡើងជាលេខា ។ ហើយក្រោយពីចាប់ ស្វ សុផាន ទៅលើក បងសៅ ឲ្យទៅជាអនុលេខា ។ ខ្ញុំសូមអានឡើងវិញ “រឿងច្របូកច្របល់មាន គឺវាយកកម្មាភិបាលផ្ទៃក្នុងខ្លះ មាន បង សុខ និងបង សៅ ជាដើមទៅប្រចូលជាមួយនឹងពួក *សេអ៊ីអា “CIA”* ខ្មែរសេរីបង្កប់ ។”

សូមខិតទៅបន្តិចទៀត ។

"យើងខ្ញុំបានដកឲ្យគេវាយពុំដោយឡែកហើយ តែវាយមិនទាន់ ។" ឌុច ។ នេះស៊ីញ៉េ ខ្ញុំ ។

ដូច្នេះ ការទាក់ទងជាប់លាប់នេះឯកសារខ្លះ ដែលគាត់ត្រូវបន្ទាន់ ខ្ញុំតម្រូវសរសររបៀបនេះជូនគាត់ ព័ត៌មានសព្វបែបយ៉ាង ដើម្បីឲ្យគាត់ម្ចាស់ការក្នុងការយល់ដឹង ។

អ៊ីចឹងសូមបញ្ចប់ការរាយការណ៍ ឯកសារមួយនេះ អំពីរបៀបចារ ។

តទៅទៀត ខ្ញុំសូមអនុញ្ញាតជូនឯកសារលេខ 00204310 *ERN* 00204 លេខ 310 ឯកសារនេះសខ្មៅ មានសភាពព្រិលៗពិបាក ។ ខ្ញុំមានសំណូមពរចង់យកឯកសារពណ៌ បើលោកចៅក្រមអនុញ្ញាត។ លោកប្រធានអនុញ្ញាតសូមមេត្តាជូនជាឯកសារពណ៌ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ។ មន្ត្រីយកឯកសារពីគាត់ដាក់បញ្ចាំង ។

**ជនជាប់ចោទ៖**

**ឆ៖** លោកប្រធានជាទីគោរព! ឯកសារនេះវាបញ្ជាក់ឲ្យឃើញថា ខ្ញុំបានរាយការណ៍ទៅលើ ទៅមេ ។ និយាយឲ្យចំក្នុងដំណាក់កាលទីមួយគឺរាយការណ៍ទៅលោកគ្រូ សុន សេន ។

[១៣:៤៧:៤០]

នេះអក្សរខ្ញុំ៖ បងជាទីគោរព!

១) កម្លាំងដែលវារាយការណ៍ក្នុងនេះសុទ្ធតែជាពួកតំបន់២២ អ៊ីចឹងពួកនៅក្នុងជួរបដិវត្តន៍ទាំងខ្សែកុកម៉េងតាំងចាស់នៅពាវាំង ។

២) កម្លាំងខ្ពស់បំផុតដែលវានិយាយគឺ អាទុំ ។ សូមបញ្ជាក់ថា "កម្លាំងខ្ពស់បំផុតដែលវានិយាយគឺអាទុំ ។ សូមបញ្ជាក់ថា អាទុំ នេះគឺសំដៅបង សៀត ឆែ ហៅ ទុំ ហៅ បង៨១ រងនាយអគ្គសេនា-ធិការ ។ មុននឹងចាប់គាត់ជា អនុលេខាអគ្គសេនាធិការ ។

៣) មិត្ត អ៊ាង ស៊ីផេង ឈ្មោះ ចិន អាណិកជនចិនម្នាក់ ។ វានិយាយថាជាអ្នកបដិវត្តន៍ និយាយជាជំហរវាតែម្តង ។ ឈ្មោះ ឡុង មុយ ហៅ ជួន នេះ ឆ្លើយថា អ៊ាង ស៊ីផេង ជាអ្នកបដិវត្តន៍ទេ គ្មានជាប់ទាក់ទងនឹងខ្សែ *សេអ៊ីអា* អ៊ីនឹងគេទេ" ។

ដូច្នេះ ខ្ញុំរាយការណ៍៣ចំណុចនេះជូនមេខ្ញុំ ។ ទីមួយ កម្លាំងនៅតំបន់២២ គឺនៅពាវាំង ទីពីរកម្លាំងខ្ពស់បំផុតគឺ ពុំ ទីបី អ៊ាង ស៊ីផេង ជាអ្នកបដិវត្តន៍ ។ ខ្ញុំរាយការណ៍ប៉ុណ្ណឹង ខ្ញុំសរសេរ "ដោយគោរព, ឌុច" ហើយខ្ញុំរាយការណ៍នៅថ្ងៃទី១១-- លោក រតន:-- ខ្ញុំរាយការណ៍នៅថ្ងៃទី១៥ ខែ១០

ឆ្នាំ១៩៧៧ ។ នេះអំពីប្រវត្តិសកម្មភាពក្បត់របស់ ឡុង មុយ ហៅ ជួន ។

សូមចុះមកក្រោម បង្ហាញឲ្យឃើញថាលោកគ្រូ សុន សេន មេខ្ញុំ ក្រោយពីបានទទួលឯកសារនេះគាត់សរសេរម៉េច ។

សូមបញ្ជាក់ថា ឯកសារនេះខាងអ្នកសួរគេសរសេរចប់នៅថ្ងៃ០២ ខែ៩ ឆ្នាំ១៩៧៧ នេះ ។ ក្រោយពីបានទទួលបានឯកសារខ្ញុំ មេខ្ញុំលោកគ្រូ សុន សេន សរសេរ៖

១) អាចសំខាន់ដែរ ។ នេះអក្សរលោកគ្រូ សុន សេន ហើយ ។ អាចសំខាន់ដែរ ។

២) អានេះខ្សែអាណិកជនចិនបកប្រែ ។

៣) ខ្ញុំមិនទាន់បានអានទេ សុំជូនបងអានមុន នេះជាពាក្យ សុន សេន និយាយទៅ បង ប៉ុល ជាពាក្យមេខ្ញុំ គាត់និយាយតែបង ប៉ុល នេះស៊ីញ៉េគាត់ ខៀវ ។ គាត់ស៊ីញ៉េនៅថ្ងៃ១៧ ខែ១០ ឆ្នាំ១៩៧៧ ។

សូមតទៅទៀត។ នេះនៅជ្រុងខាងស្តាំ អ៎!ខាងឆ្វេងនេះ ។ ពិសេសខាងសមមិត្ត ខៀវ ទាក់ទងបូព៌ា នេះអក្សរ ប៉ុល ពត ហើយអក្សរបង ប៉ុល ។ ពិសេសខាងសមមិត្ត ខៀវ ទាក់ទងបូព៌ា គឺ ប៉ុល ពត សម្រេចឲ្យ បងខៀវ, សុន សេន នេះ ទាក់ទងប្រាប់ទៅខាងបូព៌ា ឲ្យបូព៌ាគេចាត់ចែងតាមឯកសារហ្នឹង ។ (រួចសុំៗ គ្រឡប់មកនេះវិញ *អាហ្រ្គិស* ខាងចុងនេះ នេះៗ*អាហ្រ្គិស* ខាងចុងនេះ អក្សរ *វេ "V" ហ្រ្គិស* ខាងចុងនេះ អក្សរនេះ)។ គឺសញ្ញា ប៉ុល ពត របស់ ប៉ុល ពត ហើយដែលជាអ្នកធំជាងគេតែអានឯកសារ អ្វីមួយហើយ គាត់*ហ្រ្គិស* នៅខាងចុងបន្តិចហ្នឹង ។

[១៣:៥១:៥៣]

សុំត្រឡប់មកខាងដើមវិញ ដល់បានទទួលបានឯកសារនេះហើយ លោកគ្រូ សុន សេន គាត់សរសេរ "ជូនហើយ" នេះអក្សរគាត់ "ជូនហើយៗ" ១១/ ១១/ ៧៧ ។ នេះអក្សរ សុន សេន គាត់អត់ស៊ីញ៉េអីទៀតទេ ។ ដូច្នេះ បានន័យថាគាត់ជូនឯកសារនេះទៅខាងបូព៌ាហើយ ជូននៅថ្ងៃ ១១/១១/៧៧ ។

ឯកសារមួយនេះវាបញ្ជាក់ថា ខ្ញុំប្រធានមន្ទីរស-២១ រាយការណ៍ត្រង់ទៅលើ ត្រង់ទៅលោកគ្រូ សុន សេន ពីលោកគ្រូ សុន សេន ទៅ ប៉ុល ពត បានពី ប៉ុល ពត បញ្ជាអនុញ្ញាតឲ្យ សុន សេន ទាក់ទងទៅខាងបូព៌ា ។

នេះសូមបញ្ចប់ឯកសារនេះ ។

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាមានការប៉ុនប៉ងលើកឡើងពីបញ្ហាអ្វីទៅ?

**លោក អាឡិចសាន់ឌឺ បេ៊ត៖**

សូមអរគុណលោកប្រធាន ។ យើងមិនមានលេខ *ERN* ទេនៅលើឯកសារនេះ ហើយយើងមិនដឹងថាដកយកពីកន្លែងណា? មើលទៅដូចជាឯកសារនោះវាមានចែងនៅក្នុងកូនសៀវភៅមួយ ។

ដូច្នេះ គឺថាយើងចាប់អារម្មណ៍នឹងរកប្រភពនៃឯកសារនេះយកមកពីកន្លែងណា? ហើយប្រសិនបើមាន លេខ *ERN* ឬក៏លេខឯកសារ សូមអញ្ជើញអានដើម្បីកត់ត្រាឲ្យបានត្រឹមត្រូវ ។

អរគុណ ។

[១៣:៥៣:២១]

**ប្រធានអង្គជំនុំ៖**

ចៅក្រម ខាតវ៉ាយថ៍ សូមអាននូវលេខ *ERN* ជម្រាបដល់អង្គសវនាការទាំងមូលដែលមាននៅក្នុង *ហ្សាយឡេប (Zylab)* ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

គិតថា *ERN* លេខដែលជនជាប់ចោទនឹងគឺ 00204310 ដែលនៅក្នុងទំព័រនោះ គឺជាអត្ថបទសរសេរដៃ ដូចដែលយើងបានឃើញនៅលើ បានបង្ហាញតុលាការ ដោយមន្ត្រីតុលាការនោះ គឺជាផ្នែកនៃជាឯកសារមួយដែលវែង ហើយជាអត្ថបទជាភាសាខ្មែរ ដល់អ៊ីចឹងខ្ញុំមិនអាចពន្យល់អ្វីបានទៀតទេ ។

**លោក អាឡិចសាន់ឌឺ បេ៊ត៖**

លោកចៅក្រម ខ្ញុំមិនដឹងឆ្លើយថា គឺថាមានឯកសារពីរខុសគ្នា ឯកសារទីមួយ គឺឯកសារ ដែលខ្ញុំកត់លេខពីខាងដើមនោះ បញ្ជាក់លេខខាងដើមនោះ សូមទោសខ្ញុំកែខ្លួនឯង ។ ឯកសារទីមួយនោះ គឺសុទ្ធតែឯកសារ ខ្មៅ-ស ឯកសារអម្បាញ់នេះគឺមានពណ៌ តើលេខដូចដែលលោកស្រី ចៅក្រមទើបអានអម្បាញ់នេះ?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ថាមិនមែន គឺថាឯកសារច្បាប់ដើមមិនដឹងថាមកពីណាទេ ព្រោះថានៅក្នុងឯកសារ *ហ្សាយឡេប* នោះ គឺថា ខ្មៅ-ស ដែលមានលេខ *ERN* ខ្ញុំនឹងទៅ-- លេខ *ERN* ដូចដែលខ្ញុំបាន ជម្រាបអម្បាញ់នោះ យើងត្រូវរកថា តើឯកសារដើមជាអក្សរក្រហម ជាកំណត់សរសេរដៃហ្នឹង គឺចេញមកពីណា ដែលមាន

ចំណាវក្រហមហ្នឹង ព្រះរាជអាជ្ញា ។

អរគុណ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ យើងមាន១លេខ *អ៊ីនឌិក D*៩៩/៣ *(Index D99/* III*)* ដោយមានលេខ *ERN* នៅក្នុងខ្មែរ គឺថាមាន 00204310 ហើយនៅក្នុង-- តាមពិតទៅឯកសារនេះ ឯកសារដែលមានពណ៌នេះ គឺត្រូវបានដាក់បញ្ចូល ទៅក្នុងចម្លើយដែលជនជាប់ចោទបានផ្តល់តាមសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយលេខឯកសារនោះ-- បរិបទនៃចម្លើយនោះ គឺថាមានលេខនេះ គឺហៅថា *D55* បាទ *D*៩៩/III ប៉ុន្តែ បីហ្នឹងលេខរ៉ូម៉ាំង ។ បាទ *D93/III* ។ បាទ, ហើយអាបីនៅក្រោមនោះ គឺជាលេខ *អ៊ីនឌិក* គឺថាបីរ៉ូម៉ាំង ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

នៅក្នុង១សំណុំរឿង គឺថាមានឯកសារ ខ្មៅ-ស ទេ ថាតើជនជាប់ចោទ គឺថាអាចលើកឡើងដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើងនោះជាឯកសារពណ៌? ខ្ញុំមិនយល់ទេ ។

[១៣:៥៧:០៩]

**លោកហ្វ្រង់ស្វ័រ រូ៖**

នៅក្នុងការសម្ភាសន៍ជាមួយចៅក្រម យូ ប៊ុនឡេង គាត់បានជូនឯកសារពណ៌នេះទៅឲ្យជនជាប់ចោទ អ្វីដែលបានតែងតែធ្វើឡើងនៅក្នុងដំណាក់កាលស៊ើបអង្កេតដែលថា បានជូនទៅជនជាប់ចោទ ។ អ៊ីចឹងហើយយើងបានទទួលឯកសារជាកូពី ក្រោយមកយើងបានយកមកប្រើដើម្បីបង្ហាញពន្យល់ពីឯកសារ ដើមបណ្តឹងរដ្ឋប្បវេណីបានសួរ ។

ដូច្នេះហើយ យើងបានថាចុះលេខថា *D93/III* ហ្នឹង ។ អ៊ីចឹង សហចៅក្រម យូ ប៊ុនឡេង ដែលបានផ្តល់ឯកសារនេះមកឲ្យយើងនៅក្នុងដំណាក់ស៊ើបអង្កេត ។

**ប្រធានអង្គជំនុំ៖**

ជាបន្ត ជនជាប់ចោទអាចបង្ហាញនូវឯកសារផ្សេងទៀតពាក់ព័ន្ធជាមួយនឹងរបបរបាយការណ៍នៃមន្ទីរស-២១ ជូនទៅអចិន្ត្រៃយ៍នេះ ។

**ជនជាប់ចោទ៖**

**ឆ៖** សូមគោរពលោកប្រធាន! អម្បាញ់មិញ ខ្ញុំបាទបានរាយការណ៍អំពីឯកសារអំពីឯកសាររបស់មន្ទីរស-២១ ដែលជូនទៅអចិន្ត្រៃយ៍ ។ ហើយអចិន្ត្រៃយ៍បានចាត់ចែងបន្តឲ្យចាត់ការទៅខាង ភូមិភាគ ដោយឡែកនិយាយឲ្យចំឯកសារនេះសំដៅភូមិភាគបូព៌ា ។ តទៅនេះ ខ្ញុំបាទសូមជូនឯកសារមួយទៀត ដែលខ្ញុំបាទរាយការណ៍ជូនទៅអចិន្ត្រៃយ៍ ក៏ប៉ុន្តែ អចិន្ត្រៃយ៍ចាត់ចែងនៅក្នុងរង្វង់អចិន្ត្រៃយ៍ ។ ឯកសារនេះមានលេខ ៣៣/៤ លេខ ERN00173000 លេខ ERN00173000 ។ លេខ D គឺ D32/4 ឯកសារនេះខ្ញុំបានចារជូនមេ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៧ ។

“បងជាទីគោរព!

១) អានេះវាច្រើននិយាយពីសាច់ការ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការដាក់បញ្ចាំងនូវឯកសារ ។

មានទេ មានឯកសារដែរ នៅរៀបរយរួចហើយណ៎ា ។

អញ្ជើញៗ ជនជាប់ចោទ អញ្ជើញ ។

**ឆ៖** នេះជាចំណាររបស់ខ្ញុំជូនទៅមេ គឺលោក គ្រូ សុន សេន លើចម្លើយសារភាពរបស់ឈ្មោះ ហេង ពេជ្រ ហៅ ឆន ជាចម្លើយលើកទីមួយរបស់ ហេង ពេជ្រ ហៅ ឆន ។

ខ្ញុំចារថា៖ បងជាទីគោរព!

ក្បៀស “,” អានេះវាច្រើននិយាយអំពីសាច់ការ អំពីជំហរអនុវត្តលាក់ការណ៍សម្ងាត់ អំពីជំហរទ្រាំទ្រលំបាកវេទនាយូរអង្វែង លំបាកយូរអង្វែងដើម្បីបង្កប់ ឲ្យបានក្នុងបក្សកុម្មុយនីស្តកម្ពុជា ។

ខ្ញុំសូមអានឡើងវិញ “១) អានេះវាច្រើននិយាយអំពីសាច់ការ អំពីជំហរអនុវត្តលាក់ការសម្ងាត់ អំពីជំហរទ្រាំទ្រ លំបាកយូរអង្វែងដើម្បីបង្កប់ឲ្យបានក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ ២) ចំពោះសមាជិក *កា.ហ្វេ.បេ* ដែលវារាយការណ៍ វាថាបានពង្រីកថ្មី មានម្នាក់ឈ្មោះ សៀង ហួឡុងៗ ។ *កា.ហ្វេ.បេ* ដែលពង្រីកថ្មីបានម្នាក់ហ្នឹងឈ្មោះ សៀង ហួឡុង ។ ដោយគោរព! ឌុច ថ្ងៃ១៦ ខែ១ ឆ្នាំ១៩៧៧” ។

នេះខ្ញុំចារទៅជូនមេខ្ញុំប៉ុណ្ណោះ ។ ដល់បានទទួលឯកសារនេះហើយមេខ្ញុំគាត់ចារ ។ នេះបង្ហាញឲ្យឃើញថា ឯកសារនេះគាត់ចាត់ចែងតែក្នុងអចិន្ត្រៃយ៍ទេ គាត់ចារនៅក្នុងទំព័រ ERN00172999 ឯកសារលេខ D32/4 ។

ខាងលើបំផុតគាត់ដាក់ "សម្ងាត់" ។ នេះអក្សរមេខ្ញុំហើយបង ខៀវ, សុន សេន ហើយខាងក្រោមគាត់ដាក់សម្គាល់៖

១) ឯកសារនេះនាំឱ្យយល់អំពីផែនការបង្កប់ស៊ើបការណ៍ កសាងកម្លាំងក្បត់របស់ពួកសេរី ។

ខ្ញុំសូមអានម្តងទៀត "១) ឯកសារនេះនាំឱ្យយល់ពីផែនការបង្កប់ស៊ើបការណ៍ កសាងកម្លាំងក្បត់របស់ពួកសេរី ។ ២) យកខ្សែចាត់តាំងវាមួយចំនួន ក្នុងនេះចាប់អារម្មណ៍ករណីសមមិត្តប្រសិទ្ធ ។ ក្នុងនេះចាប់អារម្មណ៍ករណីសមមិត្ត ប្រសិទ្ធ ។ ប្រសិទ្ធ នេះ គឺ ជួន ប្រសិទ្ធ, ប្អូន ជួន ជឿន, ប្អូន ជួន មុំ ។

ខ្ញុំអានឡើងវិញម្តងទៀត "យកខ្សែចាត់តាំងវាមួយចំនួន ក្នុងនេះចាប់អារម្មណ៍ករណីសមមិត្តប្រសិទ្ធ ។ សមមិត្តប្រសិទ្ធ នេះលើកមុនមានឆ្លើយចម្លើយថា គាត់ណែនាំឱ្យ *កា.ហ្សេ.ប* ធ្វើសកម្មភាពតទៅទៀត ។ តាមមតិខ្ញុំ គួរចាប់អារម្មណ៍ដែរ ហើយក្នុង-- ហើយគួរឱ្យគាត់ធ្វើការងារអី ដែលមិនទាក់ទងនឹងបរទេស ។ ៣) វាចាពត្រឹកបានម្នាក់ ឈ្មោះ ស៊ាង ហ្វូឡុង អតីតវិស្វករសេដ្ឋកិច្ចនៅប្រទេសអាល្លឺម៉ង់ខាងកើត ។ សព្វថ្ងៃនៅខាងផ្នែកបច្ចេកទេសអាកាសចរណ៍ស៊ីវិល ។ ៤) ហាក់ សៀង ឡាយនី ជាមេធំ ដឹកនាំកិច្ចការទាំងអស់ ។ ១៩/១/៧៧" ។

នេះលោកគ្រូ សុន សេន បានទទួលឯកសារពីស-២១ ហើយគាត់ចាប់ចែងក្នុងអង្គអចិន្ត្រៃយ៍មជ្ឈិមរបស់គាត់របៀបនេះ ដែលខ្ញុំលើកគឺចង់ជូនជម្រាបប៉ុណ្ណឹង ថាស-២១ គ្មានសិទ្ធិអីទាក់ទងជាមួយនឹងខាងលើទេ គឺគ្នាគេខាងលើឯណោះទេ ។ សុន សេន ជាអ្នកចាត់ចែងរាយការណ៍ជូន ប៉ុល ពត ។ សេចក្តីសម្គាល់របស់គាត់នេះ គឺជូន ប៉ុល ពត ហើយ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតរំខានទៀត គឺដើម្បីជួយឱ្យតុលាការនៅពេលដែលភាគីទាំងអស់ត្រឡប់ទៅរកប្រតិចារឹក គឺថាឯកសារដែលយើងបានយល់ហើយ ដែលថាជនជាប់ចោទបានលើកឡើងដែលនុ៎ង គឺថា D32/4 ។ ប៉ុន្តែ នៅក្នុងសំណុំរឿងគឺថាមានឯកសាររាប់រយ ដែលយោងទៅរកចម្លើយសារភាពដែលអត្ថបទពណ៌ដែលបានលើកឡើងនោះ ។

លោកចៅក្រម ប្រសិនបើជនជាប់ចោទអាចលើកឡើងដោយលេខឧបសម្ព័ន្ធ ថាឧបសម្ព័ន្ធលេខប៉ុន្មាន? ដើម្បីដូចជា១៨ ដើម្បីឱ្យជាក់ច្បាស់ដែលអាចនឹងជួយក្នុងការកត់ត្រានៅក្នុងប្រតិចារឹកនៅពេលបន្ទាប់មកនោះ ។

[១៤:០៦:៥១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំមាន D៣២ ហើយនិងលេខ១៨ ជាឧបសម្ព័ន្ធ ហើយខ្ញុំមាន *ERN* ជាភាសាបារាំង គឺលេខ 00224083 ដើម្បីអ្នកបកប្រែជាភាសាបារាំងៗ ។

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទ អញ្ជើញបង្ហាញបន្តទៀត ។

[១៤:០៧:៥២]

**ឌុ៖** សូមគោរព លោកប្រធាន ឯកសារមួយតទៅទៀតនេះ គ្រាន់តែដើម្បីបញ្ជាក់ថា ខ្ញុំជាអ្នករាយការណ៍ទៅជូន សុន សេន ឬក៏ ពូនួន ក្រោយមកគឺបញ្ជូនទៅ ពូនួន ហើយគាត់អ្នកចាត់ចែង ។ នេះសូមជូនឯកសារលេខ D43/4 ដដែល ERN00174100 ។ ឯកសារនេះជាចម្លើយរបស់បង មាឃ ទូច ហៅ កែម អតីតទូតកម្ពុជាប្រចាំឡាវ ។ ខាងណេះចំណងជើងដាក់ថា អំពីប្រវត្តិសកម្មភាពក្បត់ផ្ទាល់។

ខ្ញុំចារទៅជូនខាងលើថា "បងជាទីគោរព! សកម្មភាពវានៅលាវមានពីរ ។ មួយជាមួយចក្រពត្តិ វាទាក់ទងជាមួយអង្គការ *អះហេស្រ៊ែ "HCR"* ។ HCR ជាមួយ អ៊ិន តាំ ដោះស្រាយដកអាណិកជនខ្មែរនៅលាវ ទៅអប់រំឲ្យដាក់ខាត ប្រឆាំងបដិវត្តន៍នៅថៃ ។ HCR ជាផ្នែកមួយនៃអង្គការសហប្រជាជាតិ ។ HCR ហៅពេញឈ្មោះ គឺស្នងការជាន់ខ្ពស់នៃជនភៀសខ្លួន ។ ពីរ) ជាមួយយួន វាធ្វើការជាប់ជាមួយនឹងទូតយួនឈ្មោះ ឌិញ ញ៉ល់លៀម និងរដ្ឋមន្ត្រីការបរទេសលាវឈ្មោះ ភូនស៊ីផាសី ។ ក្នុងយុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិន យួនវាត្រូវការយកអនីតិជនខ្មែរនៅលាវប្រើការ ។ ដោយគោរព ។ ឌុច ថ្ងៃ២១ ខែ២ ឆ្នាំ១៩៧៨" ។

ដោយយោងតាមថ្ងៃខែនេះ អត្ថបទនេះខ្ញុំរាយការណ៍ជូន ពូនួន មិត្តហៅ នួន ជា ឈ្មោះដើម នួន ជា មិនមែនលោកគ្រូ សុន សេន ទេ ។ លោកគ្រូ សុន សេន ចេញពីខ្ញុំបាត់ទៅហើយ ។

សកម្មភាពវានៅលាវ វាសរសេរពីទំព័រ៣៧ តទៅ។ នេះចំណារខ្ញុំបែបនេះឯង ទៅខាងលើ ។ នៅខាងលើចំហៀងខាងឆ្វេង ចុងជ្រុងខាងឆ្វេង អក្សរពីរ-បីតួដាក់ថា "សមមិត្ត វ៉ាន់" ។ អក្សរនេះ គឺ

អក្សរ ពូនួន គឺអក្សរ នួន ជា សមមិត្ត វ៉ាន់ នេះ ។ ខ្ញុំមានបំណង ឯកសារនេះជូនប៉ុណ្ណឹងថា ខ្ញុំរាយការណ៍ទៅខាងលើគេចាត់ចែងគ្នាគេនុ៎ង ដដែលជាដដែលទេ ។

ដូច្នេះ ឯកសារនៅមានច្រើនទៀត។ ក៏ប៉ុន្តែ ខ្ញុំសូមអានជូនប៉ុណ្ណោះ ហើយនិងអានជូនមួយទៀតអំពីការទាក់ទងជាមួយនឹងកងពល ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

លោកប្រធាន យើងខ្ញុំសូមឲ្យធ្វើការកត់ត្រាក្នុងប្រតិចារឹកដែលមានលេខឧបសម្ព័ន្ធលេខ៤១ ដើម្បីឲ្យភាគីទាំងអស់មានភាពងាយស្រួលបញ្ជាក់ ។ សូមឲ្យធ្វើការបញ្ជាក់អំពីលេខ ERN និងឧបសម្ព័ន្ធ ។

លោកបាននិយាយថាឯកសារមុន អ៊ីចឹងឯកសារលេខ១៨ ដែលយើងបានលើកឡើងនេះ គឺឧបសម្ព័ន្ធលេខ៤៣ ចៅក្រមបានលើកឡើង ហើយសហព្រះរាជអាជ្ញាបានលើកឡើងថា វាជាឧបសម្ព័ន្ធ ៤១ ។ ដូច្នេះ សូមឲ្យជនជាប់ចោទបញ្ជាក់ ឲ្យរំលឹក សូមឲ្យលោកប្រធានធ្វើការបញ្ជាក់ទៅដល់ជនជាប់ចោទថា ឲ្យបញ្ជាក់លេខ ERN និងឧបសម្ព័ន្ធឲ្យបានត្រឹមត្រូវ ដើម្បីឲ្យភាគី ហើយនិងអ្នកដទៃទៀតគាត់អាចធ្វើការពិនិត្យទៅលើឯកសារទាំងអស់នោះឲ្យបានត្រឹមត្រូវបន្ទាប់ពីនេះទៅ ។

[១៤:១២:៣៤]

**ប្រធានអង្គជំនុំ៖**

មានចំណុចណាមិនច្បាស់ទៅ ដូចជាអាចមានបញ្ហាមិនយល់គ្នារវាងការបង្ហាញនេះ តាមយើងយល់ គឺគាត់បង្ហាញលេខទាំងពីរនេះរួចហើយ ឬមួយក៏ចង់ឲ្យមានការបង្ហាញហ្នឹងទាំងបីភាសា? លេខ ERN ហ្នឹងជាភាសាអង់គ្លេស ឯកសារជាភាសាអង់គ្លេស ហើយឯកសារជាភាសាបារាំងផងដែរ មុននឹងធ្វើការដដែក ឬការបង្ហាញនោះ ។ ពីព្រោះគាត់ដូចបង្ហាញច្បាស់អំពីលេខនេះ ទាំងពីរនេះរួចហើយ នៅក្នុងចំណាងជើងដែលបានលើកឡើង ហើយគ្រប់សម្តីដែលបាននិយាយនេះ ប្រតិចារឹកគេបានកត់ត្រាទុកគ្រប់សម្តីទាំងអស់ហើយ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

អរគុណលោកប្រធាន។ គឺគ្មានបញ្ហាចំពោះការយោងទៅដល់លេខERN នោះទេ នៅពេលដែលទំព័រដំបូងបានលើកឡើងជាERN ជនជាប់ចោទហើយរួចនោះ ។ ប្រសិនបើជនជាប់ចោទ គាត់ជ្រើសរើសយកលេខERN នៅក្នុងទំព័រកណ្តាលណាមួយនោះ ដូច្នេះហើយវាពិបាកនៅក្នុងការស្វែងរកក្នុង

ប្រព័ន្ធ *ហ្សាយឡេប* ដោយ-- បើសិនជាគាត់មិនមានការកំណត់ ឬបញ្ជាក់អំពីឧបសម្ព័ន្ធឲ្យបានត្រឹមត្រូវនោះទេ ។ ដូច្នេះហើយសូម-- ខ្ញុំសូមបញ្ជាក់ថា លេខឧបសម្ព័ន្ធគឺជាប្រភេទនៃឯកសារ ។ ដូច្នេះខ្ញុំដឹងថាសហមេធាវីគាត់យល់ច្បាស់ទៅលើបញ្ហាហ្នឹង ។ ប្រហែលជាលោកសហមេធាវីចង់លើកឡើងទៅលើករណីនេះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារក្តី ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

អរគុណលោកប្រធាន។ ឯកសារដែលយើងបានបង្ហាញគឺD32/4 ឧបសម្ព័ន្ធលេខ៤១ ។ ដើម្បីបញ្ជាក់អ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើង ឧបសម្ព័ន្ធមួយចំនួនគឺវាមាន ។ ដូច្នេះ ឯកសារនេះ គឺវាស្ថិតនៅក្នុងឧបសម្ព័ន្ធលេខ៤១ ។ ហើយតាមអ្វីដែលយើងបានដឹង គឺមិនមានការបកប្រែជាភាសាអង់គ្លេស ឬភាសាបារាំងចំពោះការកត់សម្គាល់លេខទៅលើឯកសារនេះ ។

សូមអរគុណ ។

[១៤:១៥:២២]

**ប្រធានអង្គជំនុំ៖**

សាជាថ្មីម្តងទៀត បើសិនជាមានលេខដែលបានលើកឡើងអ៊ីចឹងមែន វាអាចមានបញ្ហាដែរ ហើយអម្បាញ់មិញនេះសូមកែតម្រូវឡើងវិញ គឺលើកឡើងដោយមេធាវី ហ្វ្រង់ស្វ័រ រូ គឺ43/4 មិនមែន 42/4 ទេ ។ ហើយជនជាប់ចោទបើសិនជាមានឯកសារក្រោយ ហើយមានយោងទៅឧបសម្ព័ន្ធនោះ សូមបញ្ជាក់អំពីឧបសម្ព័ន្ធយោងផង ។

សូមបន្តទៀត ។

**ឌ៖** សូមគោរពលោកប្រធាន ឯកសារតទៅនេះគ្មានចំណាររខ្ញុំទេ ។ ប៉ុន្តែ មានចំណារលោកគ្រូ សុន សេន មេខ្ញុំ តែក៏ពិតជាឯកសារចេញពីមន្ទីរស-២១ ។ គឺឯកសារលេខ D32/4 បើនិយាយពី *ERN* 00172986 ។ ខ្ញុំសូមលើកតែមួយទំព័រខាងដើមនេះមកនិយាយទេ ។

ចង់បង្ហាញតែអំពីប្រវត្តិចូលខ្មែរសេរីតាមរយៈ លឹម, ផេង, តុងប៉ាង ពីឆ្នាំ១៩៦៨ ។ នេះជាចំណាងជើងចម្លើយ ។ ចម្លើយរបស់ មុំ វឿន ហៅ មុនី កងពល២៩០ ។ នាទីរបស់បុគ្គល មុំ វឿន ហៅ មុនី នេះ ជាអនុសេនាធំ ។ ទន្ទឹមនេះ ខ្ញុំមានបំណងចង់បង្ហាញចំណារមេ ថាចំណារកិច្ចការខាងចាប់ចង

ខាងអ៊ីៗប្រគល់ឯកសារយ៉ាងម៉េច គឺលោកគ្រូ សុន សេន ចាត់ចែង ។ ចាត់ចែងតាមគោលការណ៍ខាងសន្តិសុខនៅក្នុងកងទ័ពមជ្ឈិម គឺគាត់ ដែលមានចែងច្បាស់លាស់នៅក្នុងសេចក្តីសម្រេចថ្ងៃ៩ តុលា ឆ្នាំ ១៩៧៥ ។

ឥឡូវ ខ្ញុំសូមអានជូនឯកសារដូចតទៅ "ជូនសមមិត្ត តាល់ និង ណាត មួយច្បាប់ពិនិត្យ ថ្ងៃ២៧ ខែតុលា បានន័យថា ខែតុលា ឆ្នាំ១៩៧៧ ។" ដូច្នេះ គ្រប់កិច្ចការទាំងអស់ ខ្ញុំរាយការណ៍ទៅលើ មេទេ អ្នកចាត់ចែងឲ្យប្រគល់ឯកសារនេះទៅបង តាល់, មាស តាល់ លេខាកងពល២៩០ ពិនិត្យជាមួយនឹងមិត្ត ណាត ។ ណាត នេះពីដើមប្រធានស-២១ នេះឯង ។ ប្រធានស-២១ នេះដកពីស-២១ ទៅ ទៅកាន់កាប់ជាជំនួយការសេនាធិការ ។ ដូច្នេះ ឲ្យពីរនាក់នេះពិនិត្យ តើអនុញ្ញាតឲ្យចាប់ប៉ុនណាទៀត មិនចាប់ប៉ុនណាទៀត គឺមេទុកសិទ្ធិឲ្យខាងក្រោមជួយសម្រេច ។ ដូច្នេះ កិច្ចការសម្រេចកម្ទេចនៅក្នុងកងពលមជ្ឈិមគឺ សុន សេន ជាអ្នកសម្រេច ។ តាមឯកសារថ្ងៃ៣០ ខែមីនា ឆ្នាំ១៩៧៦ ក៏មានចែងបញ្ហាហ្នឹងច្បាស់លាស់ ខាងលេនាធិការ គឺខាងកងទ័ពមជ្ឈិម គឺសេនាធិការអ្នកសម្រេច ។

ដូច្នេះនេះ គឺខ្ញុំចង់បង្ហាញថា ស-២១ ជាអ្នករាយការណ៍ សេនាធិការជាអ្នកសម្រេចកម្ទេចអ្នកណា មិនកម្ទេចអ្នកណា ខាងសម្រេច ប៉ុន្តែសម្រេចដោយសួរយោបល់ម្ចាស់អង្គភាពគេ ។

[១៤:១៩:៥២]

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

លោកប្រធាន ឯកសារនេះគឺបានបញ្ចូលនៅក្នុងឯកសារ D32/4 គឺនៅក្នុងឧបសម្ព័ន្ធលេខ៩ នៃលេខ*អ៊ីនឌិក* ហ្នឹង លេខ*អ៊ីនឌិច* D32/4 *ERN* ជាភាសាបារាំង គឺ00289864 ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

**សះ** ដូចការបង្ហាញឯកសារពាក់ព័ន្ធជាមួយនឹងរបបរបាយការណ៍ទាក់ទិននឹងប្រតិបត្តិការហ្នឹង គឺសូមបញ្ឈប់ត្រឹមនេះសិន ហើយចំណែកឯការពាក់ព័ន្ធផ្សេងទៀត ជាមួយអង្គហេតុផ្សេងទៀត យើងនឹងធ្វើការបន្តបន្ទាប់ ។ ប៉ុន្តែសំណួររបស់យើងសួរថា ចុះរបបរបាយការណ៍ជាសកម្មភាពប្រចាំសប្តាហ៍ ឬក៏ប្រចាំខែទាក់ទិនជាមួយនឹងសកម្មភាពទូទៅនៃមន្ទីរស-២១ ហ្នឹង តើមន្ទីរស-២១ មានរបបរាយ-ការណ៍ជូនទៅថ្នាក់លើដែរឬទេ? ហើយបើរបបរាយការណ៍មាននោះ របបរាយការណ៍នោះត្រូវបញ្ជូនតាមរូបភាពណា?

**ឆ៖** លោកប្រធានជាទីគោរព! ទី១គឺការងារសួរចម្លើយ ហើយរាយការណ៍អំពីចម្លើយដែលទើបយកបាន ដោយទារុណកម្ម យើងខ្ញុំបានលើកជូនហើយ ។ ដោយឡែក សកម្មភាពដែលកើតមាននៅក្នុងអង្គភាព ខ្ញុំបាទមិនដែលរាយការណ៍ជាលាយលក្ខណ៍អក្សរជូនមេទេ ព្រោះមេហៅទៅជួបញឹកណាស់ ។ ដូច្នេះ ពេលទៅម្តងៗ គឺគាត់តម្រូវឲ្យខ្ញុំរាយការណ៍នៅក្នុងអង្គភាពខ្លះដែរ មួយចំនួនដែលនូវអ្វីដែលចាំបាច់ មុននឹងចូលទៅធ្វើការអំពីការងារសន្តិបាលជារួម ។

ដូច្នេះរបបរាយការណ៍ប្រចាំខែ ប្រចាំអាទិត្យ គ្មានកំណត់ទេ ។ ថ្ងៃណាទៅជួបគាត់ មានការអីចាំបាច់រាយការណ៍ ។ នេះសូមបញ្ជាក់ឆ្លើយខ្លីប៉ុណ្ណេះ ។

**ស៖** ការបង្ហាញអំពីរចនាសម្ព័ន្ធ ដែលលោកបានគូរនៅក្នុងដំណាក់កាលនៃចំពោះមុខសហចៅក្រមស៊ើបអង្កេតនោះ អំពីរចនាសម្ព័ន្ធនៃគ្រប់គ្រងនៃមន្ទីរស-២១ មានពាក់ព័ន្ធជាមួយនឹងមន្ទីរ ស-២៤ ផង ដែលនៅក្នុងឯកសារហ្នឹងបញ្ជាក់ថាព្រៃសៗ ។

សំណួរសួរថា ការបង្កើតមន្ទីរស-២១ កាលពីដើមឡើយហ្នឹង រួមទាំង ព្រមគ្នាក្នុងការបង្កើត ស-២៤ ឬក៏ព្រៃសហ្នឹងជាមួយគ្នា ដែលយកតាមលំនាំនៃការបង្កើត ម-១៣“ក” និងម-១៣“ខ” អីចឹងទេ ឬក៏វាកើតក្រោយ ក្រោយមកទៀតនៅក្នុងអំឡុងពេលផ្សេងគ្នា?

[១៤:២៣:៥០]

**ឆ៖** លោកប្រធានជាទីគោរព ដំបូងខ្ញុំសូមបញ្ជាក់ជូនអំពី ម-១៣“ក” និងម-១៣“ខ” ។ ដំបូងឡើយមានតែម-១៣ ទទេ ដល់ឃើញថា ខ្ញុំមិនចង់ឲ្យអ្នកដែលយើងត្រូវដោះលែង ឃើញអ្នកដែលយើងទុក ហើយយើងធ្វើទារុណកម្ម យើងដាក់ខ្នោះ យើងសួរចម្លើយហើយ ហើយកម្ទេច ម៉្លោះហើយខ្ញុំស្នើសុំបង្កើត ម-១៣“ខ” នេះឡើង ។ ម-១៣“ខ” ដែលខ្ញុំសូមបង្កើតនេះ ទទួលការយល់ស្របពីមជ្ឈិមបក្ស គឺបង វន វ៉េត ។ បងវន គាត់យល់ស្របពេញទី ។

ដោយឡែក ស-២១ គឺជាអង្គភាពមួយដែលអចិន្ត្រៃយ៍មជ្ឈិមបង្កើតឡើង ។ ដំបូងមាន ណាត ជាលេខា ខ្ញុំជាអនុលេខា ។ មុននឹងបង្កើត ស-២១ នោះ វាមាន ម០៣ របស់ ណាត ហ្នឹង ។ ខ្ញុំសូមនិយាយរំឭកបញ្ជាក់ជូនលោកប្រធានជ្រាប។ ហើយដល់ ណាត ចេញទៅ ខ្ញុំក៏មិនដឹងជាមានពាក្យថា ស-២៤នេះ អត់ដឹង ។ ស្រាប់តែមកដល់ពេលដែលស៊ើបអង្កេតនេះ អីទទួលវាយួរឆ្នាំមកផង វាក់ស-២៤ហ្នឹង គឺស្អី ។ បានឥឡូវគិតត្រឡប់ថយក្រោយឡើងវិញ ឈរលើឯកសារ អាពាក្យស-២១នេះ បក្សគេទទួលស្គាល់ណាស់ តែស-២១ទេ ហើយចង្រៃគេទទួលស្គាល់តែពាក្យស-២១ មួយតែមួយម៉ាត់តែ

ប៉ុណ្ណឹងឯង ។ ជាក់ស្តែងមិត្ត ហ៊ុយ ចូលទៅប្រជុំកសិកម្មជាមួយនិងខាងសេនាធិការ ក៏មិត្តហ៊ុយ ទៅក្នុងនាម ស-២១ អត់មានក្នុងនាម ស-២៤ទេ ។

បានដែលថាខ្ញុំពិនិត្យសាឡើងវិញ ណាត គាត់ចង់ធ្វើអង្គភាពហ្នឹងឲ្យទៅជាក្រសួងមួយប៉ុនណាណី ។ អា ស-២១ ហ្នឹងខ្ញុំធ្វើប្រធាន ។ អា ស-២២ ហ្នឹង បែបគុកតាខ្មៅ អា ស-២៣ ហ្នឹង បែបជាចម្ការដំណាំផ្លែឈើហូបផ្លែ ដែលខ្ញុំបានជម្រាបជូននោះ ហើយអា ស-២៤ ហ្នឹងគឺព្រៃស ។ អង្គាល់ហ្នឹងអង្គាល់គាត់នៅ គឺមិនទាន់មានជើងឯកទេ ។

បានតែខ្ញុំជម្រាបនេះ និយាយនេះ មិនមែនទទួលស្គាល់តែឧក្រិដ្ឋកម្ម ដែលមាននៅទីក្រុងភ្នំពេញទេ កន្លែងទីតាំងរបស់ ស-២១ ដែលខ្ញុំនិយាយទេ អា ស-២៤នេះ គ្មានទេ មានតែ ស-២១ ព្រៃសអាព្រៃសនេះ គឺ ស-២៤ ដែរ ។

សរុបមក ស-២៤ ណាត បង្កើតក្រៅផ្លូវការ ក៏ប៉ុន្តែអង្គភាពនេះ វាជារបស់ខ្ញុំ ។ ខ្ញុំគ្រប់គ្រងបន្តពីគាត់ ។ ដូច្នេះ អង្គភាពនេះ វាមានចាប់តាំងពី អង្គភាពព្រៃសនេះ វាមានចាប់តាំងពីនៅជា០៣ មកម្ល៉េះតាំងពីដើមអើយមក តាំងពីអង្គភាពនេះនៅជា០៣ ។ សូមបញ្ចប់ប៉ុណ្ណេះ ជូនលោកប្រធានដោយគោរព ។

[១៤:២៧:១២]

**ស៖** ឥឡូវយើងត្រឡប់ទៅបញ្ហាមួយទៀត ដែលមានការពាក់ព័ន្ធជាមួយនឹងគុកតាខ្មៅ បញ្ជាក់ឡើងវិញ គុកដែលមានទីតាំងនៅអតីតមន្ទីរពេទ្យឆ្កួតនៅតាខ្មៅ ហើយលោកក៏បានបង្ហាញអំពីបញ្ហានេះខ្លះហើយ ប៉ុន្តែមិនទាន់ច្បាស់ ។ សំណួរសួរថា លោកដឹងទេ ថាគុកនៅមន្ទីរពេទ្យឆ្កួតតាខ្មៅ ដែលព្រឹកមិញក៏លោកបានឆ្លើយពាក់ព័ន្ធទៅនឹងមន្ទីរ-- គុកពេទ្យឆ្កួតនៅតាខ្មៅនោះដែរ ថាតើវាកកើតឡើងចាប់ពីពេលណាមក?

**ឆ៖** លោកប្រធានជាទីគោរព! មន្ទីរ០៣ ឬក៏មន្ទីរនគរបាលកងពល៧០៣ វាកកើតឡើង វាកាន់កាប់នៅខាងតាខ្មៅនោះឯង ។ គឺដូចខ្ញុំបានជម្រាប់អ៊ីចឹង ពេទ្យឆ្កួតតាខ្មៅនេះមួយ ចម្ការដំណាំនៅតាខ្មៅនេះពីរ ហើយគុកពិសេសនៅភូមិគ្រឹះស្តេច ក្រុមព្រះស៊ីសុវត្ថិ មុន្នីវ៉េត តាមផ្លូវព្រះនរោត្តម នេះសម្រាប់ដាក់អ្នកទោសពិសេស ។ នេះវាមានបីអង្គភាពបីរបស់វា ។ ជារួមមកហៅ មន្ទីរនគរកងពល៧០៣ ដែលមាន ណាត គ្រប់គ្រងពីលើទៅ ហើយ មិត្តហ៊ី ជាអ្នករត់ការប្រចាំថ្ងៃ គ្រប់បែបគ្រប់យ៉ាងវាកកើតតាំងពីដំបូងនេះមក ។ នេះរឿងគុកតាខ្មៅ ។

សូមបញ្ជាក់ជូនលោកប្រធានត្រឹមនេះ ។

**សៈ** បានន័យថា លោកអត់ច្បាស់លាស់ទេ អំពីការកកើតឡើងនៃមន្ទីរគុកតាខ្មៅហ្នឹងពេលណាហ្នឹង អត់ច្បាស់ទេ? ប្រហែលជាអំឡុងពេលក្រោយថ្ងៃរំដោះ១៧ មេសា ៧៥ ឬក៏កើតមុនហ្នឹង?

**ឆៈ** ជម្រាបប្រសាសន៍លោកប្រធាន! តាខ្មៅយើងរំដោះបាន នៅថ្ងៃ១៧ មេសា ហ្នឹងឯង ។ ដូច្នេះ ក្រោយ១៧មេសា មួយថ្ងៃពីរថ្ងៃហ្នឹងកកើតហ្នឹង ។ សូមបញ្ជាក់បន្ថែមបន្តិចទៀត បើតាមការសង្កេតរបស់ខ្ញុំ ត្រឡប់ទៅក្រោយវិញ កងពលផ្សេងទៀត ដូចយ៉ាងកងពល៥០២ កងពល៦៥០ គេមានភារកិច្ចតែមួយទេ គឺចាប់ពួកមន្ត្រីចាស់របស់រដ្ឋការ លន់ នល់ យកទៅកម្ទេច ។ ដោយឡែក កងពល៧០៣ សម្រិតសម្រាំង គណៈកម្មាធិការតំបន់២៥ ដែលមាន សុខ ប៊ុតចំរើន ជាអនុលេខា ។ ឈ្មោះ សុខ ប៊ុតចំរើន ហ្នឹង ឈ្មោះដើម ស៊ីសុវត្ថិ ប៊ុតមុន្នី ជាអនុលេខ ។ នៅ ផន ហៅ សុខ ជាសមាជិក ហើយនិង ហ៊ួត សេ ហៅ ប៊ុន ថន ជាសមាជិក ។ ដូច្នេះ ការសម្រិតសម្រាំងផ្ទៃក្នុងបក្ស និងផ្ទៃក្នុងកងពល១២ កងពល៧០៣ ហ្នឹង ពីដើមឈ្មោះ កងពល១២ វាចាប់កំណើតតាំងក្រោយ ១៧ មេសា មកភ្លាម ទន្ទឹមគ្នានឹងដើរចាប់ពួកទាហានចាស់ ប៉ូលិសចាស់ អ្នករដ្ឋការចាស់យកមកដាក់គុកតាខ្មៅ ហើយកម្ទេច ទន្ទឹមគ្នានោះ ។

**សៈ** លោកបានឆ្លើយបញ្ជាក់ថា ព្រឹកមិញហ្នឹង គឺបើតាមការយល់ឃើញរបស់លោក ដែលលោកបានធ្វើកិច្ចការពាក់ព័ន្ធជាមួយនិងការបង្កើតមន្ទីរស-២១ នៅជុំវិញនៃកន្លែងទួលស្លែងបច្ចុប្បន្ននេះ នាំឲ្យលោកយល់ថា មនុស្សដែលកំពុងជាប់ឃុំឃាំងនៅអតីតមន្ទីរពេទ្យឆ្កួត នៅតាខ្មៅហ្នឹងមានចំនួនច្រើន អ៊ីចឹងមែនទេលោក?

[១៤:៣១:០៤]

**ឆៈ** ច្រើនប៉ុនណា ខ្ញុំមិនជាក់ស្តែងទេ ជម្រាបលោកប្រធានដោយស្មោះត្រង់ ឯចំណែកគេយកមកចំនួនតិច យកមកទុកនៅនុំង សម្រាប់ឲ្យសួរចម្លើយ ហើយដល់ក្រោយមកកន្លែងទៅ *ប៉េហ្ស៊ី* សួរចម្លើយផង រៀនសួរផង ។ ខ្ញុំបង្រៀនកម្មាភិបាលកងពល៧០៣ សួរចម្លើយ គឺនៅ *ប៉េហ្ស៊ី* ។

ដូច្នេះមួយចំនួនច្រើន មិនដឹងច្រើនប៉ុណ្ណាទេនៅគុកតាខ្មៅហ្នឹង ខ្ញុំមិនប៉ានចូលទេ ។

**សៈ** កាលពីពេលមុនលោកបានឆ្លើយពាក់ព័ន្ធជាមួយនឹងថា ចាត់តាំងអនុប្រធានរបស់លោកថា ដើម្បីឲ្យទៅរៀបចំនៃការចាត់ចែងគាស់នូវអដ្ឋិធាតុ នូវឆ្អឹងជនរងគ្រោះដែលបានកប់នៅទីនោះ មុននឹងប្រគល់ទីនោះ ឲ្យទៅខាងផ្នែកសង្គមកិច្ច ទៅសង្គមកិច្ច ។

សំណួរសួរថា ពេលដែលគាស់កកាយ ឬយកឆ្អឹងជនរងគ្រោះ ដើម្បីដុតចោលហ្នឹង ការរកឃើញហ្នឹងមានចំនួនច្រើនប៉ុន្មានទៅ តាមការប៉ាន់ស្មាន?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំអត់បានទៅមើលទេ បញ្ជាគេទៅប្រហែលជាពីរអាទិត្យ គេមករាយការណ៍ប្រាប់វិញ ថាអស់ហើយបង នៅតែពីរទេ ក្រោមទំនប់មួយធំ ដែលយើងទើបនឹងជីក ខ្ញុំជឿ ពេលនោះខ្ញុំជឿ ថាតើវាមែន ឬមិនមែន ។ ខ្ញុំជឿ សូមទោស ដល់ខ្ញុំជឿ ខ្ញុំរាយការណ៍ទៅលើ ខ្ញុំថាបងគាស់កកាយអស់ហើយ នៅតែពីរខាងក្រោមទំនប់ ខ្ញុំសូមជូនហើយ ជូនទៅខាងសង្គមកិច្ច ។ ក៏រឿងហ្នឹងក៏ស្ងាត់មក ។ មកដល់ពេលកំពុងតែសួរស៊ើបអង្កេតនេះ ខ្ញុំចាប់អារម្មណ៍ថា អង្គាល់ហ្នឹងមិត្តហ៊ួ វររកកាយមិនអស់ទេដឹង ។ ដល់ក្រោយមកឃើញឯកសារស្រាវជ្រាវរបស់ខាងសហព្រះរាជអាជ្ញាយើងហ្នឹង ឬក៏ខាងចៅក្រមស៊ើបអង្កេតយើងហ្នឹង ថាគ្មានឃើញដានឧក្រិដ្ឋកម្មនៅហ្នឹងទេ ។ រាយការណ៍មាន ហើយបានខ្ញុំសូមបញ្ជាក់ថា ខ្ញុំជាអ្នកបញ្ជាឲ្យ មិត្តហ៊ី គាស់កកាយ ។ ដូច្នេះ បញ្ជាក់ថា មិត្តហ៊ួ បានធ្វើការដោយត្រង់ ហើយរត់មករាយការណ៍ឲ្យខ្ញុំវិញ ដោយត្រង់មិនប៊ានលាក់ទេ គឺគាស់កកាយអស់ ។ ដូច្នេះ ប៉ុន្មាន ឬប៉ុន្មានខ្ញុំភ្លាប់បានទេ សូមជម្រាបប្រសាសន៍ដោយត្រង់ គ្រាន់តែបើពេលវេលាដែលតាំងខ្ញុំបញ្ជារហូតមកដល់គេមករាយការណ៍ឲ្យវិញ ប្រហែលជាកន្លះខែ លើសខ្វះបន្តិចបន្តួចប៉ុណ្ណឹង ។

[១៤:៣៣:៣៥]

**ស៖** លោកបានឆ្លើយថា ក្រោមទំនប់ហ្នឹងពីរ ពីរហ្នឹងពីរនាក់ ឬក៏ពីររណ្ដៅ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ពីរហ្នឹង គឺពីររណ្ដៅ-- សូមទោស ពីរហ្នឹងពីរនាក់ៗក្រោមទំនប់ ។ រួចអាទំនប់ហ្នឹងធំណាស់ គាស់មិនបានទេ រួចតែពីរនាក់ទេបង ខ្ញុំក៏បានរាយការណ៍ទៅមេប៉ុណ្ណឹងដែរ ។

**ស៖** លោកគិតឡើងវិញ សាកល្បងគិតឡើងវិញមើល៎ ថាតើការបរិច្ឆេទនៃការប្រគល់មន្ទីរអតីតគុកនៅពេទ្យឆ្កួតឲ្យទៅសង្គមកិច្ចហ្នឹង ប្រហែលជាក្នុងអំឡុងថ្ងៃខែឆ្នាំណាទៅ?

**ឆ៖** ខ្ញុំយកកាលបរិច្ឆេទមួយជាគោល គឺថ្ងៃ១៥ សីហា ឆ្នាំ១៩៧៧ តាមចំណាំខ្ញុំ ដែលខ្ញុំជឿជាក់ថាមិនខុស គឺជាថ្ងៃដែល ពូនួន គាត់មកទទួលគ្រប់គ្រងខ្ញុំ បន្តពីលោកគ្រូ សុន សេន ហើយគាត់ប្រាប់ខ្ញុំថាលោកគ្រូសុន សេន ទៅសមរភូមិ ។ បើយកថ្ងៃនេះជាគោល គឺមុននោះបន្តិច បួនប្រាំខែ ពីរបីខែ ខ្ញុំអត់ច្បាស់ទេ ។ ដូច្នេះ គឺមុន មុនដែលលោកគ្រូលោកសុន សេន គាត់ចេញពីខ្ញុំ ។ នេះសូមបញ្ជាក់

ប៉ុណ្ណឹង ។ ចាំបានតែប៉ុណ្ណឹងឯង ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់ជនជាប់ចោទទេ អំពីអង្គហេតុដែលបានកំណត់ក្នុងការធ្វើសវនាការនៅពេលនេះ?

បើមានសូមអញ្ជើញ សូមអញ្ជើញលោកស្រី។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** សូមអរគុណលោកប្រធាន សំណួរចុងក្រោយមួយអំពីគុកនៅតាខ្មៅ ខ្ញុំមិនច្បាស់ថា លោកអាចនឹងផ្តល់ចម្លើយឲ្យខ្ញុំ ប៉ុន្តែខ្ញុំមិនច្បាស់ទេ ពីដំបូងជាពេទ្យឆ្កួតទេ តើត្រូវទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! អង្កាល់ពីសម័យសម្តេចព្រះនរោត្តមសីហនុ កន្លែងនុ៎ងពេទ្យឆ្កួត គេហៅថា ពេទ្យស៊ុនម៉ម ហើយតែដល់ លន់ នល់ ក៏ប្រហែលជានៅពេទ្យឆ្កួតទៅទៀត ។ ទើបតែមកសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹងទេ បាន ណាត គាត់ប្រែកន្លែងហ្នឹងឲ្យទៅជាគុករបស់គាត់ ។ ហ្នឹងខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ដោយគោរព ។

[១៤:៣៦:៣៣]

**ស៖** អ៊ីចឹង គឺថានៅថ្ងៃទី ១៧ មេសា ឆ្នាំ១៩៧៥ ហ្នឹង គឺបានបង្កើតកន្លែងហ្នឹងទៅជាគុក ឬក៏យ៉ាងដូចម្តេច?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវនេះ! ជាការវិភាគ និងការសន្និដ្ឋានរបស់ខ្ញុំ គឺអ៊ីចឹង ។ សូមបញ្ជាក់ថា ពេលនុ៎ងខ្ញុំបាទនៅឯអមលាំងនុះនៅឡើយទេ ។ ដូច្នេះ គ្រាន់តែវិភាគ និងសន្និដ្ឋានតាមហេតុការណ៍ដែលជាក់ស្តែង ដែលនៅសល់មកក្រោយនេះ ។

**ស៖** ដូច្នេះ ខ្ញុំយល់ហើយលោកមិនដឹងច្បាស់ទេ ប៉ុន្តែខ្ញុំសូមសួរសំណួរមួយទៀត តើលោកដឹងថាតើអ្នកជំងឺៗពេទ្យឆ្កួត--

តាមពិតមិនមានការបកប្រែភាសាបារាំង--

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមអនុញ្ញាត-- យើងប្រឈមមុខនឹងបញ្ហានោះ សញ្ញាការសួរហ្នឹង គឺត្រូវបានជាន់-- គឺថាមិនមានការបកប្រែទៅជាបារាំងទេ យើងមិនដឹងថាដល់ចំណុចណាទេ ពេលនេះនោះ ។ ដូច្នេះ សូមលោកស្រីចៅក្រមមេត្តាអានសំណួរចុងក្រោយនោះឡើងវិញ ឬក៏សំណួរមុនហ្នឹង ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** សំណួរពីដំបូងដែលខ្ញុំសួរទៅជនជាប់ចោទនោះ គឺៗសួរគាត់ថាតើត្រូវឬទេដែលថា ពេទ្យឆ្កួតតាខ្មៅនុំង ត្រូវបានយកទៅប្រើ គឺថាពីរបីថ្ងៃក្រោយមក ។ ក្រោយថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ ហ្នឹង តែពីរបីថ្ងៃក្រោយហ្នឹង ទៅជាគុក ។ ហើយជនជាប់ចោទ បានកត់សម្គាល់ថា គាត់មិនបានដឹងដោយផ្ទាល់ខ្លួនច្បាស់ទេពីរឿងហ្នឹង ។ ប៉ុន្តែ បញ្ជាក់ថាវាផ្អែកទៅលើការយល់ដឹង ហើយការសន្និដ្ឋានឯកសារដែលគាត់បានពិនិត្យទេ ។

សំណួរមួយទៀតរបស់ខ្ញុំដែលបានសួរនោះ ដោយកត់សម្គាល់ឃើញថាលោកៗមិនបានដឹងផ្ទាល់អំពីរយៈកាលដំបូងនៃគុកតាខ្មៅនោះ តើលោកដឹងថា តើអ្នកជំងឺនៅពេទ្យឆ្កួត នៅកន្លែងពេទ្យឆ្កួតនោះពួកគេយកទៅណា ហើយជួបជោគវាសនាដូចម្តេចនៅកន្លែងហ្នឹង មុននឹងកើតជាគុកនោះ?

[១៤:៣៩:៤១]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ បញ្ហានេះក៏នៅតែក្នុងបញ្ហាវិភាគ និងសន្និដ្ឋានដដែលទៀត។ ជោគវាសនារបស់អ្នកមានជំងឺឆ្កួតទៅដេកពេទ្យនុំង មិនដឹងជាគេដោះចេញពីគុកឲ្យទៅពាស់វាលពាសកាល ឬក៏គេកម្ទេចទាំងអស់ ។ ខ្ញុំអត់ច្បាស់ ។ ក៏ប៉ុន្តែ ខ្ញុំសូមវិភាគបញ្ហាមួយដោយប្រៀបធៀបទៅនឹងមនុស្សឃ្លង់ ។ នៅខាងតំបន់១៥ មនុស្សឃ្លង់គេឲ្យកម្ទេច ។ ខ្ញុំជួបលេខាស្រុកពញាឮ តំបន់១៥ ប្រាប់ខ្ញុំមនុស្សឃ្លង់ខាងលើឲ្យកម្ទេច ។

ដូច្នេះ ខ្ញុំសន្និដ្ឋានលទ្ធភាពលោកពី៥០ភាគរយ ដែលជនរងគ្រោះជាមនុស្សឆ្កួតនៅក្នុងមន្ទីរពេទ្យនេះ ត្រូវគេកម្ទេច ។ នេះជាសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ដោយប្រៀបចុះប្រៀបឡើង វិភាគចុះវិភាគឡើង ។ សូមបញ្ជាក់ថានេះ ក៏នៅជាសេចក្តីសន្និដ្ឋានដដែល ដែលខ្ញុំខំវិភាគ និងរាយាការណ៍លោកស្រី ត្រូវខុសឬយ៉ាងម៉េច ខ្ញុំសូមអត់ទោស ។

**ស៖** សូមអរគុណ។ ខ្ញុំមានសំណួរសំណួរសង្ខេបមួយទៀតអំពីអ្នកទោសជាជនជាតិវៀតណាមដែលបាននាំមកកាន់សាលាពញាយ៉ាត ដែលមានឯកសារ ERN00153575 ដែលផែនទីនៃប្លង់នៃអគារទាំងឡាយនៅក្នុងស-២១ ។ លោកបាននិយាយថា អ្នកទោសវៀតណាមត្រូវបានគេយកសួរចម្លើយនៅភាគខាងលិច។ ប៉ុន្តែ ខ្ញុំមិនដឹងច្បាស់ថាតើចំណុចណាមួយនៃកន្លែងនោះដែលគេឃុំខ្លួនអ្នកទោសវៀត-ណាមនោះ ខាងកើតហ្នឹង។ តើលោកអាចបញ្ជាក់បានទេថា សួរនៅខាងកើត ប៉ុន្តែ គេឃុំខ្លួនអ្នកទោសវៀតណាមនៅកន្លែងណា?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! គឺខ្ញុំដឹងតែកន្លែងសួរទេ ខ្ញុំប្រគល់អាផ្ទះលេខ៦ របស់ខ្ញុំនេះទៅឲ្យបង ម៉ម ណៃ សួរចម្លើយវៀតណាម ។ ហើយក្រោយមកប្រុងរៀបចំ*ស្នូតយោ* ថែមទៅទៀតនៅកន្លែងនុំុង នេះខ្ញុំដឹងប៉ុណ្ណឹង ។ ឯចំណែក កន្លែងឃុំឃាំងពិតជារួមគ្នានៅក្នុងអាគារ B, C ហើយនិង D នៃគ្រិះស្ថានវិទ្យាល័យពញាយ៉ាត មិនដឹងណាមួយទេ ខ្ញុំអត់បានដឹង អត់បានគិតគូរដល់នុំុងទេ ។

[១៤:៤២:៥៨]

**ស៖** សូមអរគុណ។ ខ្ញុំចង់ត្រឡប់ទៅចំណុចចុងក្រោយមួយទាក់ទងទៅនឹងជោគវាសនារបស់អ្នកសួរចម្លើយដែលសុទ្ធតែជាស្ត្រីដែលត្រូវបានចាត់តាំងឲ្យសួរចម្លើយអ្នកទោសស្ត្រីនៅស-២១ ។

លោកបានបញ្ជាក់ប្រាប់យើងនូវផែនការ នៅតារាងមួយដែលមានលេខ 0000154228 ហើយនៅក្នុងប្លង់នោះ លោកបាន១វាយឈ្មោះអ្នកសួរចម្លើយស្ត្រីចំនួនបួននាក់ តើលោកនៅចាំទេ ឈ្មោះអ្នកបួននោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! កម្មាភិបាលសួរចម្លើយស្រីដែលមានភេទជាស្រីសម្រាប់សួរចម្លើយអ្នកទោសស្រីទាំងអស់មានប្រាំ ។ ក៏ប៉ុន្តែ នៅពេលដែលធ្វើអង្គការលេខនេះ ខ្ញុំបាទភ្លេចម្នាក់គឺភ្លេចឈ្មោះ មិត្តពឿន ។ មិត្តពឿន នេះត្រូវបាន ស-២១ ចាប់កម្ទេចដោយសាររឿងប្តីគាត់ ដែលត្រូវកម្ទេច ។ ប្តីគាត់ឈ្មោះ មិត្តម៉េង ។ ដល់ក្រោយមកទៀត ស-២១ ទទួលបញ្ជាឲ្យកម្ទេច មិត្តហ៊ុយ គឺនុន ហ៊ុយ នៅស្រែនេះ ។ ដូច្នេះ ដោយទាំង មិត្តឃឿន, ប្រុក ឃឿន នេះទៅជាមួយប្តីដែរ ទៅទៀត ។

ដូច្នេះ អស់ពីរនាក់ៗ នៅសល់បីនាក់ នៅសល់ទីមួយគឺ មិត្តម៉ុត នៅសល់ទីពីរគឺ មិត្តនី ប្រពន្ធមិត្តប៉ុន ។ សូមនិយាយត្រឡប់ទៅខាងដើមវិញមិត្តម៉ុត នេះគឺប្រពន្ធ មិត្តហ៊ី មុននឹងរៀបការជាមួយមិត្ត ម៉ុតនេះ (សូមទោស) មុននឹងមិត្តម៉ុត រៀបការ មិត្តហ៊ី នេះ, មិត្តម៉ុត ជាកម្មាភិបាលវរសេនាតូចរបស់អង្គភាពកាត់ដេរ ។ ហើយដល់យកចូលមកស-២១ ខ្ញុំចាត់តាំងឲ្យធ្វើជាប្រធានពួកកម្មាភិបាលស្រីៗសួរចម្លើយស្រី ។

ដូច្នេះ នៅសល់ទីមួយមិត្ត ម៉ុត នេះប្រពន្ធមិត្តហ៊ី ពីព្រោះមិត្តហ៊ី គាត់នៅដែរ ។ ទីពីរនៅសល់មិត្តនី ប្រពន្ធ មិត្តប៉ុន ពីព្រោះ មិត្តប៉ុន ហ្នឹងក៏នៅរស់ដែរ។ ដូច្នេះ មិត្តនី ក៏នៅរស់ទៅ ។ ទីបីកម្មាភិបាលស្រីមួយទៀតសួរចម្លើយស្រីឈ្មោះ មិត្តរ៉ន ។ មិត្តរ៉ន នេះមិនមែននៅរស់ដោយសារ មិត្តត្រូវ ទេ គឺមិត្តត្រូវ នៅរស់ដោយសារមិត្ត រ៉ន ។ មិត្តរ៉ន នេះមានឪពុកមាគាត់ម្នាក់ លេខាតំបន់៣១ ភូមិភាគបស្ចិមឈ្មោះ បងយឹម ។ ឪពុកមារបស់គាត់នោះធំណាស់ ។ ដូច្នេះ ពូជអ្នកពាមមិនសូវនរណាហ៊ានប៉ះទេ ។

ពូជអ្នកភូមិពាម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

សរុបមកនៅសល់បីនាក់រហូតដល់ថ្ងៃ៧ មករា នេះសូមរាយការណ៍ជូនលោកជំទាវប៉ុណ្ណោះអំពីកម្មាភិបាលសួរចម្លើយស្រី ។

**ស៖**

អ៊ីចឹងនិយាយដោយសង្ខេបប្រពន្ធរបស់កម្មាភិបាលដែលគេទុកចិត្តត្រូវបានគេជ្រើសតាំងឲ្យធ្វើជាអ្នកសួរចម្លើយ ។ ប៉ុន្តែ ពេលដែលប្តីរបស់ពួកគេ-- គេមិនទុកចិត្តនោះទៅទៀតទេ គេយកទៅអ្នកហ្នឹងមកឃុំខ្លួន ។ ប្រពន្ធនោះក៏ត្រូវគេឃុំខ្លួនដែរ ហើយក៏កម្ទេចដែរ ។ អ៊ីចឹងជាសេចក្តីសង្ខេបត្រូវទេ ការយល់បែបនេះ?

[១៤:៤៧:១២]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន នេះជារឿងពិតនៃរបបកម្ទេចនៅពេលនុ៎ង គឺអ៊ីចឹង ប្តីទៅហើយ ប្រពន្ធទៅហើយ ។

**ស៖** លោកបាននិយាយថា គឺថាមានយុវជនពីរឡាន ហើយនិងកុមារពីរឡានដែលគេដឹកមកពីកំពង់ឆ្នាំង ដើម្បីបំពេញបន្ថែមធ្វើជាបុគ្គលិកនៅក្នុងស-២១ លោកក៏បានបញ្ជាក់ដែរ ថាអ្នកទាំងនោះអ្នកខ្លះត្រូវបានគេឲ្យ-- ចាត់តាំងឲ្យធ្វើជានីរសារ ប៉ុន្តែមានតែប្រាំនាក់ប៉ុណ្ណោះទេ ដែលធ្វើនីរសារ ។ ចុះកុមារ ហើយនិងយុវជនផ្សេងៗទៀតគេធ្វើអីនៅស-២១?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ប្រាំនាក់ដែលមានមុខនៅ ស-២១ នេះ មិនមែនសុទ្ធតែពួកកំពង់ឆ្នាំទេ ។ នីរសាររបស់ នុន ហ៊ុយ ពួកខាង២៥ ខាងតំបន់២៥ ខាងស្អាងកោះធំឯណោះទេ ។ មិត្តថា នីរសារ មិត្តហ៊ី ក៏ខាងស្អាងកោះធំ ។ ចំណែក នីរសារមួយរបស់ខ្ញុំបាទ ដែលថាកំបុតដៃម្ខាងមកពីកងពល៧០៣ ហ្នឹង ក៏ជាពួកកោះធំ ។ នីរសារខ្ញុំតែម្នាក់គត់ដែលជ្រើសរើសពីកុមារ និងក្មេងជំទង់កំពង់ឆ្នាំង គឺមិត្តថាន់ ។ មិត្តថាន់ នេះកំណើតនៅខាងកំពង់ឆ្នាំ នៅខាងតំបន់៣១ ។ ឯចំណែក មិត្តឆេនកំណើតគាត់នៅខាងអមលាំង ត្រពាំងគ្រោប យើងខ្ញុំយកមកតាំងពីឆ្នាំ១៩៧៣ ។

ដូច្នេះ នេះជាសភាពនីរសារទាំងប្រាំនាក់របស់គ្នាខ្ញុំបីនាក់នេះ គឺខ្ញុំបាទ មិត្តហ៊ី និង នុន ហ៊ុយ ។

[១៤:៤៩:២៨]

ឯចំណែកពួកខាងកំពង់ឆ្នាំងយើងខ្ញុំយកមកបីនាក់ ដំបូងយកឈ្មោះ មិត្តសំ មក ហ្នឹង ជាកុមារខាងកំពង់ឆ្នាំង ដល់មើលទៅឃើញ មិត្តសំ មិនមានលក្ខណៈសម្បត្តិល្មមនឹងពឹកផ្អែក ហើយជឿបានខ្ញុំ

ប្រគល់ទៅឲ្យខាង មិត្តហ៊ា គេអប់រំកសាងឲ្យទៅជាកងការពារតទៅទៀតទៅ ។ ខ្ញុំយកមួយមកទៀត ឈ្មោះ មិត្តម៉ៅ មើលទៅមិនកើត ខ្ញុំរុញទៅឲ្យ មិត្តហ៊ា ទៀតបានចុងបញ្ចប់ពួកក្មេងអស់នោះខ្ញុំយកបាន មិត្តថាន់ មួយ ។

ដូច្នេះ បីនាក់ខាងកំពង់ឆ្នាំងនេះ ខ្ញុំជ្រើសរើសបានមួយនៅជាប់ជាមួយនឹងខ្ញុំគឺ មិត្តថាន់ ។ នេះខាងកំពង់ឆ្នាំង ។ ដូច្នេះ ខាងកំពង់ឆ្នាំងខ្ញុំស្គាល់បីនាក់នេះច្បាស់ ហើយនិងម្នាក់ទៀតទៅជួបខ្ញុំនៅសំឡូត ឈ្មោះ មិត្តទុយ គេរត់មកប្រាប់ខ្ញុំ ថាគេពីដើមជាកុមាររកត្រកួនឲ្យទន្សាយស៊ី ។ ដូច្នេះ ខាងកំពង់ឆ្នាំង ប្រហែលជា៦០នាក់ៗហ្នឹង មានទាំងកុមារធំអាយុដប់ពីរឡើងលើផង ហើយរហូតដល់ទៅក្មេងជំទង់អាយុដប់ប្រាំពីរចុះក្រោមផង ។ ក្នុងប៉ុន្មាននាក់ ៦០នាក់ហ្នឹង ខ្ញុំស្គាល់បួននាក់នេះច្បាស់ ក្រៅពីនោះខ្ញុំមិនស្គាល់ទេមិនដឹងជាគេចាត់តាំងទៅឯណាខ្លះនៅឡើយទេ ។ ក៏ប៉ុន្តែ គ្រាន់តែសូមបញ្ជាក់ថា ក្នុងចំណោម ៦០នាក់មកពីកំពង់ឆ្នាំងនេះ ក៏ដូចជាពួកមកពីអមលាំងដែរ គ្មាននរណាប៉ានបៀបបបគេ បានពាសវាលពាស កាលក្នុងរឿងចង់ចាប់ចង់ចងអីទេ ព្រោះវណ្ណភាពគេវាធានា ។ នេះសូមបញ្ជាក់បន្ថែមបន្តិចប៉ុណ្ណេះ។ សូមបញ្ចប់ ។

[១៤:៥១:២៥]

**ស៖** ដូច្នេះ និយាយសង្ខេបក្មេងៗនិងអ្នកទាំងអស់នោះពីកំពង់ឆ្នាំង គឺគាត់រកត្រកួនដើម្បីឲ្យទន្សាយស៊ី ។ ហើយនៅក្នុងនោះ គឺជាការងារដែលពួកគេធ្វើនៅស-២១ ។ អ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ការងាររកត្រកួនឲ្យទន្សាយវាជាផ្នែកការងារមួយទ ។ ក្រៅពីនោះមិនដឹងជាធ្វើអីទៀតទេ ខ្ញុំក្តាប់មិនបាន ។ ប៉ុន្តែគ្រាន់តែដឹងថា មានម្នាក់ឈ្មោះមិត្តទុយ រត់មកប្រាប់ខ្ញុំថា ខ្ញុំកូនចៅចាស់របស់បងឯង ។ អង្កាល់ពីនៅស-២១ ខ្ញុំជាអ្នករកត្រកួនឲ្យទន្សាយ ខ្ញុំដឹងថា អូ! មែនមាន ។ ពួកនុ៎ងបួនប្រាំនាក់រកត្រកួនឲ្យទន្សាយ ចិញ្ចឹមទន្សាយច្រើន ។

សរុបមកវិញ អ្នករកត្រកួនឲ្យទន្សាយហ្នឹងមានមួយចំនួនទេ ឯចំណុចផ្សេងទៀត មិនដឹងជាគេធ្វើអីខ្លះទេ ខ្ញុំក្តាប់មិនបាន ។ គ្រាន់តែបញ្ជាក់ឡើងវិញជូនលោកជំទាវថា ពួកនេះគ្មានអ្នកណាប៉ានបៀតបតរាយការណ៍ចាប់ចងអី ពួកខាងកំពង់ឆ្នាំងនេះល្មើសពាសវាលពាសកាលបានទេ-- គ្មានអ្នកណាប៉ានរាយការណ៍រឿងចាប់ចងអីបានទេ ពួកកំពង់ឆ្នាំងហ្នឹងបើតាមខ្ញុំចាំគឺនៅទាំងអស់ ។

**ស៖** ចាតើអ្នកទាំងអស់នោះមានដែលធ្លាប់ធ្វើជាអ្នកយាមនៅខាងក្នុង អ្នកយាមខាងក្នុង និងអ្នកយាមខាងក្រៅដែរឬទេ?

**ឆ៖** ខ្ញុំមិនច្បាស់ទេ ។

**ស៖** ដើម្បីឲ្យអ្នកបារាំងគាត់ច្បាស់លាស់នោះ ថាតើក្មេងៗទាំងអស់នោះមានការធ្វើការជាអ្នកយាមនៅខាងក្នុងនិងអ្នកនៅខាងក្រៅដែរឬទេ? ហើយជនជាប់ចោទឆ្លើយថា គាត់អត់មានការយល់ដឹងច្បាស់ទៅលើបញ្ហានេះទេ ។

សូមអរគុណ ខ្ញុំអស់សំណួរហើយ ។

[១៤:៥៣:៥២]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ខ្ញុំសូមវិលត្រឡប់ទៅលើលក្ខខណ្ឌនិងស្ថានភាពដែលស-២១ បានបង្កើតឡើង ។ ប្រសិនបើខ្ញុំយល់ត្រឹមត្រូវនោះ គឺបុគ្គលិកស-២១ គឺបង្កើតចេញពី គឺរួមមាន គឺវាមានពីបុគ្គលិកមកពីកងពល៧០៣និងបុគ្គលិកមកពីម-១៣ ។ ហើយតាមអ្វីដែលខ្ញុំយល់ត្រឹមត្រូវផងដែរនោះ អ្នកដែលធ្វើការនៅក្នុងភ្នំពេញមុនពេលដែលការដួលរលំភ្នំពេញនោះ គឺត្រូវបានប្រើប្រាស់ជាភ្នាក់ងារស៊ើបអង្កេត ឬភ្នាក់ងារចារកម្ម ។ ថាតើត្រឹមត្រូវដែរ ឬទេចំពោះបញ្ហានេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ការបកប្រែមកជាភាសាខ្មែរ គេថាភ្នាក់ងារស៊ើបអង្កេត ភ្នាក់ងារចារកម្ម ។ ខ្ញុំគិតថាបញ្ហានេះ ដូចជាមិនត្រូវនឹងពាក្យដែលលោកចៅក្រមសួរខ្ញុំ ។ ដូច្នេះ សូមលោកមានប្រសាសន៍ម្តងទៀត ខ្ញុំស្តាប់ជាបារាំងម្តង ។

**ស៖** ខ្ញុំសង្ឃឹមថា សំណួររបស់ខ្ញុំនឹងបកប្រែត្រឹមត្រូវជាភាសាខ្មែរ ។ សំណួររបស់ខ្ញុំដែលខ្ញុំចោទសួរ គឺទាក់ទងទៅនឹងបុគ្គលិករបស់ស-២១ នៅពេលដែលស-២១ បានបង្កើតឡើង ។ ដូច្នេះ ថាតើមានបុគ្គលិកណាខ្លះដែលក្លាយទៅជាបុគ្គលិកស-២១ហ្នឹង? ហើយក្រៅពីបុគ្គលិកមកពីកងពល៧០៣ គឺបុគ្គលិកមួយផ្នែកទៀតមកពីមន្ទីរម-១៣ ។ ប៉ុន្តែ វាហាក់ដូចជា ចំពោះខ្ញុំបានដឹងថាបុគ្គលិកមួយផ្នែកទៀត គឺចេញមកពីសមាជិកបក្សដែលធ្វើការនៅក្នុងក្រុងភ្នំពេញមុនពេលការដួលរលំភ្នំពេញ ហើយក្រោយ មកគឺគាត់បានផ្តល់ព័ត៌មានផ្សេងៗ ។ ហើយតើលោកយល់សំណួររបស់ខ្ញុំ ហើយលោកអាចឆ្លើយបានដែរ ឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! សេចក្តីសន្និដ្ឋានហើយនិងសំណួររបស់លោកចៅក្រមត្រឹមត្រូវហើយ ។ កម្លាំងរបស់ស-២១ កកើតឡើងអំពីកងពល៧០៣ កម្លាំងនេះច្រើនណាស់ច្រើនលើសលប់ ។ ហើយកម្លាំងពីរទៀតតូចៗទេ គឺកម្លាំងខាងពួកក្រុង ហើយនិងកម្លាំងរបស់មន្ទីរ១៣ ។

ហើយក្រោយមក មានថែមពួកក្មេងមកពីកំពង់ឆ្នាំងខ្លះ ។ សរុបមក សំណួររបស់លោកចៅក្រមត្រឹមត្រូវ ។

[១៤:៥៨:២០]

**ស៖** ដូច្នេះ លោកបានពន្យល់អំពីបុគ្គលិកមួយចំនួនរបស់ស-២១ អ្នកទាំងអស់នោះគឺជាជនរងគ្រោះនៃការកម្ទេច ។ ដូច្នេះ តើលោកអាចប្រាប់យើងខ្ញុំដែរឬទេ ថានៅក្នុងចំណោមបុគ្គលិកបីប្រភេទដែលលោកបានលើកឡើងនោះ ហើយប្រភេទនីមួយៗនៃបុគ្គលិកទាំងបីនោះ គឺវាធ្វើឡើងចំពោះបុគ្គលិកកងពល៧០៣ ឬក៏ការកម្ទេចនោះ និងបោសសម្អាតនោះចំពោះសមាជិកម-១៣ ឬក៏សម្រាប់បុគ្គលិកនៅភ្នំពេញ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ការសម្រិតសម្រាំងក្នុងអង្គភាពស-២១ ប៉ះពាល់តែទៅលើកម្លាំងមកពីខាង៧០៣ ទាំងអស់ និងពួកមកពីក្រុងទាំងអស់ ។ ខាងក្រុងនៅសល់តែម្នាក់ទេ ។ ឯចំណែកពួកខាងម-១៣ អត់ប៉ះមួយគ្រាប់ទេ ហើយពួកខាងកំពង់ឆ្នាំងអត់ប៉ះមួយគ្រាប់ដែរ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងបីដប់ប្រាំនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចពិភាក្សាដេញដោលតទៅទៀត ។

*[សវនាការសម្រាកពីម៉ោង១៥:០០ នាទីដល់ម៉ោង ១៥:២៨ នាទី]*

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ។

មានបញ្ហាអ្វីទៅ លោកស្រីមេធាវី?

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្តី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងចូលទៅដល់ និយាយដោយសង្ខេបទៅរកបញ្ហាមួយ យើងខ្ញុំចង់ដាក់ជូននូវឯកសារមួយ ដែលមានកាលកំណត់ចប់នៅថ្ងៃស្អែក គឺជាការឆ្លើយតបទៅនឹងសំណើរបស់សហមេធាវី របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ។ យើងបានបញ្ជូនឯកសារទៅខាងបកប្រែទៅ *អាយស៊ីធី "ICT"* នៅថ្ងៃស្រុកល្ងាច ហើយថ្ងៃនេះ ខ្ញុំបានទទួលការជូនដំណឹងថា ខាងអង្គភាព

បកប្រែនោះប្រាប់យើងថា គេមិនអាចបកប្រែបញ្ចប់បានពីអង់គ្លេស ទៅជាភាសាខ្មែរទេ ។ អង្គភាពនោះបានបញ្ជាក់បង្ហាញថា នៅថ្ងៃទី២៩ ខែមេសា អាចនឹងបញ្ចប់បាន ហើយនិងបកប្រែចប់ ។

[១៥:២៧:៥៧]

ដូច្នេះហើយ ខ្ញុំសុំស្នើអង្គជំនុំជម្រះដើម្បីផ្តល់ឲ្យយើងនូវការពន្យារពេលរហូតទៅដល់ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ដើម្បីយើងខ្ញុំដាក់ជូនឯកសារនេះ ដែលមានភាសាខ្មែរនិងអង់គ្លេស ។ ហើយយើងខ្ញុំនឹងថ្លែងអំណរគុណ ដើម្បីបានសេចក្តីសម្រេចលើបញ្ហានេះថ្ងៃនេះ ។ ពីព្រោះថា យើងខ្ញុំមិនអាចដាក់ជូនបានជាលាយលក្ខណ៍អក្សរទេ ដោយហេតុថា ដោយអង្គជំនុំជម្រះយល់ហើយថា អង្គភាពខាងបកប្រែមិនអាចមានលទ្ធភាពនឹងបកប្រែសំណើនេះ ឲ្យទៅជាភាសាខ្មែរបានទាន់ពេល ។

ដូច្នេះហើយ យើងខ្ញុំសូមប្រើឱកាសនេះ ដើម្បីលើកឡើងនៅថ្ងៃនេះ ។

សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ខាតរាយថ៍ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។

កញ្ញាមេធាវី ស្ទួតហ្វ៊ីនស្គី ឆ្លើយតបទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីមួយ បានដាក់សំណើសុំការណែនាំពីអង្គជំនុំជម្រះថា នៅពេលដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ឯកសារ គប្បីតែបញ្ជាក់ថា តើក្រុមណា ដែលបានដាក់ឯកសារហ្នឹង? ប៉ុន្តែ ខ្ញុំគិតថាឆ្លើយតប ឬក៏ការសម្រេចហ្នឹង ជាសង្ខេបដោយខ្លី ។

**លោកស្រី ស៊ីលឃីស្ទួត ហ្វ៊ីនស្គី៖**

គឺថាមានអត្ថបទតែពីរទំព័រទេ ជាឯកសារខ្លី ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ជាអត្ថបទពីរទំព័រខ្លី តើលោកអាចផ្តល់ចម្លើយខ្លីបានទេ ដើម្បីកាត់បន្ថយការបកប្រែ ហើយនិងកុំឲ្យមានបញ្ហាអីផ្សេង ។

**លោកស្រី ស៊ីលឃីស្ទួត ហ្វ៊ីនស្គី៖**

អំពីខ្លឹមសារនៃឯកសារ?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

តើអ្វីជាចម្លើយរបស់កញ្ញាមេធាវី?

**លោកស្រី ស៊ីលយីស្វត ហ្សិនស្គី៖**

ចម្លើយគឺថា បានបញ្ជាក់អំពីចំនួនលេខក្រុមដើមបណ្តឹងរដ្ឋប្បវេណី នៅខាងដើមទំព័រ គឺជាការសំខាន់ ហើយឯកសារនោះគឺ បង្ហាញដោយបញ្ជាក់ឈ្មោះនាមរបស់មេធាវី ដែលដាក់សំណើ ហើយបង្ហាញថា ជាភាគីដែលដាក់ឯកសារគឺគ្រប់គ្រាន់ ដើម្បីកំណត់យ៉ាងច្បាស់ថាអ្វី ថាអ្នកណាជាអ្នកដាក់ជូនឯកសារនេះ ។ ហើយជាពិសេសទៅទៀត ថាអាចឱ្យមានការច្រឡំបន្តិច បើសិនជាយើងបញ្ជាក់លេខរបស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះយើងបានដឹងទៅហើយ គ្រប់គ្នាមិនជាក្រុមមិនបាន--ថាមិនបានជាសមាជិកនៃក្រុមទាំងអស់តែមួយ ហើយមិនមានគំនិតដូចគ្នាទាំងអស់នោះទេ ។ អ៊ីចឹងគឺថាមួយផ្នែកមួយរបស់ក្រុមមួយ ដែលបានដាក់ជូនជាមួយនឹងក្រុមផ្សេងទៀត ។ល។ និង ។ល។ ការបញ្ជាក់លេខក្រុម ហើយនិងមតិយោបល់ អ៊ីចឹងហើយក្រុមពីរ គឺថាផ្នែកមួយទៀតដែលក្រុមពីរមានមតិយោបល់ម៉េច? គឺថាបើធ្វើអ៊ីចឹង គិតថា អាចនឹងធ្វើឱ្យមានការភ័ន្តច្រឡំ ។ នេះជាសេចក្តីសង្ខេបនៃខ្លឹមសារ ។

[១៥:៣១:៤៤]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ ថាតើដើមបណ្តឹងរដ្ឋប្បវេណីក្រុមណាទៀត ដែលចង់មានមតិយោបល់ឆ្លើយតបអំពីការឆ្លើយតបហ្នឹងដែរឬទេ? តើដើមបណ្តឹងរដ្ឋប្បវេណីក្រុមផ្សេងទៀតៗចង់ធ្វើមតិយោបល់ពីបញ្ហានេះដែរឬទេ?

**លោក អាឡាំង វែនណឺ៖**

លោកស្រីចៅក្រម យើងមិនមានអ្វីបន្ថែមទៀតទេ សំណើរបស់យើងនោះ គឺថាស្រដៀងគ្នាទៅនឹងសំណើរបស់ក្រុមនោះ គឺថាមិនមានអ្វីទេ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីបី ។

**លោក ហ្វីលីព កាណុន៖**

លោកស្រីចៅក្រម សូមអរគុណដែលបានផ្តល់ឱកាសឱ្យខ្ញុំ គឺថាក្រុមទីបីមិនមានមតិយោបល់ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទីបួន ។

**លោក ហុង គីមសួន៖**

ការកត់សម្គាល់របស់ខ្ញុំបាទ គឺមិនមានអ្វីយល់ទាស់ទេ ព្រោះថាឯកសារដែលដាក់គឺសុទ្ធតែបានដាក់ឈ្មោះមេធាវីតំណាងក្រុមរួចហើយ ។ ដូច្នេះ ការមិនបានបញ្ជាក់អំពីក្រុមទីមួយ, ទីពីរ, ទីបី ខ្ញុំបាទយល់ឃើញថាគ្មានបញ្ហាទេ ។ សំខាន់ឈ្មោះមេធាវីនៃក្រុមបានចុះហត្ថលេខា ។ សូមអរគុណ ។

[១៥:៣៣:០៦

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ សហព្រះរាជអាជ្ញា តើលោកមានមតិយោបល់ មិនមានទេ?

មេធាវីការពារ តើលោកមានមតិយោបល់អ្វីទេ?

អត់មានទេ សូមអរគុណ ។

លោកប្រធាន ខ្ញុំសូមស្នើថាយើងទទួលយកនូវសេចក្ដីសង្ខេបនៃចម្លើយតប ហើយចង្អុលបង្ហាញថាយើងនឹងធ្វើសេចក្ដីសម្រេចដោយផ្ទាល់មាត់ នៅក្នុងថ្ងៃស្អែក ឬខានស្អែក ។ ហើយសូមស្នើឱ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទីពីរ មិនបន្តនូវការឆ្លើយតបជាលាយលក្ខណ៍អក្សរទេ មិនបាច់ធ្វើអីចឹងទេ ។

**ប្រធានអង្គជំនុំ៖**

បាទ, យល់ព្រម យើងធ្វើ សម្រេចធ្វើដូច្នេះទៅចុះ ។

ជាកិច្ចបន្ត សូមចូលដល់រឿងពិភាក្សាដេញដោលនៅអង្គហេតុពាក់ព័ន្ធតទៅទៀត ហើយតើលោកចៅក្រមមានសំណួរសួរអ្វីទៅដល់ជនជាប់ចោទ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** មុនពេលយើងសម្រាកនោះ យើងបានជជែកអំពីបញ្ហាមួយចំនួនអំពីបុគ្គលិករបស់ស-២១ ។ លោកបានបញ្ជាក់ថាមានបីរូប មួយមកពីកងពល៧០៣ ដែលជាក្រុមធំ ហើយគឺជាជនរងគ្រោះដែលមានការសម្រិតសម្រាំងជនរងគ្រោះដ៏ច្រើន តើខ្ញុំយល់នឹងត្រូវដែរឬទេ?

ខ្ញុំគិតថា ជនជាប់ចោទបានកត់សម្គាល់ ខ្ញុំមិនដឹងបានកត់ត្រានៅក្នុងប្រតិចារឹក ហើយគឺថាវាមានអង្គភាពមួយគឺថាមានមួយក្រុមទៀតដែលមកពី ម-១៣ ដែលមិនត្រូវបានសម្រិតសម្រាំងទេ តើត្រូវ

ដែរឬទេ?

ខ្ញុំក៏គិតថា សុំឲ្យលោកឆ្លើយជាខ្មែរ សូមមេត្តាកុំឆ្លើយជាភាសាបារាំងអ្វី ។

[១៥:៣៥:៤១]

**ឆ៖** អង្គភាពដែលត្រូវរងគ្រោះដោយសារការសម្រិតសម្រាំងនេះ ធ្លាក់ទៅលើអង្គភាពពីរ។ ខ្ញុំសុំនិយាយម្តងទៀត អង្គភាពដែលត្រូវរងគ្រោះដោយការសម្រិតសម្រាំងនេះ គឺអង្គភាពពីរ ទីមួយគឺអង្គភាព៧០៣ ទីពីរគឺ អង្គភាពពួកមកពីក្រុង ។ ពួកមកពីក្រុងមានគ្នាតិចទេ ក៏ប៉ុន្តែសម្រិតសម្រាំងចង់អស់នៅសល់តែម្នាក់ទេ ឈ្មោះមិត្ត ប៉ាន់ សុខន ហៅ ត្រូវ ។ ចំណែក កងពល៧០៣ គឺអស់ជាង១០០នាក់ជិត២០០ ។ ឯចំណែកមកពីខាងម-១៣ អត់មានប៉ះម្នាក់សោះ ។ ឯចំណែក ពួកក្មេងៗមកពីខាង៣១តាមខ្ញុំចាំគ្នាប៉ះម្នាក់ដែរ ព្រោះដូចមិនបានទរណាប៉ះពួកក្មេងៗអស់នេះទេ ។ នេះខ្ញុំសូមសរុបប៉ុណ្ណេះ ។

**ស៖** ដូច្នេះបើខ្ញុំយល់តាមអ្វីដែលលោកឆ្លើយនោះត្រឹមត្រូវ គឺអ្នកដែលមកពីក្រុង ក៏ត្រូវបានសម្រិតសម្រាំងមុនបង្កើតស-២១ តើត្រូវឬទេ?

*(មានបញ្ហាមៃក្រូហ្វូន)*

តើលោកស្តាប់បានទេ?

**ឆ៖** ស្តាប់បាន ។

**ស៖** ខ្ញុំនឹងសួរម្តងទៀត តើបុគ្គលិកដែលមកពីក្រុង ត្រូវបានសម្រិតសម្រាំងមុនការបង្កើត ស-២១ ដែរឬទេ?

**ឆ៖** ពួកកងការពារក្រុងនេះ ចូលមកស-២១ ក្រោយដែល ស-២១ កើត។ ក៏ប៉ុន្តែ មុននឹង ណាត គាត់ចេញ ។

ដូច្នេះ ការសម្រិតសម្រាំងពួកនេះ ហូរហែមករហូតដល់ពេលដែល ណាត គាត់ចេញទៅនៅសល់តែប្រហែលជាពីរនាក់បីនាក់អីប៉ុណ្ណឹងទេ ដល់រឿងហ្នឹងចេដក់តៗមក ក្រោយដែល ណាត គាត់ទៅចេញក៏បង្ហើយ នៅសល់តែម្នាក់គត់ ។

**ស៖** តើការសម្រិតសម្រាំងហ្នឹងធ្វើឡើងនៅក្នុង ស-២១ ចាប់ផ្តើមពីការឃុំឃាំង ហើយនិងសម្លាប់តាមរយៈ ស-២១ ថាតើការសម្រិតសម្រាំងដូម្តេច?

**ឆ៖** បុគ្គលិករបស់មន្ទីរស-២១ គឺស-២១ ជាអ្នកចាប់, ស-២១ ជាអ្នកដាក់គុក, ស-២១ ជាអ្នកសួរដោយមានទារុណកម្ម ហើយចុងបញ្ចប់ក៏ស-២១ កម្ទេចដែរ ។ វាគ្រាន់តែខាងលើជាអ្នកសម្រេច

តែប៉ុណ្ណឹងឯង ។

[១៥:៣៩:៥៦]

**ស៖** ថាតើដំណើរការដូចគ្នាអនុវត្តចំពោះអ្នកដែលមកពីកងពល៧០៣ ដែរឬទេ?

**ឆ៖** គ្មានអត់ខ្លាចអីទេ ។

**ស៖** ថាតើសេចក្តីសម្រេចនាំយកក្មេងៗមកធ្វើការគាំទ្រទៅលើបុគ្គលិកនោះ ដោយសារតែក្មេងៗត្រូវបានគេចាត់ទុកថាមានប្រវត្តិល្អមិនដូចនឹងបុគ្គលិកផ្សេងៗដែលត្រូវបានគេសម្រិតសម្រាំង?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រមរឿងនេះ គឺពិតជាអ៊ីចឹង តាមសំណើ-- ជាសំណូមពររបស់ខ្ញុំចំពោះលោកគ្រូ សុន សេន គាត់ក៏ឯកភាពឲ្យខ្ញុំទៅសុំ ក្នុងគោលបំណងរកអ្នកដែលមាន-- រកៗអ្នកដែលមានប្រវត្តិរូបស្អាតស្អំអ៊ីចឹង គាត់ឯកភាព ។ ដូច្នេះ ខ្ញុំទៅគឺសំដៅសំខាន់គឺរកអ្នកដែលមានប្រវត្តិរូបស្អាតស្អំហ្នឹងឯង ។

**ស៖** តើផ្អែកលើអ្វី ហើយនរណាគេជាអ្នកធ្វើសេចក្តីសម្រេចថាបុគ្គលិកមកពីក្រុង ឬក៏បុគ្គលិកមកពីអង្គភាព៧០៣ មិនមានប្រវត្តិស្អាតស្អំ?

**ឆ៖** លោកចៅក្រមជាទីគោរព! សូមបញ្ជាក់ថា បុគ្គលិកមកពីកងពល៧០៣ មានលេខាម្នាក់មុន ណាត ត្រូវកម្ទេច ។ លេខាម្នាក់ដែលមុន ណាត ហ្នឹងគឺឈ្មោះ នៅ ផន ហៅ សុខ ជាលេខាកងពល១២ មុន ណាត ដល់មេធំត្រូវកម្ទេចហើយ វាតែងមានកូនចៅតមកក្រោម ។ នៅពេលដែលអស់មេសំខាន់ៗយ៉ាងនេះ កូនឲ្យតែធ្វើខុសអីតិច ខាងក្រោមចេះតែព្រួយហើយ ។ ដូច្នេះ តែកាលណាពួកនេះធ្វើខុសអីបន្តិចមិត្តហ៊ុ តែងតែចាប់អារម្មណ៍ ត្រូវរាយការណ៍ឲ្យខ្ញុំ ។ ហើយបើសិនជា មិត្តហ៊ុ គ្នាមិនរាយការណ៍ទេ ថ្ងៃក្រោយធ្លោះធ្លោយ គ្នាវារងគ្រោះ ។ ដូច្នេះ តែកាលណារាយការណ៍មកដល់ខ្ញុំៗរាយការណ៍ទៅដល់លើ ខាងលើសម្រេច តែកាលណាគេសម្រេចកម្ទេច យើងខ្ញុំមិនចាប់ មិនដាក់គុក មិនបានទេ ។

[១៥:៤៤:៥៥]

សូមបញ្ជាក់ថា ពួកកងពល៧០៣ អង្គភាពរបស់ មិត្តហ៊ុ របស់គេផ្ទាល់ដែលចូលរួមចំណែកមកស-២១ អត់មានប៉ះពាល់ ។ សូមបញ្ជាក់ម្តងទៀតថា អង្គភាពដែលមកពី៧០៣ កូនចៅ ហ៊ុ ផ្ទាល់របស់គេ គេធានាប្រវត្តិរូបអត់មានប៉ះពាល់ទេ ។ ដូច្នេះ វារងគ្រោះតែអ្នកណាដែលបាត់មេ ។ ដែលគេមិនក៏ទុកចិត្ត ខ្ញុំក៏មិនទុកចិត្ត ។ ដែលខ្ញុំនិយាយ “គេ” គឺសំដៅ មិត្តហ៊ុ ដែលមិត្តហ៊ុ ក៏គាត់មិនទុកចិត្ត ខ្ញុំក៏មិនទុកចិត្ត ។ នេះពួក៧០៣ ដែលទទួលរងគ្រោះថ្នាក់គឺប្រភេទហ្នឹង ។

ហើយពួកមកពីក្រុងអត់មានមេមកទេ ។ ដូច្នេះ សកម្មភាពមិនដាច់ខាត ហើយគ្នាមិនដាច់ខាតមែន ក្នុងរឿងបទឧក្រិដ្ឋដែលគេឲ្យសួរឲ្យអី ហើយចេះតែមាត់កតវ៉ាហ្នឹងនាយអាយថែមទៀត ។ ដូច្នេះ មាត់កថែមទៀតធ្វើឲ្យ ណាត គាត់ចាប់អារម្មណ៍ គាត់រាយការណ៍ ។ ដូច្នេះ ពួកនេះក៏ត្រូវបានសម្រិតសម្រាំងមុននឹង ណាត មួយរយៈ ។ ដល់ក្រោយមកបន្តទៅទៀត ហ៊ ហើយនិងខ្ញុំឯកភាពគ្នារាយការណ៍តែទៅទៀត ចប់នៅសល់តែមួយហ្នឹងឯង សល់តែ មិត្តត្រូវ ។ សរុបមក ថ្នាក់ក្នុងរឿងសម្រិតសម្រាំងនេះ គឺផ្លាក់ទៅលើកងពល ភាគមួយចំណែករបស់កងពល៧០៣ ហើយនិងពួកមកពីក្រុង ។

[១៥:៤៨:៤១]

**ស៖** កែតម្រូវខ្ញុំប្រសិនបើខ្ញុំនិយាយខុស ខ្ញុំយល់អំពីពាក្យថា “សម្រិតសម្រាំង” គឺមានវិន័យនិងច្បាប់ទម្លាប់ ។ នៅពេលដែលសមាជិកគ្រួសារត្រូវបានគេចាប់ខ្លួន ហើយកម្ទេចចោលសមាជិកផ្សេងទៀតនៅក្នុងគ្រួសារក៏ត្រូវទទួលរងនូវចំណុចនេះដូចគ្នាដែរ ។ ដូច្នេះហើយគឺ តើលោកបញ្ជាក់ទៅលើចំណុចនេះដែរឬទេ?

**ឆ៖** គឺកម្លាត់ គេសម្រិតសម្រាំងតាមខ្សែគ្រួសារ ។

**ស៖** លោកក៏បានបញ្ជាក់ផងដែរថា គោលការណ៍នៃការសម្រិតសម្រាំងក៏អនុវត្តទៅតាមខ្សែទំនាក់ទំនង ហើយប្រសិនបើមានបញ្ហាដល់អ្នកដឹកនាំ ឬក៏មេ កូនចៅក៏មានមេបញ្ហាផងដែរ ។ ហើយលោកក៏បានទទួលទៅលើចំណុចនេះផងដែរ ប៉ុន្តែប្រហែលខ្ញុំយល់ខុសហើយ សុខ គឺជាប្រធានត្រូវបានគេសម្រិតសម្រាំង ។ ហើយខ្ញុំដឹងថាគឺគាត់ជាបុគ្គលទីមួយដែលត្រូវគេសម្រិតសម្រាំង ហើយបន្ទាប់មកគឺមានបុគ្គលផ្សេងៗដែលជាប់ពាក់ព័ន្ធគាត់ត្រូវបានគេសម្រិតសម្រាំងផងដែរ ។ តើត្រឹមត្រូវដែរឬទេចំពោះអ្វីដែលខ្ញុំយល់នេះ?

**ឆ៖** ជម្រាសប្រសាសន៍ៗលោកចៅក្រមដំបូង សុខ ត្រូវសម្រិតសម្រាំង នេះគឺជាការពិត ។ ដល់ សុខ ត្រូវសម្រិតសម្រាំងអ៊ីចេះ អាកម្មាភិបាលខាងក្រោម ខាងលើគេតាមដាន ថ្នាក់ដឹកនាំមជ្ឈិមបក្សគេតាមដាន ។ មនុស្សយើងកាលណាគេតាមដានហើយ ចៀសមិនរួចពីខុសទេ ចៀសមិនរួចពីងាប់ទេ ដូច្នេះ តែមេគេចាប់ហើយ យូរឬឆាប់កូនទៅហើយ ។ នេះជាក្រឹត្យក្រមនៃការសម្រិតសម្រាំងជំនាន់នុ៎ង ។

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** ដែលនៅជាមួយនឹង មិត្តហ៊ា នៅជាមួយនឹងខ្ញុំ តែកាលណាឃើញភេទណាមួយដែលទាស់ និយាយមិនស្តាប់ ទាស់ជាបន្តបន្ទាប់ បើសិនជាយើងទុកដល់ថ្ងៃក្រោយអាចគ្រោះថ្នាក់ដល់យើង ។ តែកាលណាតែយើងខ្ញុំរាយការណ៍ទៅហើយ ខាងលើសម្រេចហើយ ។ ខ្ញុំសូមបញ្ជាក់ថា តើស្អីដែលទាស់ល្មមតែទ្រាំមិនបាន? ឧទាហរណ៍ ហាមមិនឲ្យវាយអ្នកទោសឲ្យស្លាប់ដាច់ចម្លើយ ។ អ្នកដែលរងគ្រោះដោយ-- អ្នកដែលត្រូវចាប់ចងដោយប្រការនេះមានពីរនាក់ បើតាមខ្ញុំចាំ ។ ដូចជាឈ្មោះ មិត្ត ខឹម ផូ នេះមួយអនុសេនាធំ កម្មាភិបាលអនុសេនាធំ ហើយមួយទៀតឈ្មោះ មិត្តហាក់ មិនដឹងត្រកូលស្អីទេ ។ ដូច្នេះ តែកាលណាឃើញទាស់ ។

[១៥:៥៥:០២]

សរុបមក ពួកកម្មាភិបាលមកពីកងពល៧០៣ ដែលទាស់នឹងច្រើនតែធ្វើៗរបៀបជាអ្នកដាច់ខាតខ្លាំងពេក បង្អួតខ្លាំងពេក ទប់មិនជាប់ ។ ក៏ប៉ុន្តែ និយាយបែបនេះវាហាក់ដូចជាយើងទម្លាក់កំហុសទៅលើគ្នាអ្នករងគ្រោះដែលស្លាប់ទៅហើយ ។ យើងជាអ្នកអប់រំ យើងជាអ្នករាយការណ៍ យើងមានចំណែកនៅក្នុងឧក្រិដ្ឋកម្មនេះជាប្រាកដ ។ យើងមិនពុះពារអប់រំគេឲ្យស្រួល ឲ្យជាប់លាប់ ឲ្យខ្លាំងក្លា តែបែជាប្រញាប់រាយការណ៍សុំសេចក្តីសម្រេច ។ អាហ្នឹងជាកំហុសមួយ ជាឧក្រិដ្ឋកម្មមួយ ។ ផ្ទាល់ខ្លួនខ្ញុំ ខ្ញុំចេះភ័យដែរ នៅពេលដែលគេចាប់ វន វេត ចុះម៉េចក៏ខ្លួនខ្ញុំ ខ្ញុំមិនមើលឃើញគេអ្នកផ្សេងទៀតហ្នឹងដែលមេត្រូវចាប់ហើយខ្ញុំខំអប់រំ។ យើងធ្វើការយករួចតែខ្លួន គិតតែជីវិតខ្លួនឯងថ្លៃពេក ។ បានសរុបមក គឺពួក៧០៣ ហើយនិងពួកក្រុមហ្នឹងឯងដែលគ្នារងគ្រោះ ។

សរុបមក កំហុសដែលនាំឲ្យចាប់ចងវាមាន ទីមួយ គឺគេវាមានកម្មាភិបាលអឺចឹងទៅហើយ ។ កម្មាភិបាលគ្នាវាត្រូវគេចាប់ចងអឺចឹងទៅហើយ អាគ្នាវារងនូវថ្មបាក់អឺចឹង ។ ខ្លួនយើងអ្នកអប់រំ យើងអត់អប់រំគេ អាហ្នឹងក៏វាមានភាគចំណែកសំខាន់ វាមានតួនាទីទទួលខុសត្រូវក្នុងឧក្រិដ្ឋកម្មនេះទៅលើអាយុជីវិតគេដែរ ។ ដូច្នេះ ខ្ញុំសូមសរុបប៉ុណ្ណឹង ចំពោះរឿងអ្នកដែលត្រូវសម្រិតសម្រាំងក្នុងស-២១ ប្រហែលជា២០០នាក់ ។

**ស៖** នៅពេលដែលលោករាយការណ៍ចំពោះអំពើដែលមិនសមរម្យទៅថ្នាក់លើរបស់លោក តើលោកដឹងដែរឬទេ ថាការរាយការណ៍នេះ គឺវាមានន័យយ៉ាងម៉េច? វានាំទៅដល់យ៉ាងម៉េច? ថាតើលោកដឹងថា បុគ្គលិកទាំងនោះនឹងត្រូវគេកម្ទេចដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! កាលណាខ្ញុំរាយការណ៍ទៅដោយមានហេតុផលថាមិត្ត ហ៊ី គេពិនិត្យអីចេះ ខ្ញុំក៏យល់ស្របអីចុះ មិនដែលខានទេគឺត្រូវតែសម្រេចឲ្យចាប់ គឺត្រូវសម្រេចឲ្យចាប់។ ទីមួយប្រាប់ថា ពួកនេះកម្មាភិបាលវានេះ ។ ទីពីរ សកម្មភាពនេះអីចេះ ហើយអប់រំបែបនេះមិនស្តាប់ តែកាលណារាយការណ៍ទៅ ទាំងពីរនាក់រាយការណ៍ទៅហើយ ខ្ញុំក្នុងនាមគណៈនេះរាយការណ៍ ទៅហើយគឺទៅហើយ គ្មាមិនដែលខាន ។

**ស៖** ខ្ញុំមិនទាន់ច្បាស់ថា លោកប្រាកដជាឆ្លើយសំណួររបស់ខ្ញុំទេ ប៉ុន្តែមិនបញ្ហាទេ ។ ខ្ញុំចង់ដឹងទៀតថា តើពេលណាការរាយការណ៍នេះចាប់ផ្តើមធ្វើពេលណា របបរាយការណ៍នេះ? តើបានចាប់ផ្តើមមុនការចេញទៅរបស់ ណាត ឬក៏ក្រោយពេលដែល ណាត ចេញទៅបាត់នោះ?

[១៦:០០:៥០]

**ឆ៖** សម័យ ណាត គេនៅធ្វើប្រធាន គេអ្នករាយការណ៍ ។ ដោយឡែក មានរឿងមួយដែលវែងបន្តិច ប៉ុន្តែ ឥឡូវខ្ញុំសុំគ្រាន់តែជម្រាបតែមួយមាត់សិនទេ ណាត មានលក់-- ណាត មានសម្រេចចាប់ចងយុទ្ធជន និងកម្មាភិបាលកងពល១២ គឺអតីតកងពល៧០៣ នេះដោយអត្តនោម័តិ ។ ដូច្នេះ ចំពោះ ណាត គាត់មានអាសុំយោបល់មេក៏មាន មានអាលួចចាប់មិនឲ្យមេដឹងក៏មាន ។ ហើយចំណែកខ្ញុំ តាំងពី ណាត ចេញទៅ ទាល់តែទទួលការសម្រេចពីមេសិនបានខ្ញុំបញ្ជាឲ្យ ហ៊ី អនុវត្ត ។

**ស៖** សូមលោកប្រាប់យើងបន្ថែមទៀត តើមានភាពខុសគ្នាអ្វីជាសំខាន់ដែរឬទេ? នៅក្នុងការអនុវត្តការងារ តើភាពខុសគ្នាក្នុងការប្រព្រឹត្តិទៅរវាងម-១៣ ហើយនិងស-២១ តើលោកជ្រាបបានសំណួរហ្នឹងច្បាស់ដែរឬទេ?

**ឆ៖** ខ្ញុំសូមសាកល្បងនិយាយចំណុចមួយទៅចំណុចមួយ រាយការណ៍ជូនលោកចៅក្រម។ ដំបូងខ្ញុំសូមនិយាយពីធាតុដូចគ្នា ។ លក្ខណៈដូចគ្នា គឺការអប់រំ ។ យើងខ្ញុំបានយុវជនក្មេងៗយកមក យើងខ្ញុំអប់រំ ។ ការអប់រំនេះ គឺសំដៅទៅរកទិសឃោរឃៅដាច់ខាត ឧក្រិដ្ឋ ដោយប្រើពាក្យកុម្មុយនីស្ត ។

ដូច្នេះ នៅក្នុងអង្គភាពណាក៏ដូចអង្គភាពណាដែរ ការអប់រំ វាដើរតួសម្រាប់ធ្វើមនុស្ស, មនុស្សស្លូតសោះ ទៅធ្វើមនុស្សឲ្យឃោរឃៅ ។ មនុស្សកូនកសិករគ្នាត្រឹមត្រូវ យើងយកមកអប់រំឲ្យគេទៅជាបក្ខជន ឲ្យទៅជាសម្ព័ន្ធយុវកក ។ ដូច្នេះ យើងយកយុវជនមកបង្វឹកបង្ហាត់ឲ្យគេប្រកាន់ធាតុដាច់ខាត ប៉ានសម្លាប់ ប៉ានសួរចម្លើយ ប៉ានចាប់ ប៉ានធ្វើអីទាំងអស់ ។ ដូចជា យុវជននៅអមលាំងអ៊ីចឹង យើងខ្ញុំយកមកអប់រំគេ បង្វឹកគេនៅក្នុងចលនាឃោរឃៅ ចលនាកាប់សម្លាប់មនុស្ស ចលនាឃុំឃាំង

មនុស្ស ។ ដូចយុវជននៅខាង កំពង់ឆ្នាំងគ្នាមកក្មេងៗ យើងខ្ញុំយកមកអប់រំ ។ ជាក់ស្តែងនៅជាមួយនឹងខ្ញុំប៉ុន្មាននាក់ អាហ្នឹងយើងក្តាប់បាន ក៏ប៉ុន្តែជាទូទៅយើងអាចនិយាយមួយមាត់ពួកនេះ ប្រែធាតុអស់ហើយៗ ។ ប្រែពីស្លូតបូតទៅជាឃោរឃៅដាច់ខាតក្នុងរឿងចាប់ចង កាប់សម្លាប់ ត្បះតិះដៀលមនុស្សគឺគេហៅថា មានជំហរវណ្ណៈ ។

ដូច្នេះ សរុបមកគេនៅកន្លែងណាខ្លះគេត្រូវទទួលការចាត់តាំងឲ្យទៅត្រង់ណា ខ្ញុំផ្ទាល់ខ្លួនអត់ដឹងមែន ក៏ប៉ុន្តែអ្នកណាអប់រំ គឺខ្ញុំអ្នកអប់រំជាទូទៅ ឲ្យគេទៅអ៊ីចឹង ឲ្យគេដាច់ខាតអ៊ីចឹង ។

[១៦:០៧:៤៥]

**ស៖** ដូច្នេះ ការប្តូរមនុស្ស គឺថាខ្ញុំអាចប្រើថា ការអប់រំជាការបំប្លែងមនុស្សៗ ដែលលោកបានបញ្ជាក់ខាងដើមនេះ បានកើតឡើងនៅម-១៣ ហើយបន្តកើតឡើងទៀតនៅស-២១ អំពីនីតិវិធីអប់រំមនុស្សបំប្លែងអ៊ីចឹងបន្តទៀតនៅស-២១ ។ ដូច្នេះ តើមានចំណុចណាផ្សេងទៀតដែលថាវាមានលក្ខណៈស្រដៀងគ្នារវាងស-២១ ហើយនិងម-១៣ ដែរទេ? ឬក៏មានភាពខុសគ្នាអ្វីដែរឬទេ ចំពោះរូបលោក? តើមានបញ្ហាកើតឡើងដូចម្តេច? ថាតើ ស-២១ បន្តនូវអ្វីដែលកើតឡើងនៅម-១៣ ឬយ៉ាងដូចម្តេច?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! លក្ខណៈដែលស-២១ វាតំណអំពីលក្ខណៈនៅម-១៣ ការដែលអប់រំបំពាក់បំប៉នយុវជនឲ្យទៅទិសឃោរឃៅ ទិសឧក្រិដ្ឋនេះបន្ត ។ ទីពីរ របៀបលក្ខណៈសួរចម្លើយដែលមានទារុណកម្ម ហើយនិងការខំនិយាយបញ្ចុះបញ្ចូលភូតភរនៅពេលសួរនេះវាបន្តពីម-១៣ ។ ឯចំណែកបញ្ហាផ្សេងខ្លះទៀត វាឯកភាពដូចគ្នាជាមួយនឹងមន្ទីរនគរបាលរបស់ខ្មែរក្រហមទូទាំងប្រទេស ។

ខ្ញុំនិយាយថាដូចគ្នាទូទាំងប្រទេសនេះ មិនមែនបានន័យថាខ្ញុំបានទៅមើលឃើញទេ ក៏ប៉ុន្តែស្តាប់ដំណឹងមកដូចតែគ្នា ដូចជា វិធីសម្លាប់យ៉ាងម៉េច វ៉ៃយ៉ាងម៉េច ។ ជាពិសេស រឿងដែលពិសេសរបស់គេដែលខាងកងពល៧០៣ គេនាំយកមកទុកជាស្នាដៃរបស់គេ ទុកជាជំនាញរបស់គេនៅស-២១នេះ គឺបច្ចេកទេសខាងចាប់ ព្រោះគេជាកងពិសេស។ បច្ចេកទេសខាងសម្លាប់ក៏មានលក្ខណៈពិសេសរបស់គេមួយដែរ ។ ឯចំណែក របៀបឃុំឃាំងស្អីៗហ្នឹង ខ្ញុំមើលទៅៗ គឺអារបៀបឃុំឃាំងរបៀបអីៗហ្នឹង វាបន្តតាំងពីមន្ទីរកងពល៧០៣មក មន្ទីរនគរបាលកងពល៧០៣មក ហើយក៏ប្រហែលជាដូចគ្នាហ្នឹងទូទាំងប្រទេសដែរ ។

សរុបមក របស់ដែលប្លែកពីមន្ទីរនគរបាលផ្សេងទៀត គឺរបៀបធ្វើឯកសាររបៀបសរសេរ ឲ្យគេសរសេរកំណត់ចម្លើយ ហ្នឹងដែលប្លែកច្បាស់ ។

**ស៖** ដូច្នេះ វាមានមន្ទីរសន្តិសុខទូទាំងប្រទេសកម្ពុជា ដែលអនុវត្តវិធីដូចគ្នា តើអាហ្នឹងជាអ្វី ដែលលោកបញ្ជាក់ឬទេ? តាមលោកផ្ទាល់ តើគេបានបង្គាប់ឲ្យ ដើម្បីឲ្យបន្តនូវការទទួលខុសត្រូវ ដើម្បីចាត់ចែងស-២១ សម្រាប់មូលហេតុណាមួយដែលគេជ្រើសតាំងលោកឲ្យចាត់ចែងគ្រប់គ្រងស-២១ នោះ?

[១៦:១៣:៣៥]

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា សំណួរនេះលោកចៅក្រម ម៉ាកសែល ឡឺម៉ុងដ៍ លោកសួរខ្ញុំម្តង ។ ខ្ញុំឆ្លើយតាមការយល់នៅពេលនោះ គឺខ្ញុំឆ្លើយជម្រាបលោកចៅក្រម ម៉ាកសែល ឡឺម៉ុងដ៍ ថាមកពីខ្ញុំសួរបានល្អចេះសួរៗជាង ណាត ។ ក៏ប៉ុន្តែ ក្នុងការដែលខ្ញុំពិនិត្យបច្ចុប្បន្ននេះ មិនមែនបញ្ហាប៉ុណ្ណឹងទេ ។ ទីមួយ គឺខ្ញុំពិតជាសួរល្អជាង ណាត ។ បង្រៀនគេឲ្យសួរបានល្អជាង ណាត ។ នេះប្រាកដ ខ្ញុំអត់បដិសេធទេ ក៏ប៉ុន្តែបើតាមខ្ញុំពិនិត្យមើលបកទៅក្រោយវិញ គេអត់ទុកចិត្ត ណាត គេអត់ទុកចិត្ត ណាត តែហ្នឹងគេទុកចិត្តខ្ញុំ ។ មេខ្ញុំលោកគ្រូ សុន សេន ដល់ពេលដែល ណាត ចេញទៅគាត់ចេះតែនិយាយថា ណាត សម្បូរល្បិចៗ ។ ដូច្នេះ គេជឿទុកចិត្តខ្ញុំ ព្រោះខ្ញុំត្រង់ហ្នឹងគេ ត្រង់ៗ អ្វីបើថា បើថាឫស្សីវាគង់មានថ្នាំង ឯចំណែក ខ្ញុំដូចស្លឹកខ្ទឹមអីចឹងអត់មានថ្នាំងទេ ត្រង់នឹងបក្សសុខចិត្តស្លាប់ជាជាងនិយាយភរ ។

ដូច្នេះសរុបមក ដែលគេប្រគល់ឲ្យខ្ញុំកាន់កាប់អង្គភាពរបស់ ណាត គឺគេជឿទុកចិត្តខ្ញុំ ដោយសារត្រង់ហ្នឹងជាសំខាន់ ។ សូមអស់ចម្លើយប៉ុណ្ណេះ ។

[១៦:១៧:១២]

**ស៖** លោកបាននិយាយអំពី ចំណាងចុងក្រោយមួយដែលថា លោកបានផ្តល់ចម្លើយទៅក្នុងការសួរចម្លើយរបស់ចៅក្រម ឡឺម៉ុងដ៍ ហើយខ្ញុំនឹងអាននៅក្នុងលេខ D11 នៃសំណុំរឿងមួយ ដែលលោកបានផ្តល់ចម្លើយទៅចៅក្រម ម៉ាកសែល ឡឺម៉ុងដ៍ នោះជាភាសាបារាំងនៅក្នុងទំព័រលេខបី នៃអត្ថបទកត់សម្គាសនៃ ERN លេខដូចខាងក្រោមនេះ 00147894 ។ ខ្ញុំមិនមានលេខ ERN សម្រាប់ភាសាខ្មែរ និងអង់គ្លេសទេ ប៉ុន្តែ ខ្ញុំនឹងអានប្រហែលលោកចៅក្រមផ្សេងទៀតអាចតាមទាន់។ សំណួរនោះ គឺដូចខាងក្រោមនេះ៖

ហេតុអ្វីបានជា ណាត ត្រូវបានដាក់ជំនួសនោះ? មូលហេតុជាផ្លូវការនោះគឺថា គាត់ត្រូវទៅមើលខាងទំនាក់ទំនងខាងយោធា ខាងអង្គភាពទំនាក់ទំនងវិទ្យុ ទំនាក់ទំនាក់ទំនងខាងយោធាទូទាំងប្រទេស ណាត ទៅធ្វើការងារហ្នឹង ។ ហើយគាត់មិនមានសមត្ថភាពធ្វើជាអ្នកសួរចម្លើយទេ ប៉ុន្តែគាត់

ពូកែខាងយោធា ខាងកិច្ចការយោធា ។ ដោយហេតុថា ពីមុននោះគាត់ជាមេកងពល នេះជាមូលហេតុដែលគេដូរគាត់ចេញពីកន្លែងហ្នឹង ពីស-២១ហ្នឹង ។ ហើយខ្ញុំបានមានជំនាញខាងសួរចម្លើយ ហើយខ្ញុំបានធ្វើការងារនេះតាំងពីឆ្នាំ១៩៧១ មកម្ល៉េះ ។ ហើយជាពិសេសទៅទៀត ណាត មិនចង់ធ្វើការងារសួរចម្លើយនេះទេ ហើយខ្ញុំមានការចាប់អារម្មណ៍ថា ទោះជាខ្ញុំស្អប់ការងារហ្នឹង ស្អប់ការងារសន្តិបាលហ្នឹងជាអ្នកសួរចម្លើយហ្នឹងក៏ដោយ ខ្ញុំត្រូវតែធ្វើការងារហ្នឹង ។ ហើយខ្ញុំបានធ្វើការងារហ្នឹង ការងារហ្នឹងល្អជាង ណាត ។ ខ្ញុំត្រូវតែធ្វើការងារហ្នឹង គឺជាការងារដែលចៀសមិនរួច វាមិនមែនជាការបញ្ជាទេ ប៉ុន្តែពេលនោះខ្ញុំត្រូវតែទទួលការងារហ្នឹង ។

តើនេះជាខ្លឹមសារដែលលោកបានឆ្លើយទៅចៅក្រម ឡឺម៉ុងដ៍ អ៊ីចឹងទេ តើមែនទេ?

[១៦:២០:៤៩]

**ឌ:** ពាក្យទាំងប៉ុន្មាន ដែលលោកចៅក្រមអាន គឺពិតជាចេញពីដួងចិត្តរបស់ខ្ញុំ ដែលខ្ញុំឆ្លើយជម្រាបលោកចៅក្រម ឡឺម៉ុងដ៍ ។ ខ្ញុំពិតជាចាំថា ខ្ញុំមានឆ្លើយមួយម៉ាត់ទៀត ខ្ញុំថា ខាងលើគេគិតយ៉ាងម៉េចគេដក ណាត ខ្ញុំអត់ដឹងទេ ។ នេះជាពាក្យដែលខ្ញុំឆ្លើយជាមួយនឹងលោកចៅក្រម ម៉ាកសែល ឡឺម៉ុងដ៍ ។ ដោយឡែកមានរឿងមួយទៀត ដូចជាលោកចៅក្រមអានមិនទាន់ដល់ គឺខ្ញុំបានស្នើសុំឲ្យមេខ្ញុំលោកគ្រូ សុន សេន យក ឆាយ គឹមហ៊ី មកដាក់ជំនួស ណាត ពីលើខ្ញុំ ខ្ញុំនៅធ្វើអនុប្រធានតទៅទៀត ។

សូមបញ្ជាក់ជូនលោកចៅក្រមថា ឆាយ គឹមហ៊ី នេះក៏ជាកូនសិស្ស សុន សេន ក៏ជាមនុស្សម្នាក់ដែលសុន សេន អប់រំៗបានមុនខ្ញុំទៅទៀត គឺជាកូនសិស្ស ដែល សុន សេន អប់រំខាងផ្លូវកុម្មុយនីស្តមុនខ្ញុំទៅទៀត ។ ហើយគឺ ឆាយ គឹមហ៊ី នេះមកអប់រំខ្ញុំខាងកុម្មុយនីស្ត ។ ដូច្នេះហើយបានជាពេលដែលលោកគ្រូ សុន សេន ប្រគល់ឲ្យខ្ញុំកាន់កាប់ ស-២១ ខ្ញុំតក់ស្លុត ខ្ញុំអត់ចង់ធ្វើមែនអាពេលហ្នឹង ។ នេះជាពេលមួយដែលខ្ញុំប្រកែក ។ ក៏ប៉ុន្តែ អត់ប៊ានប្រកែកចំមុខទេគឺប្រកែកដោយសុំបង គឹមហ៊ី មកធ្វើប្រធាន ។ នៅពេលនុ៎ង លោកគ្រូ សុន សេន កំហែងឲ្យខ្ញុំមួយម៉ាត់ ខ្ញុំដូចជាបានជម្រាបលោកចៅក្រមព្រឹមមិញហើយថា សុន សេន គាត់កំហែងឲ្យខ្ញុំថា ស្អីហ្នឹង ឌុច នេះ! ស-២១ ហ្នឹងវាធំប៉ុនណា? ដល់គាត់និយាយអ៊ីចឹងមក ខ្ញុំលែងប៊ានទាមទារតទៅទៀត បង្ខំចិត្តធ្វើទៅ ។

សរុបមក ពាក្យដែលលោកចៅក្រមអានទាំងប៉ុន្មាន គឺជាពាក្យរបស់ខ្ញុំឆ្លើយជម្រាបលោកចៅក្រម ម៉ាកសែល ឡឺម៉ុងដ៍ ត្រឹមត្រូវតាមគំនិតខ្ញុំ។ ក៏ប៉ុន្តែគ្រាន់តែពេលនេះ ខ្ញុំងាកទៅក្រោយវិញខ្ញុំឃើញខាងលើគេទុកចិត្តខ្ញុំ គេមិនទុកចិត្ត ណាត យើងនិយាយភាសាឲ្យសាមញ្ញស្តាប់ទៅ ខ្ញុំដូចជា *ប៉ើកហ្សេ*

របស់គេអ៊ីចឹង ។

[១៦:២៥:០០]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ពេលត្រូវឈប់សម្រាកនៅពេលល្ងាចហើយ ។ អង្គជំនុំជម្រះសាលាដំបូង សូមប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ ហើយសវនាការនឹងលើកបន្តទៅព្រឹកថ្ងៃស្អែកទី២៨ ខែមេសា ឆ្នាំ២០០៩ ចាប់ពីម៉ោងប្រាំបួនព្រឹកទៅ ។

អង្គជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់ត្រឡប់មកកាន់ទីនេះ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនជាកំហិត ហើយនិងជម្រាបផងដែរដល់អ្នកដែលចូលរួមក្នុងនីតិវិធី និងសាធារណជន សូមអញ្ជើញចូលមកកាន់សាលសវនាការ នៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក ៕

*[សវនាការផ្អាកនៅម៉ោង ១៦:២៥ នាទី]*